**សម្តេច ហ៊ុន សែន**

***នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា***

# អារម្ភកថា

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ (*ផយអជ*) ដែលត្រូវបានអនុម័តកាលពីឆ្នាំ២០០៦ បង្ហាញនូវទិដ្ឋភាពរួមនៃបំណងប្រាថ្នានិងបណ្តាគោលដៅដែលអាចសម្រេចបានសម្រាប់ប្រជាជនកម្ពុជា ស្របគ្នានឹងពេលដែលប្រជាជនកម្ពុជា កំពុងបោះជំហានទៅរកការធ្វើឱ្យប្រសើរឡើងបន្តិចម្តងៗក្នុងស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ច ការពឹងផ្អែកលើខ្លួនឯង ស្ថានភាពរស់នៅនិងគុណភាពនៃជីវិត សន្តិសុខនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស ព្រមទាំងការអភិវឌ្ឍន៍សម្រាប់ប្រជាជនគ្រប់រូបនៅទូទាំងប្រទេស ។ ខ្ញុំបានគូសបញ្ជាក់រួចមកហើយថា "***ផយអជ* គឺជាឯកសារផែនការមួយសម្រាប់ការធ្វើឱ្យមានវឌ្ឍនភាពជាបន្តទៀត ក្នុងការកសាងកម្ពុជា និងជាឯកសារតែមួយដែលរួមបញ្ចូលនូវគ្រប់ឯកសារគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាលសម្រាប់រយៈពេល៥ឆ្នាំខាងមុខ**" ។

ជាមួយគ្នានេះដែរ *ផយអជ* គឺជាឯកសាររស់ដែលអាចធ្វើការកែសម្រួលបានទៀតទាត់ ទៅតាមកាលវេលាកំណត់ តាមរយៈការវាស់វែងនិងការវាយតម្លៃលើវឌ្ឍនភាពដែលមានកន្លងមក ។ ការអនុវត្ត *ផយអជ* នេះ ត្រូវបានគ្រោងទុកថា នឹងធ្វើការតាមដានត្រួតពិនិត្យនិងវាយតម្លៃតាមរយៈរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពីការសម្រេចបាននិងការសម្រេចមិនបានតាមការគ្រោងទុក ព្រមទាំងការកែសម្រួលប្រសិនបើមានការចាំបាច់ ។

របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ដើរតួនាទីជារបាយការណ៍ស្តីពី "ស្ថានភាពរបស់ប្រជាជាតិ" សម្រាប់ប្រជាជនកម្ពុជានិងមជ្ឈដ្ឋានអន្តរជាតិ ។ ដូចគ្នានឹង *ផយអជ* ដែរ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំនេះ ត្រូវបានចាត់ទុកថា ជាឯកសារមួយសម្រាប់អនុវត្ត ។ ឯកសារនេះគឺជាការវាយតម្លៃពីភាពជឿនលឿនដែលបានធ្វើឡើង និងចំណុចខ្វះខាតដែលបានពើបប្រទះកន្លងទៅ ហើយឯកសារនេះក៏ជាមធ្យោបាយមួយសម្រាប់កែសម្រួលកត្តានានា ដោយមិនភ្លេចគិតគូរដល់គោលដៅចម្បងគឺការធ្វើឱ្យសម្រេចបានវឌ្ឍនភាពនិងការកាត់បន្ថយភាពក្រីក្រ ទាំងតាមលក្ខណៈភូមិសាស្ត្រនិងតាមវិស័យនៅទូទាំងប្រទេសទេ ។

របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ២០០៦ ដែលជារបាយការណ៍ឆ្នាំដំបូងនៃការអនុវត្តនី *ផយអជ* ត្រូវបានរៀបចំឡើងដោយឆ្លងកាត់ដំណាក់កាលជាច្រើន នៃការពិគ្រោះយោបល់នៅក្នុងចំណោមអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ ទាំងក្នុងនិងក្រៅរដ្ឋាភិបាល ។ ក្នុងន័យនេះ របាយការណ៍វឌ្ឍនភាពតំណាងឱ្យមតិឯកភាពរួមគ្នាទៅលើខ្លឹមសារទាំងឡាយដែលបានលើកឡើង ។ របាយការណ៍នេះក៏បានបង្ហាញឱ្យឃើញផងដែរនូវទិដ្ឋភាពជាក់ស្តែងរបស់កម្ពុជា ស្របគ្នានឹងពេលដែលទិដ្ឋភាពទាំងនោះ តំណាងឱ្យរូបភាពពិតរបស់កម្ពុជា ។ ដូចគ្នានឹង *ផយអជ* ដែរ របាយការណ៍វឌ្ឍនភាព ត្រូវបានរៀបចំឡើងទៅតាមទម្រង់នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ។

ស្ថានភាពដូចរៀបរាប់ខាងក្រោម គឺជាទិដ្ឋភាពសំខាន់ៗមួយចំនួននៅក្នុងចំណោមសមិទ្ធផលនិងការប្រែប្រួលចម្បងៗជាច្រើនដែលបានកើតមានឡើង ចាប់តាំងពីការអនុវត្តន៍ *ផយអជ* មក :

- ក្នុងផ្នែកអភិបាលកិច្ច ការសម្រេចការបញ្ចប់ដោយជោគជ័យ នៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់លើកទី ២ បានផ្តល់កាលានុវត្តភាពជូនប្រជាជនកម្ពុជា ក្នុងការប្រើប្រាស់សិទ្ធិប្រជាធិបតេយ្យមូលដ្ឋានរបស់ខ្លួន ដោយសេរី បើកចំហ យុត្តិធម៌ និងសន្តិវិធី ហើយក្នុងន័យនេះ មូលដ្ឋានគ្រឹះនៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា កាន់តែត្រូវបានពង្រឹងឡើងថែមទៀតនៅក្នុងប្រទេស ។
- ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចយ៉ាងល្អប្រសើរក្នុងឆ្នាំ ២០០៦ បានធ្វើមានការព្យាករណ៍លើសូចនាករម៉ាក្រូសេដ្ឋកិច្ចជាច្រើននៅកម្រិតមួយខ្ពស់ជាងការរំពឹង ទុកនៅក្នុង *ផយអជ* ។
- សូចនាករសង្គមកិច្ចដែលមានលក្ខណៈល្អប្រសើរជាងមុននិងដែលអាចជឿជាក់បាន ដែលជាលទ្ធផលនៃ *អង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០០៥* ជាពិសេសកម្រិតរីករាលដាលនៃមេរោគហ៊ីវនៅក្នុងចំណោមប្រជាជនពេញវ័យបានថយចុះដល់ ០.៦ ភាគរយ គឺទាបជាងច្រើនពីកម្រិតដែលបានប៉ាន់ស្មាន ១.៩ ភាគរយ ។

បញ្ហាដែលសំខាន់បំផុតនោះ គឺថា គ្រប់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ក្រៅប្រទេសរបស់យើងត្រូវតម្រឹមតម្រង់យ៉ាងហ្មត់ចត់នូវគោលនយោបាយនិងកម្មវិធីរបស់ខ្លួនទៅនឹង *ផយអជ* ។ ភាពរីកចម្រើនត្រង់ចំណុចនេះ នៅមិនទាន់បានឈានទៅកម្រិតដែលចង់បានដូចការរំពឹងទុកនៅឡើយទេ ។ បញ្ហានេះចាំបាច់ត្រូវតែធ្វើការដោះស្រាយជាបន្ទាន់ និងដោយយកចិត្តទុកដាក់ ។ កម្មវិធីកំពុងដំណើរការ និងកម្មវិធីថ្មីទាំងអស់ដែលបានទទួលការគាំទ្រ ត្រូវតែមានការពិនិត្យមើលឡើងវិញដោយយកចិត្តទុកដាក់ ពីក្រុមការងារបច្ចេកទេស ហើយការប្រើប្រាស់ធនធានទាំងអស់ប្រកបដោយលក្ខណៈប្រសើរបំផុត ត្រូវតែធានាធ្វើឱ្យបានជាក់ស្តែង ដើម្បីបង្កើតឱ្យមានការអភិវឌ្ឍន៍សុទ្ធសាធនិងជាក់ស្តែង ជាជាងគ្រាន់តែការលើកឡើងក្នុងរបាយការណ៍និងទទួលជំនួយបច្ចេកទេស ។

ជាថ្មីម្តងទៀត ខ្ញុំសូមឱ្យស្ថាប័នរបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ក្រៅប្រទេសទាំងអស់អនុវត្តយ៉ាងហ្មត់ចត់ ទៅតាមអាទិភាពដែលមានចែងក្នុង *ផយអជ* ហើយខ្ញុំសង្ឃឹមថា ការស្នើឡើងនេះ នឹងត្រូវយកទៅអនុវត្តតាមដោយយកចិត្តទុកដាក់ខ្ពង់ខ្ពស់បំផុត ។

*រាជធានីភ្នំពេញ ថ្ងៃទី* ២៩ *ខែ*មករា*ឆ្នាំ ២០០៧*

ហ៊ុន សែន

## មាតិកា

អារម្ភកថា ........ i
តារាងមាតិកា ........ iii
សញ្ញាជាតិនិងទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា........ iv
គំនូសបំព្រួញនៃយុទ្ធសាស្ត្រចតុកោណ ........ v
សូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗ ........ vi
**ជំពូកទី១** : សេចក្តីផ្តើម ........ ១
**ជំពូកទី២** : វឌ្ឍនភាពក្នុងឆ្នាំ២០០៦ និងស្ថានភាពបច្ចុប្បន្ន ........ ៨
**ជំពូកទី៣** : គោលដៅនិងចំណុចដៅអាទិភាព និង ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ........ ៤១
**ជំពូកទី៤** : ចំណាយ ធនធាន និងការរៀបចំកម្មវិធី ........ ៤៨
**ជំពូកទី៥** : សេចក្តីសន្និដ្ឋាន ........ ៥៥

## តារាង

តារាង ១.១ : សូចនាករសំខាន់ៗនៃការអនុវត្ត *ផយអជ* ឆ្នាំ២០០៦ ........ ៥
តារាង ២.១ : ទិន្នន័យម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ........ ១៧
តារាង ២.២ : ចំណុចដៅសម្រាប់វិស័យកសិកម្ម សម្រាប់ឆ្នាំ២០១០ ........ ២៥
តារាង ២.៣ : ចំណុចដៅសម្រាប់ការអភិវឌ្ឍជនបទ សម្រាប់ឆ្នាំ២០១០ ........ ២៦
តារាង ២.៤ : វិស័យអប់រំ : គោលដៅនិងចំណុចដៅអាទិភាព ........ ៣៦
តារាង ២.៥ : វិស័យសុខាភិបាល : គោលដៅនិងចំណុចដៅអាទិភាព ........ ៣៧
តារាង ៣.១ : គោលដៅចម្បងៗ និងសូចនាករ (ចំណុចដៅ) សំខាន់ៗ របស់ *ផយអជ* ........ ៤៥
តារាង ៤.១ : កម្រិតនៃការវិនិយោគវិស័យសាធារណៈដែលត្រូវការចាំបាច់សម្រាប់ ២០០៦-២០១០........ ៤៨
តារាង ៤.២ : ការបែងចែកធនធានតាមវិស័យ របស់ *ផយអជ* ២០០៦-២០១០ ........ ៥៣

## ឧ

ឧបសម្ព័ន្ធ ១.១ កម្ពុជា : សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ........ ៥៧
ឧបសម្ព័ន្ធ ១.២ កម្ពុជា : ការព្យាករណ៍ការវិនិយោគសម្រាប់ ឆ្នាំ២០០៦-២០១០ ........ ៥៩
ឧបសម្ព័ន្ធ កម្ពុជា : ការប៉ាន់ស្មានការបែងចែកចំណាយចរន្តនៃថវិកាតាមវិស័យនិងក្រសួងអាទិភាព. ៦១
ឧបសម្ព័ន្ធ ១.៤ កម្មវិធីវិនិយោគសាធារណៈ ២០០៦-២០០៨ : តារាងទី ១ : សង្ខេបតាមវិស័យ........ ៦២
ឧបសម្ព័ន្ធ ១.៥ កម្មវិធីវិនិយោគសាធារណៈ ២០០៧-២០០៩ : តារាងទី ១ : សង្ខេបតាមវិស័យ........ ៦៤
ឧបសម្ព័ន្ធ ១.៦ កម្មវិធីវិនិយោគសាធារណៈ ២០០៨-២០១០ : តារាងទី ១ : សង្ខេបតាមវិស័យ........ ៦៦
ឧបសម្ព័ន្ធ ២ ក្របខ័ណ្ឌតាមដានត្រួតពិនិត្យផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ........ ៦៨
ឧបសម្ព័ន្ធ ៣ ពាក្យបំព្រួញ ........ ៧៥

# កម្ពុជា ៖ សូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗ

**ព័ត៌មានទូទៅ**

| | |
|---|---|
| ផ្ទៃដីសរុបៈ គម$^2$ | ១៨១.០៣៥ |
| ចំនួនខេត្ត-ក្រុង | ២៤ |
| ចំនួនទីប្រជុំជន រួមទាំង ទីក្រុងភ្នំពេញ | ១៦២ |
| ចំនួនស្រុក-ខ័ណ្ឌ | ១៨៥ |
| ចំនួនឃុំ-សង្កាត់ | ១.៦២១ |
| ចំនួនភូមិ | ១៣.៨៩០ |
| ឆ្នាំសារពើពន្ធ | មករា-ធ្នូ |
| រូបិយវត្ថុ | រៀល (រ) |

សម្គាល់ ៖ តួលេខឆ្នាំ២០០៩និង២០១០ ដែលបានបង្ហាញនៅក្នុង *ផយអជ* ត្រូវបានកែតម្រូវ នៅក្នុងកន្លែងមួយចំនួន ដោយផ្អែកលើទិន្នន័យថ្មីៗ ឬអង្កេតនានា

| | សូចនាករសំខាន់ៗ | ឯកតា | ២០០៥ | ២០០៦ | ២០១០ |
|---|---|---|---|---|---|
| | | | | ការប៉ាន់ស្មាន | ការព្យាករណ៍ |
| **១.00** | **កម្រិតនៃភាពក្រីក្រ** | | **២០០៤** | | |
| ១.0១ | សរុបទូទាំងប្រទេស | %នៃប្រជាជន | ៣៤.៦៧ | | ២៥.0 |
| | ៥៩%នៃផ្ទៃប្រទេស (អង្កេតឆ្នាំ ១៩៩៣-១៩៩៤) | % | ២៨.0 | | |
| ១.0២ | ភ្នំពេញ | % | ៤.៦ | | |
| ១.0៣ | ទីប្រជុំជនផ្សេងទៀត | % | ២៤.៦ | | |
| ១.0៤ | ជនបទ | % | ៣៩.២ | | |
| ១.0៥ | ប្រជាជនរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ ស្បៀងអាហារ | % | ១៩.៧ | | ១៣.0 |
| **២.00** | **បញ្ហាយេនឌ័រ** | | | | |
| ២.0១ | ស្ត្រីក្នុងកម្លាំងពលកម្ម (ក.ព) ៖ វិស័យកសិកម្ម | %នៃ ក.ព សរុប | ៥២.៥ | | ៥0 |
| ២.0២ | វិស័យឧស្សាហកម្ម | %នៃ ក.ព សរុប | ៥៣.៥ | | ៥0 |
| ២.0៣ | ក្នុងវិស័យសេវាកម្ម | %នៃ ក.ព សរុប | ២៧.0 | | ៣៧.00 |
| **៣.00** | **ប្រជាជន** | | | | |
| ៣.0១ | សរុប | លាននាក់ | ១៣.៨0 | ១៤.0៨ | ១៥.៣ |
| ៣.0២ | ដង់ស៊ីតេប្រជាជន | ក្នុងមួយគម$^2$ | ៧៤(២00៤) | ៧៩ | ៨៤.0 |
| ៣.0៣ | បុរសធៀបនឹងស្ត្រី(១00) | % | ៩៣.៥(២00៤) | ៩៤.៣៨ | ៩៤.៨៥ |
| ៣.0៤ | អាយុ 0-១៤ | % | ៣៩(២00៤) | ៣៧.៣ | ៤៦.៥ |
| ៣.0៥ | អាយុ ១៥-៥៩ | % | ៥៥.១(២00៤) | ៥៧.២ | ៤៥.0 |
| ៣.0៦ | អាយុ ៦0 និង លើសពី៦0 | % | ៥.៩(២00៤) | ៥.៥ | ៤.៨ |
| ៣.0៧ | ជនបទ | % | ៨៥.0 | | ពុំមានតួលេខ |
| ៣.0៨ | ទីប្រជុំជន | % | ១៥.0 | | ពុំមានតួលេខ |
| ៣.0៩ | អត្រាកំណើនប្រចាំឆ្នាំ | % | ១.៨១(២00៤) | | ២.១ |
| ៣.១0 | អត្រាបង្កើតកូនសរុប (ក្នុងស្ត្រីម្នាក់) | កំណើតរស់ | ៣.៤ | | ៣.៤ |
| ៣.១១ | អាយុកាលមធ្យមសង្ឃឹមរស់តាំងពីកំណើត ៖ ប្រុស | ឆ្នាំ | ៥៧.៨៧ | | |
| | ស្ត្រី | ឆ្នាំ | ៦៤.១៤ | | |

| | **សូចនាករសំខាន់ៗ** | **ឯកតា** | **២០០៥** | **២០០៦** | **២០១០** |
|---|---|---|---|---|---|
| | | | | **ការប៉ាន់ស្មាន** | **ការព្យាករណ៍** |
| **៤.00** | **ម៉ាក្រូសេដ្ឋកិច្ច** | | | | |
| ៤.0១ | *ផសស* ប្រចាំឆ្នាំ (គិតតាមថ្លៃថេរ) | ពាន់លានរៀល | ២១.៨១២ | ២៤.0៨0 | ៣១.៩៩២ |
| ៤.0២ | ចំណែកនៃ*ផសស*: កសិកម្ម (ដំណាំ) | % | ១៦,៨៩ | ១៥,៨១ | ១៤,៤0 |
| ៤.0៣ | : បសុសត្វ និង បសុបក្សី | % | ៤,៥៥ | ៤,៤៦ | ៤,៣0 |
| ៤.0៤ | : ជលផល | % | ៧,៨២ | ៧,៣៥ | ៦,១0 |
| ៤.0៥ | : ព្រៃឈើ | % | ២,១៧ | ២,0៩ | ១,៦៤ |
| ៤.0៦ | : កម្មន្តសាល | % | ១៩,៨៦ | ២១,១៩ | ២២,៥៣ |
| ៤.0៧ | : សំណង់ | % | ៦,៣២ | ៦,៦៣ | ៦,៨២ |
| ៤.0៨ | : ទេសចរណ៍(សណ្ឋាគារនិងភោជនីយដ្ឋាន) | % | ៤,១៩ | ៤,៦៨ | ៥,៨៦ |
| ៤.0៩ | : ការដឹកជញ្ជូន | % | ៦,0៩ | ៦,00 | ៥,៥៦ |
| ៤.១0 | : សេវាកម្មផ្សេងៗទៀត | % | ៨,២៨ | ៨,៣២ | ៨,៧៨ |
| ៤.១១ | *ផសស* សម្រាប់ប្រជាជនម្នាក់ | ពាន់រៀល | ១.៨៥៧,៧៧ | ២.១0៤,៨៤ | ២.៨៨៨,៤៥ |
| ៤.១២ | អត្រាកំណើន *ផសស* ប្រចាំឆ្នាំ (ថ្លៃថេរ) | % | ១៣,៤0 | ១0,៨0 | ៧,00 |
| ៤.១៣ | អតិផរណា (មធ្យមប្រចាំឆ្នាំ) | % | ៥,៨0 | ៤,៧ | ៣,00 |
| ៤.១៤ | អត្រាប្តូរប្រាក់ | រៀល/ដុល្លារ | ៤.0៩២ | ៤.១0៣ | ៤.២00 |
| ៤.១៥ | ទុនបំរុងបរទេសសរុប[១] (ជាចំនួនខែនៃការនាំចូលទំនិញ និងសេវាកម្មមិនទាក់ទងនឹងកត្តាផលិតកម្ម ) | ចំនួនខែនាំចូល | ២,៨0 | ២,៩0 | ៣,00 |
| ៤.១៦ | ការវិនិយោគផ្ទាល់ពីបរទេស (ប្រចាំឆ្នាំ) | លានដុល្លារ | ៣៧៥ | ៤៧៥ | ៦២0 |
| **៥.00** | **សារពើពន្ធ** | | | | |
| ៥.0១ | ចំណូលថវិកាសរុប | %នៃ *ផសស* | ១0,៦0 | ១១,៥0 | ១១,៦0 |
| ៥.0២ | ចំណូលពន្ធ | %នៃ *ផសស* | ៧,៨0 | ៨,១0 | ៩,00 |
| ៥.0៣ | ក្នុងនោះ - ពន្ធផ្ទាល់ | %នៃ *ផសស* | 0,៩0 | ១,១0 | ១,៣0 |
| ៥.0៤ | - ពន្ធមិនផ្ទាល់ | %នៃ *ផសស* | ៤,៤0 | ៤,៤0 | ៤,៩0 |
| ៥.0៥ | - ពន្ធពីពាណិជ្ជកម្មអន្តរជាតិ | %នៃ *ផសស* | ២,២0 | ២,២0 | ២,៤0 |
| ៥.0៦ | ចំណូលមិនមែនពន្ធ | %នៃ *ផសស* | ២,៣0 | ២,១0 | ២,៤0 |
| ៥.0៧ | ចំណាយថវិកាសរុប | % នៃ *ផសស* | ១៣,៣0 | ១៤,២0 | ១៤,៩0 |
| ៥.0៨ | ក្នុងនោះ - ចំណាយចរន្ត | %នៃ *ផសស* | ៧,៧0 | ៨,00 | ៩,៥0 |
| ៥.0៩ | - ចំណាយមូលធន | %នៃ *ផសស* | ៥,២0 | ៥,៨0 | ៥ ৭0 |
| **៦.00** | **ជំនួយអភិវឌ្ឍន៍ផ្លូវការ (រួមទាំងអង្គការក្រៅរដ្ឋាភិបាល)** | | | | |
| ៦.0១ | សរុប | លានដុល្លារ | ៥៥0,00 | | ៥៥0,00 |
| ៦.0២ | ជំនួយបច្ចេកទេស | លានដុល្លារ | ពុំមានតួលេខ | | ពុំមានតួលេខ |
| ៦.0៣ | ជំនួយផ្សេងៗទៀត | លានដុល្លារ | ពុំមានតួលេខ | | ពុំមានតួលេខ |
| **៧.00** | **កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | | | | |
| ៧.0១ | ផ្ទៃដីដំណាំ | ពាន់ហត | ២.៨៩៣ | ២.៩៣0 | ៣.៥00 |
| ៧.0២ | ផ្ទៃដីស្រោចស្រព | ពាន់ហត | ៥៩៦,៣ | ៧២១,៣ | ៨១0,៣ |
| ៧.0៣ | ផ្ទៃដីដាំដុះស្រូវ | ពាន់ហត | ២.៤៣៨ | ២.៤៨0 | ២.៥00 |

[១] គណនាតាមនិយមន័យរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ

| | សូចនាករសំខាន់ៗ | ឯកតា | ២០០៥ | ២០០៦ | ២០១០ |
|---|---|---|---|---|---|
| | | | | ប៉ាន់ស្មាន | ព្យាករណ៍ |
| ៧.០៤ | ទិន្នផលក្នុងមួយហិកតា | តោន | ២.៤៨ | ២.៤៩ | ២.៥០ |
| ៧.០៥ | ឡូតិ៍នេសាទ | គម² | ៤.១៥២ | | ៤.១៥០ |
| ៧.០៦ | - សម្រាប់សហគមន៍នេសាទ | % | ៥៦.៥ | | ៥៦.៥ |
| ៧.០៧ | ត្រី : នេសាទបាន (ពីគ្រប់ប្រភព) | តោន | ៣៨០.០០០ | ៥០៥.០០០ | ៤៤៥.០០០ |
| ៧.០៨ | ផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ | %នៃផ្ទៃដី | ៦០ | ៥៩ | ៦០ |
| ៧.០៩ | ព្រៃឈើដាំដុះឡើងវិញ (សរុបផ្ទៃដីដាំដុះតាំងពីឆ្នាំ១៩៨៥) | ហត | ១៥.៧២៩ | ១៦.៨២៥ | ៣០.០០០ |
| ៧.១០ | ការប្រើប្រាស់អុសសម្រាប់ដុត | %គ្រួសារសរុប | ៨៣.៩ | ៨៣.៩ | ៦១.០ |
| ៧.១១ | កំណែទម្រង់ដី : ចំនួនប័ណ្ណកម្មសិទ្ធិដែលបានផ្តល់ជូនកសិករ | %នៃក្បាលដីសរុបទូទាំងប្រទេស | ១៥ | ១៧ | ២៤ |
| **៨.០០** | **ការអភិវឌ្ឍជនបទ** | | | | |
| ៨.០១ | ផ្លូវថ្នល់ដែលបានស្តារ (នៃប្រវែងសរុប ២៨.០០០ គម) | គម | ២២.៧០០ | ២៣.៧១០ | ២៥.០០០ |
| ៨.០២ | លទ្ធភាពទទួលបានទឹកស្អាត (ជនបទ) | %នៃប្រជាជន | ៤១.៦ | ៤២.៦ | ៤៥.០ |
| ៨.០៣ | លទ្ធភាពទទួលបានអនាម័យ (ជនបទ) | %នៃប្រជាជន | ១៥.៧ | ១៥.៨ | ២៥.០ |
| **៩.០០** | **ឧស្សាហកម្ម** | | | | |
| ៩.០១ | ផលិតផលកម្មន្តសាល | ពាន់លានរៀល | ១៥.៩៦០ | ១៩.២៨៤ | ៣០.៦១១ |
| ៩.០២ | ក្នុងនោះ ឧស្សាហកម្មសំលៀកបំពាក់ : ផលិតផល | ពាន់លានរៀល | ៩.៥៧១ | ១២.៧០៩ | ២០.៦០០ |
| ៩.០៣ | : កម្លាំងពលកម្ម | នាក់ | ៣០៥.៦៧៨ | ៣០៧.៩០២ | ៣៦៩.០២៦ |
| **១០.០០** | **ថាមពល** | | | | |
| ១០.០១ | ថាមពលដែលបានប្រើប្រាស់: ប្រេងសាំង & ម៉ាស៊ូត | តោន | ១៩៦.៣២៣ | ២២៧.៩០៨ | ៣១៧.៣៥០ |
| ១០.០២ | អគ្គិសនីដែលផលិតបាន | គីកាវ៉ាត់ម៉ោង | ៨៩៤.៥ | ១.០៧៣.២៨ | ១.៣៨៦.០០ |
| ១០.០៣ | ប្រវែងបណ្តាញខ្សែបញ្ជូនថាមពល (១១៥ KVA) | គម | ១៣៤ | ២៧៩ | ៤៤៤ |
| ១០.០៤ | ចំនួនគ្រួសារប្រើប្រាស់ថាមពល | ចំនួន | ២០៨.៤៧៦ | ២៥០.០០០ | ៣៧០.០០០ |
| ១០.០៥ | ការប្រើប្រាស់ថាមពលរបស់ប្រជាជនម្នាក់ ក្នុង១ឆ្នាំ | គវ៉ម | ៥៤.០១ | ៨៣.៩៥ | ៨៩.១១ |
| **១១.០០** | **ដឹកជញ្ជូន** | | | | |
| ១១.០១ | ផ្លូវជាតិ និងផ្លូវខេត្ត : សរុប | គម | ១១.៣១០ | ១១.៣១០ | ១១.៣១០ |
| | (ផ្លូវកៅស៊ូ) | គម | (២.១០០) | (២.៧៣២) | (៤.១០០) |
| ១១.០២ | ផ្លូវដែក | គម | ៦០២ | ៦០២ | ៦៥០ |
| ១១.០៣ | ចំនួននៃកំពង់ផែអន្តរជាតិ | ចំនួន | ២ | ២ | ២ |
| ១១.០៤ | ចំនួននៃអាកាសយានដ្ឋានអន្តរជាតិ | ចំនួន | ២ | ៣ | ៥ |
| **១២.០០** | **ទូរគមនាគមន៍** | | | | |
| ១២.០១ | ទូរសព្ទ័ដែលកំពុងប្រើប្រាស់ (ខ្សែ និងចល័ត) | ពាន់គ្រឿង | ៨៨២ | ១.១៧៩ | ១.៤៦៩ |
| ១២.០២ | អ្នកប្រើប្រាស់អ៊ិតធ័រណែត | នាក់ | ៨.៦៣២ | ៨.៩៦០ | ២២.៥០០ |
| **១៣.០០** | **ទេសចរណ៍** | | | | |
| ១៣.០១ | ចំនួនភ្ញៀវទេសចរណ៍មកដល់ | លាននាក់ | ១.៣០ | ១.៧០ | ៣.១២ |
| ១៣.០២ | ប៉ាន់ស្មានចំណូលជារូបិយប័ណ្ណបរទេស | លានដុល្លារ | ៦០០.០០ | ១.០៤៩ | ១.៥០០.០០ |
| | | | | | |

| សូចនាករសំខាន់ៗ | | ឯកតា | ២០០៥ | ២០០៦ | ២០១០ |
|---|---|---|---|---|---|
| | | | | ការប៉ាន់ស្មាន | ការព្យាករណ៍ |
| **១៤.00** | **ព័ត៌មានសាធារណៈ** | | | | |
| ១៤.0១ | អង្គភាពសារព័ត៌មានប្រចាំថ្ងៃជាភាសាខ្មែរ | អង្គភាព | ១៦ | ២៣ | ៣៥ |
| ១៤.0២ | អង្គភាពសារព័ត៌មានប្រចាំថ្ងៃជាភាសាអង់គ្លេស | អង្គភាព | ៦ | ១0 | ១៨ |
| ១៤.0៣ | ចំនួនស្ថានីយ៍វិទ្យុក្នុងស្រុក | ចំនួន | ២១ | ២២ | ២៧ |
| ១៤.0៤ | ចំនួនស្ថានីយ៍ទូរទស្សន៍ក្នុងស្រុក | ចំនួន | ១៤ | ១៥ | ១៧ |
| ១៤.0៥ | ចំនួនទូរទស្សន៍ដែលប្រជាជនប្រើប្រាស់ | ពាន់គ្រឿង | ៧00 | ១.000 | ១.៨00 |
| **១៥.00** | **សុខាភិបាល** | | | | |
| ១៥.0១ | អត្រាមរណភាពទារក | ក្នុង១.000កំណើត | ៦៦ | ៦៥ | ៦0 |
| ១៥.0២ | អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ | ក្នុង១.000កំណើត | ៨២ | ៨២ | ៨៣ |
| ១៥.0៣ | ទារកអាយុក្រោម១ឆ្នាំដែលទទួលវ៉ាក់សាំង ប្រឆាំង DPT3 | % | ៨៣ | ៧៦ | ៨៥ |
| ១៥.0៤ | ទារកអាយុក្រោម១ឆ្នាំដែលទទួលវ៉ាក់សាំងប្រឆាំងជម្ងឺកញ្ជ្រិល | % | ៨0 | ៧0 | ៨៥ |
| ១៥.0៥ | មរណភាពមាតា | ក្នុង ១00.000កំណើត | ពុំមានតួលេខ | ៤៧២ | ២៤៣ |
| ១៥.0៦ | ការបង្កើតកូនដោយបុគ្គលិកសុខាភិបាល ដែលមានជំនាញ | % | ៤៤ | ពុំមានតួលេខ | ៧0 |
| ១៥.0៧ | ករណីជម្ងឺគ្រុនចាញ់ : ព្យាបាលនៅមណ្ឌលសុខភាពសាធារណៈ | ក្នុង១000ករណី | ៧,៣0 | ៥,១0 | ៦,00 |
| ១៥.0៨ | អត្រាស្លាប់ដោយជម្ងឺគ្រុនចាញ់ | % | 0,៣៦ | 0.៣៥ | 0,២៥ |
| ១៥.0៩ | ប្រេវ៉ាឡង់ជម្ងឺរបេងក្នុងចំណោមអ្នកពិនិត្យសួត | ក្នុង១00.000 | ពុំមានតួលេខ | ២៦៩ | ២១៤ |
| ១៥.១0 | អត្រាស្លាប់ដោយជម្ងឺរបេង | ក្នុង១00.000 | ពុំមានតួលេខ | | ៦0 |
| ១៥.១១ | ហ៊ីវ/អេដស៍:អត្រាប្រេវ៉ាឡង់មនុស្សពេញវ័យ | %(១៥-៤៩ឆ្នាំ) | ១,៩ | 0,៦0 | 0,៥ |
| ១៥.១២ | មន្ទីរពេទ្យបង្អែក | ចំនួន | ៦៩ | ៦៩ | |
| ១៥.១៣ | មណ្ឌលសុខភាព | ចំនួន | ៩៦៥ | ៩៧២ | |
| ១៥.១៤ | ការទទួលបានទឹកស្អាត (ទីប្រជុំជន) | %នៃប្រជាជន | ៣៥,0 | ៣៧,0 | ៧៥,0 |
| ១៥.១៥ | ការទទួលបានអនាម័យ (ទីប្រជុំជន) | %នៃប្រជាជន | ៥៥,0 | | ៦៧,0 |
| **១៦.00** | **អប់រំ** | | **២00៤-២00៥** | **២00៥-២00៦** | **២00៩-២0១0** |
| ១៦.0១ | សាលាបឋមសិក្សា | ចំនួន | ៦.១៨0,0 | ៦.២៧៧,0 | ពុំមានតួលេខ |
| ១៦.0២ | ចម្ងាយផ្លូវឆ្ងាយបំផុតទៅសាលាបឋម សិក្សា | គម | ២,0 | | ១,៥0 |
| ១៦.0៣ | អត្រាពិតនៃការសិក្សា : សរុប | % | ៩១,៩ | ៩១,៣ | ១00 |
| | ប្រុស | % | ៩៣,0 | ៩៣,0 | ១00 |
| | ស្រី | % | ៩0,៧ | ៨៩,៧ | ១00 |
| ១៦.0៤ | អត្រាពិតនៃការសិក្សា : ទីប្រជុំជន | % | ៩១,៦ | ៩១,២ | ១00 |
| | ជនបទ | % | ៩២,៤ | ៩១,៧ | ១00 |
| | តំបន់ដាច់ស្រយាល | % | ៨២,៥ | ៨៣,៧ | ១00 |
| ១៦.0៥ | អត្រាគង់វង្សសិស្សថ្នាក់ទី១-ទី៦ | % | ៥៣,១ | ៤៨,១៥ | ១00 |
| ១៦.0៦ | ចំនួននៃសាលាមធ្យមសិក្សាបឋមភូមិ | ចំនួន | ៨00 | ៩១១ | |
| ១៦.0៧ | ចម្ងាយផ្លូវឆ្ងាយបំផុតទៅសាលាមធ្យមសិក្សាបឋមភូមិ | គម | ៨ | | ៤ |
| | | | | | |

| | សូចនាករសំខាន់ៗ | ឯកតា | ២០០៥ | ២០០៦ | ២០១០ |
|---|---|---|---|---|---|
| | | | | ការប៉ាន់ស្មាន | ការព្យាករណ៍ |
| ១៦.០៨ | អត្រាពិតនៃការសិក្សា : សរុប | % | ២៦.១ | ៣១.៣ | ៥០ |
| | ប្រុស | % | ២៧.៣ | ៣២.១ | ៥០ |
| | ស្រី | % | ២៤.៨ | ៣០.៤ | ៥០ |
| ១៦.០៩ | អត្រាពិតនៃការសិក្សា : ទីប្រជុំជន | % | ៤១.៣ | ៥០.១ | ៧៥ |
| | តំបន់ជនបទ | % | ២៣.៧ | ២៨.៦ | ៥០ |
| | តំបន់ដាច់ស្រយាល | % | ៣.៩ | ០៦.០ | ៥០ |
| ១៦.១០ | អត្រាគង់វង្សសិស្សថ្នាក់ទី១-ទី៩ | % | ២៩.៣ | ២៦.៤៨ | ៥០ |
| ១៦.១១ | ចំនួនអក្ខរជនអាយុ ១៥-២៤ឆ្នាំ | % | ៨៣.៤ | ៨៤.៧ | ៩៥ |
| **១៧.០០** | **កម្មវិធីសំអាតមីន** | | | | |
| ១៧.០១ | ជនរងគ្រោះដោយសារមីនប្រចាំឆ្នាំ (ស្លាប់ និង របួស) | នាក់ | ៨៧៥ | ៤៤០ | ២០០ |
| ១៧.០២ | សរុបផ្ទៃដីដែលបានបោសសំអាតមីន-យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ | ហត | ៣០.២៦៣ | ៣៥.៤៣៦ | ៤៥.០០០ |
| ១៨.០០ | **វប្បធម៌** | | | | |
| ១៨.០១ | ចំនួនភ្ញៀវជាតិ-អន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | នាក់ | ៦៦.៥៧១ | ៩១.៥០៨ | ១០០.០០០ |
| ១៨.០២ | ចំណូលជារូបិយប័ណ្ណបរទេស | ដុល្លារ | ១២៩.១៧៧ | ១៨៣.៣៨១ | ៩០០.០០០ |
| ១៨.០៣ | ចំណូលជាប្រាក់រៀល | ពាន់រៀល | ៥.៦៥៦ | ៨.១៧៦ | ១០.០០០ |

# ជំពូកទី១

## សេចក្តីផ្តើម

១.០១ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(*ផយអជ*) ២០០៦-២០១០ ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ និងត្រូវបានប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រម ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ។ ផែនការនេះ ត្រូវបានចាត់ទុកជាឯកសារគោលនយោបាយតែមួយគត់ ដែលគ្របដណ្តប់លើគ្រប់វិស័យ និងដាក់បញ្ចូលបណ្តាគោលដៅនិងយុទ្ធសាស្ត្រអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់បន្ថយភាពក្រីក្រឱ្យបានឆាប់រហ័ស ហើយដើម្បីឈានទៅសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា(*គអសក*) និងគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចនានា សម្រាប់ជាផលប្រយោជន៍របស់ប្រជាជនកម្ពុជាទាំងមូល ។ *ផយអជ* នឹងត្រូវដាក់ឱ្យដំណើរការ ដើម្បីសម្រេចបានគោលដៅទាំងឡាយដែលមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណ ។

១.០២ *ផយអជ* ដែលជាឯកសាររស់ នឹងត្រូវបានធ្វើបច្ចុប្បន្នភាពនិងកែសម្រួល ទៅតាមវឌ្ឍនភាពដែលបានកើតឡើង និងដែលត្រូវបានតាមដានត្រួតពិនិត្យ តាមរយៈការវាយតម្លៃជារៀងរាល់ឆ្នាំ ។ ឯកសារនេះ គឺជារបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពីការអនុវត្ត*ផយអជ* ក្នុងឆ្នាំ២០០៦ ។ របាយការណ៍នេះ ធ្វើបច្ចុប្បន្នភាពរាល់ទិន្នន័យទាំងអស់ ដែលមានក្នុង*ផយអជ* សម្រាប់ឆ្នាំគោល២០០៥ និងដែលត្រូវបានព្យាករធ្វើការសម្រាប់រយៈពេល៥ឆ្នាំ ២០០៦-២០១០ ។ ឯកសារនេះបង្ហាញពីចំណុចសំខាន់ៗ និងវិភាគពីវឌ្ឍនភាពនិងការធ្វើចំណោលទាំងក្នុង រូបភាពជាបរិមាណ ទាំងក្នុងរូបភាពជាគុណភាព ។

១.០៣ ទិសដៅសំខាន់ៗនៃរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពីការអនុវត្ត*ផយអជ* រួមមាន :

- វាយតម្លៃ ពិនិត្យមើលឡើងវិញ និងលើកឡើងពីវឌ្ឍនភាព ឬការមិនសម្រេចបាន ដែលបានកើតឡើងក្នុងការអនុវត្ត*ផយអជ* នៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់ ក្នុងឆ្នាំ២០០៦ ដោយមានការវិភាគពីមូលហេតុនៃការសម្រេចបាន ឬ ការមិនសម្រេចបានគោលដៅណាមួយ ។
- ផ្តល់ដំណឹងដល់អ្នករៀបចំគោលនយោបាយ ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស និងមជ្ឈដ្ឋានសាធារណៈក្នុងស្រុក អំពីវឌ្ឍនភាព ឬការមិនសម្រេចបានគោលដៅណាមួយ ។
- ដើរតួនាទីជារបាយការណ៍ប្រចាំឆ្នាំស្តីពី "ស្ថានភាពរបស់ប្រជាជាតិ" ដើម្បីផ្តល់ពី "ទិដ្ឋភាពរួមសំខាន់ៗ" របស់កម្ពុជា ដែលអាចប្រើប្រាស់ជាឯកសារយោង និងជាប្រភពឯកសារ សម្រាប់អ្នកដែលមានចំណែកពាក់ព័ន្ធទាំងឡាយ ដែលមានចំណាប់អារម្មណ៍មកលើប្រទេសកម្ពុជា រួមទាំងវិនិយោគិនណា ដែលមានបំណងមកវិនិយោគនៅកម្ពុជាផង ។

១.០៤ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពីការអនុវត្ត*ផយអជ* នឹងបង្ហាញទៅតាមទីតាំងសមស្រប នូវបញ្ហាដូចខាងក្រោម ៖

- វឌ្ឍនភាពក្នុងការអនុវត្តយុទ្ធសាស្ត្រនិងសកម្មភាពសំខាន់ៗនៅក្នុងវិស័យផ្សេងៗ ដែលបានកំណត់នៅក្នុង*ផយអជ* ជាពិសេស ការរៀបចំផែនការតាមវិស័យនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ នៅក្នុងវិស័យណាមួយ ដែលពុំទាន់មានផែនការនេះនាពេលបច្ចុប្បន្ន ។
- ការវាយតម្លៃពីវឌ្ឍនភាព ក្នុងការធ្វើឱ្យសម្រេចបាននូវសូចនាករសំខាន់ ដែលបានជ្រើសរើសនៅក្នុង *ផយអជ* ( តារាង ៣.២ ក្នុង*ផយអជ* ) ។
- កម្រិតនៃការតម្រឹមតម្រង់ ការសន្យា និងការផ្តល់មូលនិធិដោយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ចំពោះអាទិភាពតាមវិស័យ ដែលបានកំណត់នៅក្នុង*ផយអជ*( តារាង ៥.២ នៃ*ផយអជ* ) ។
- អនុសាសន៍ និងការកែសម្រួល ដែលស្នើឡើងសម្រាប់*ផយអជ* ។

១.០៥ លក្ខណៈសំខាន់ៗនៃរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពីការអនុវត្ត*ផយអជ* គឺ ៖

- ឯកសារនេះ គ្របដណ្តប់លើគ្រប់បញ្ហា ( ការងារនយោបាយ អភិបាលកិច្ច សេដ្ឋកិច្ច និង សង្គមកិច្ច) ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេស ទៅលើការកាត់បន្ថយភាពក្រីក្រ និងការធ្វើឱ្យសម្រេចបាន*គអសក* ។
- របាយការណ៍នេះ ក៏ដូចជា*ផយអជ*ដែរ គឺឯកសារមួយដែលរាជរដ្ឋាភិបាលធ្វើជាម្ចាស់ ។ របាយការណ៍នេះ គឺជាឯកសារមួយយ៉ាងសំខាន់ ហើយនឹងក្លាយជាឯកសារគោលជំហររបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់*វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា* ដែលនឹងជំនួស*កិច្ចប្រជុំក្រុមពិគ្រោះយោបល់* ចាប់ពីឆ្នាំ២០០៧ តទៅ ។
- ដោយសាររបាយការណ៍នេះ គ្រាន់តែជាការធ្វើបច្ចុប្បន្នភាពវឌ្ឍនភាពក្នុងការអនុវត្ត*ផយអជ* នោះរបាយការណ៍នេះ នឹងមិនចាំបាច់លើកឡើងជាថ្មីម្តងទៀត ឬបង្ហាញឡើងវិញ (លើកលែងតែមានការចាំបាច់ណាមួយក្នុងការធ្វើបែបនេះ) នូវគ្រប់ទិសដៅ គោលការណ៍ យុទ្ធសាស្ត្រ កម្មវិធី និងផែនការការងារសំខាន់ៗទាំងអស់ ដែលបានកំណត់នៅក្នុង*ផយអជ* ។
- របាយការណ៍នេះ ត្រូវបានរៀបចំឡើងទៅតាមទម្រង់នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាដូចគ្នានឹង *ផយអជ* ដែរ ។
- របាយការណ៍នេះបង្ហាញពីទិន្នន័យនៅក្នុងតារាងនានា ដែលនឹងបង្ហាញពីតួលេខដែលបានព្យាករណ៍នៅក្នុង*ផយអជ* និងពីការកែសម្រួល ( ប្រសិនបើមាន) ។

១.០៦ របាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្ត*ផយអជ*នេះ ផ្អែកលើ ៖

- ព័ត៌មានពីក្រសួង-ស្ថាប័ននានា ។
- របកគំហើញថ្មីៗមួយចំនួន ដែលបានមកពីការសិក្សាស្រាវជ្រាវរបស់ក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ស្ថាប័នស្រាវជ្រាវនានា ដូចជា វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជា ព្រមទាំង អង្គការសង្គមស៊ីវិល ដូចជា អង្គការក្រៅរដ្ឋាភិបាល ជាដើម ។
- ទិន្នន័យថ្មីៗដែលបានមកពីការអង្កេតផ្សេងៗ ដែលត្រូវបានបញ្ចប់នៅក្នុងឆ្នាំ២០០៦ ។
- ការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធ ជាមួយក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៏ក្រៅប្រទេស ។

១.០៧ ការប្រែប្រួលសំខាន់ៗ ដែលបានកើតឡើង ចាប់តាំងពីការរៀបចំ *ផយអជ* មក រួមមាន :

- ជោគជ័យដ៏ចំបងមួយជំហានទៀតនៅក្នុងការលើកកម្ពស់ស្ថេរភាពក្នុងអភិបាលកិច្ច តាមរយៈការធ្វើវិសោធនកម្មដ៏សំខាន់លើរដ្ឋធម្មនុញ្ញ ដែលធ្វើឱ្យការងារនីតិប្បញ្ញត្តិអាចប្រព្រឹត្តទៅបាន តាមរយៈការអនុម័តច្បាប់ដោយសម្លេងភាគច្រើនដាច់ខាត ជំនួសឱ្យតម្រូវការសម្លេង២/៣ដែល ជាឧបសគ្គដ៏ធំមួយនៅក្នុងពេលនោះ ។

- ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់លើកទី២ សម្រាប់ឃុំ-សង្កាត់ ១.៦២១ នៅទូទាំងប្រទេស ដែលមានប្រជាជនមានសិទ្ធិបោះឆ្នោតប្រមាណ ៦៨ភាគរយបានចូលរួម បានប្រព្រឹត្តិទៅនៅដើមខែមេសាឆ្នាំ២០០៧ ប្រកបដោយសន្តិវិធី មានសេរីភាពនិងយុត្តិធម៌ ហើយបានបង្ហាញជាថ្មីម្តងទៀតថា លទ្ធិប្រជាធិបតេយ្យនៅកម្ពុជាត្រូវបានជំរុញនិងធ្វើឱ្យប្រសើរឡើងដោយប្រជាជនកម្ពុជា និងបានចាក់ឫសយ៉ាងរឹងមាំនៅក្នុងប្រទេស ព្រមទាំងក្លាយជាផ្នែកមួយនៃរចនាសម្ព័ន្ធសង្គម និងនយោបាយ ។
- កំណើនសេដ្ឋកិច្ច ដែលពិនិត្យមើលឃើញតាមរយៈកំណើនជិតពីរដង នៃផលិតផលក្នុងស្រុកសរុប (*ផសស*)គិតតាមថ្លៃថេរ ដែលស្ទុះឡើងពីការប៉ាន់ស្មានប្រមាណ ៧ភាគរយ ដល់ ១៣,៤ភាគរយ សម្រាប់ឆ្នាំ២០០៥ ដោយសារមានការកើនឡើងក្នុងវិស័យកសិកម្ម ឧស្សាហកម្មកាត់ដេរ សំណង់ និងទេសចរណ៍ ជាពិសេស ការកើនឡើងយ៉ាងខ្លាំងនៃផលលិតកម្មកសិកម្ម ។
- កំណើនខ្ពស់ក្នុងវិស័យកសិកម្ម (ដំណាំ) គឺ ២៨,០ភាគរយ[១] ក្នុងឆ្នាំ២០០៥ ខ្ពស់ជាងការប៉ាន់ស្មាន ៨,០ភាគរយនៅក្នុង*ផយអជ* ដែលជាបច្ច័យល្អនៃការវិនិយោគក្នុងផ្នែកធារាសាស្ត្រ និងភាពអំណោយផលល្អនៃអាកាសធាតុ ។
- ការមកដល់នៃភ្ញៀវទេសចរបរទេស មានចំនួន ១,៧លាននាក់ ក្នុងឆ្នាំ២០០៦ កើនលើសតួលេខឆ្នាំ២០០៥ ដែលមានតែ ១,៣លាននាក់ ប៉ុណ្ណោះ ។

[១] គណនេយ្យជាតិកម្ពុជា ឆ្នាំ១៩៩៣-២០០៥, ព្រឹត្តិប័ត្រលេខ១០, វិជ្ជាស្ថានជាតិស្ថិតិ, ក្រសួងផែនការ

- ភាពប្រសើរឡើងជាទូទៅក៏បានកើតមានឡើងនៅក្នុងវិស័យដទៃទៀតផងដែរ ដោយសារការជះឥទ្ធិពលខ្លាំងនៃកំណើននៅក្នុងវិស័យកសិកម្ម ប៉ុន្តែទោះជាដូចនេះក្តី សមាមាត្ររបស់វិស័យដទៃទៀតក្នុង *ផសស* បានថយចុះ ប្រៀបធៀបជាមួយនឹងការប៉ាន់ស្មានកន្លងទៅ ។
- ដោយសារតែការប្រែប្រួលទាំងនេះ ការកែតម្រូវត្រូវបានធ្វើឡើង ចំពោះទិន្នន័យម៉ាក្រូសេដ្ឋកិច្ចផ្សេងទៀត សម្រាប់ឆ្នាំ២០០៦ ដល់ ២០១០ រួមទាំង ព្យាករណ៍លើផ្នែកសារពើពន្ធផងដែរ ។
- លទ្ធផលចុងក្រោយដែលបានពីអង្កេតប្រជាសាស្ត្រនិងសុខភាព បានបញ្ជាក់ជាថ្មីថា គោលនយោបាយ ផែនការ និងកម្មវិធី ដែលបានកំណត់និងអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា បានបង្កើតនូវសមិទ្ធផលជាវិជ្ជមាន នៅក្នុងវិស័យសុខាភិបាល ។ ប្រការដែលគួរឱ្យកត់សម្គាល់នោះគឺថា អត្រាប្រេវ៉ាឡង់ហ៊ីវ/អេដស៍នាពេលបច្ចុប្បន្ន ដោយផ្អែកតាមអង្កេតប្រជាសាស្ត្រនិងសុខភាព២០០៥ មានត្រឹមតែ ០,៦ភាគរយ គឺទាបជាង ៧០ភាគរយនៃកម្រិតប៉ាន់ស្មានកន្លងមក ដែលមានរហូតដល់ ១,៩ ភាគរយ ។
- ក្របខ័ណ្ឌតាមដានត្រួតពិនិត្យ ដែលបានពិនិត្យពិចារណាយ៉ាងល្អិតល្អន់និងមានភាពអាចបត់បែនបាន ត្រូវបានរៀបចំឡើង និងដាក់ឱ្យអនុវត្ត សម្រាប់ការតាមដានត្រួតពិនិត្យជាប្រចាំនូវវឌ្ឍនភាពនៃការអនុវត្ត *ផយអជ* ។
- ការរំពឹងទុកលើការធ្វើអាជីវកម្មនិងការប្រើប្រាស់ នូវធនធានឧស្ម័ននិងធនធានធម្មជាតិទាំងឡាយប្រកបដោយជោគជ័យ បានផ្តល់ក្តីសង្ឃឹមយ៉ាងច្រើនចំពោះលទ្ធភាពទទួលបានជោគជ័យ នាពេលអនាគត ។
- *ផយអជ* ត្រូវបានធ្វើការផ្សព្វផ្សាយនៅថ្នាក់ក្រោមជាតិ ។

១.០៨ ការប៉ាន់ស្មានដំបូង ដែលនឹងត្រូវធ្វើការកែសម្រួលឡើងវិញនៅក្នុងឆមាសទី១នៃឆ្នាំ២០០៧ លើគ្រប់ទិន្នន័យ ដែលបានមកពីគ្រប់វិស័យទាំងអស់ ក៏បានបង្ហាញឱ្យឃើញពីកំណើនយ៉ាងខ្លាំងនៅឆ្នាំ២០០៦ ដែរ ។ *ផសស* ត្រូវបានរំពឹងទុកថា បានកើនឡើងក្នុងកម្រិតខ្ពស់ គឺ ១០,៨ភាគរយ ថែមពីលើសន្ទុះដ៏ខ្លាំងដែលមាននៅក្នុង ឆ្នាំ២០០៥ ។ ចំណូលសម្រាប់មនុស្សម្នាក់បានកើនឡើងពី ១,៨៦លានរៀលក្នុងឆ្នាំ២០០៥ ដល់ ២,១០លានរៀលក្នុងឆ្នាំ២០០៦ ដោយមានការគ្រប់គ្រងអតិផរណាបានល្អ ។ ការកើនឡើងនៃចំណូលសម្រាប់មនុស្សម្នាក់នេះ ក៏ឆ្លុះបញ្ចាំងឱ្យឃើញផងដែរអំពីការរីករាលដាលនៃផលប្រយោជន៍ទៅដល់តំបន់ និងប្រជាជនដែលកន្លងមកមិនទាន់បានទទួលផលប្រយោជន៍ពីកំណើនសេដ្ឋកិច្ច ។

១.០៩ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាយ៉ាងមុតមាំ ចំពោះគោលការណ៍ទាំងឡាយ ដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ និង *ផយអជ* ក្នុងការធ្វើឱ្យសម្រេចបានកំណើនសម្រាប់ប្រជាជនកម្ពុជាទាំងមូល តាមរយៈកំណើនសេដ្ឋកិច្ចនិងកិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយភាពក្រីក្រ ។ ទិសដៅនិងការប្តេជ្ញាចិត្តយ៉ាងមុតមាំ

របស់រាជរដ្ឋាភិបាល គឺដើម្បីជំរុញនិងលើកកម្ពស់កិច្ចខិតខំប្រឹងប្រែង សំដៅឱ្យមានការលើកទឹកចិត្តនិងការអនុវត្តយ៉ាងសកម្ម នូវបណ្ដាគោលនយោបាយនិងសកម្មភាពទាំងឡាយ ដែលអាចនាំឱ្យមានការកើនឡើងនូវការចូលរួម (ទាំងបរិមាណ ទាំងគុណភាព) របស់ប្រជាជនពីគ្រប់ផ្នែកទាំងអស់ ក្នុងឋានៈជាអ្នករួមចំណែកនិងជាអ្នកទទួលផលនៅក្នុងកិច្ចការអភិបាលកិច្ចជាតិ និងការកសាងជាតិ ។ ក្នុងន័យនេះ ទិសដៅ គោលដៅ និងចំណុចដៅនៃ*ផយអជ* គួរតែត្រូវ បានអនុវត្ត ដោយមានការប្ដេជ្ញាចិត្តខ្ពស់បំផុត ។

១.១០ ស្ថានភាពរួមនៃលទ្ធផលនៃការអនុវត្ត*ផយអជ* ក្នុងឆ្នាំ២០០៦ មានបង្ហាញដោយសង្ខេបក្នុងតារាង ១.១ ខាងក្រោម ៖

**តារាង ១.១ ៖ សូចនាករសំខាន់ៗនៃការអនុវត្ត*ផយអជ* ឆ្នាំ២០០៦**

| សូចនាករ | ២០០៥ | ២០០៦ (ជាក់ស្តែង) |
|---|---|---|
| **ម៉ាក្រូសេដ្ឋកិច្ច** | | |
| *ផសស* ពិត % ប្រែប្រួល | ១៣.៤ | ១០.៨០ |
| *ផសស* សម្រាប់ប្រជាជនម្នាក់ (ពាន់រៀល) | ១.៨៥៧.៧៧[១] | ២.១០៤.៨៤[២] |
| អតិផរណា (មធ្យមប្រចាំឆ្នាំ- %ប្រែប្រួល) | ៥.៨ | ៤.៧ |
| ចំណូល (%នៃផសស) | ១០.៦ | ១១.៥ |
| -- ចំណូលពន្ធ (%នៃផសស) | ៧.៨ | ៨.១ |
| ចំណាយ (%នៃផសស) | ១៣.៣ | ១៤.២ |
| -- ចរន្ត (%នៃផសស) | ៧.៧ | ៨.០ |
| ការវិនិយោគផ្ទាល់ពីបរទេស (លានដុល្លារ) | ៣៧៥ | ៤៧៥ |
| **វិស័យកសិកម្ម** | | |
| ផលិតផលស្រូវ (លានតោន) | ៥.៩៨ | ៦.២៦ |
| ទិន្នផលស្រូវក្នុងមួយហិកតា (តោន) | ២.៤៨ | ២.៤៩ |
| ការនេសាទ (ទឹកសាប សមុទ្រ និងវារីវប្បកម្ម) តោន | ៣៤០.០០០ | ៥០៥.០០០ |
| ផ្ទៃដីស្រោចស្រព រួមទាំងការស្រោចស្រពបន្ថែម (ពាន់ហិកតា) | ៥៩៦.៣ | ៧២១.៣ |
| កំណែទម្រង់ដី ៖ ចំនួនប័ណ្ណកម្មសិទ្ធិដែលបានផ្តល់ជូនកសិករ | ១៥* | ១៧ |
| ផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ (%នៃផ្ទៃដីសរុប) | ៦០* | ៥៩ |
| ការពឹងផ្អែកលើឈើដុត (អុស ធ្យូង) ៖ គ្រួសារ (%) | ៨៥.៥* | ៨៣.៩ |
| **វិស័យអភិវឌ្ឍន៍ជនបទ** | | |
| ផ្លូវលំជនបទដែលស្តារបានគម(ក្នុងចំណោមផ្លូវសរុប២៨.០០០គម) | ២២.៧០០* | ២៣.៧១០ |

[១] ស្មើនឹង ៤៥៤ដុល្លារ គិតតាមអត្រាប្តូរប្រាក់ ៤.០៩២រៀលក្នុងមួយដុល្លារ

[២] ស្មើនឹង ៥១៣ដុល្លារ គិតតាមអត្រាប្តូរប្រាក់ ៤.១០៣រៀលក្នុងមួយដុល្លារ

| សូចនាករ | | ២០០៥ | ២០០៦ (ជាក់ស្តែង) |
|---|---|---|---|
| ការទទួលបានទឹកស្អាតបរិភោគ (%នៃប្រជាជននៅជនបទ) | | ៤១,៦* | ៤២,៦ |
| ការទទួលបានអនាម័យ (%នៃប្រជាជននៅជនបទ) | | ១៥,៧ | ១៥,៨ |
| **វិស័យអប់រំ** | | | |
| អត្រាពិតនៃការសិក្សានៅសាលាបឋមសិក្សា (១-៦) (%) : | សរុប | ៩១,៩* | ៩១,៣ |
| | ប្រុស | ៩៣,០* | ៩៣,០ |
| | ស្រី | ៩០,៧* | ៨៩,៧ |
| អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ (៧-៩) (%) : | សរុប | ២៦,១* | ៣១,៣ |
| | ប្រុស | ២៧,១* | ៣២,១ |
| | ស្រី | ២៤,៨* | ៣០,៤ |
| អត្រាគង់វង្សសិស្សថ្នាក់ទី១-ទី៦ (%) | | ៥៣,១* | ៤៨,២ |
| អត្រាគង់វង្សសិស្សថ្នាក់ទី១-ទី៩ (%) | | ២៩,៣ | ២៦,៥ |
| អត្រាអក្ខរជនអាយុ ១៥-២៤ឆ្នាំ (%) | | ៨៣,៤* | ៨៤,៧ |
| **វិស័យសុខាភិបាល** | | | |
| អត្រាមរណៈភាពទារក ក្នុង ១.០០០កំណើតរស់ | | ៦៦* | ៦៦ |
| អត្រាមរណៈភាពកុមារក្រោមអាយុ ៥ឆ្នាំ ក្នុង ១.០០០ កំណើតរស់ | | ៨២* | ៨៣ |
| ផលធៀបមរណៈភាពមាតា ក្នុង ១០០.០០០កំណើតរស់ | | ពុំមានតួលេខ | ៤៧២ |
| អត្រាយុវជនដែលផ្ទុកហ៊ីវ/អេដស៍ (%យុវជនអាយុ១៥-៤៩) | | ១,៩* | ០,៦ |
| ជម្ងឺគ្រុនចាញ់ : អត្រាស្លាប់ (%) | | ០,៣៦* | ០,៣៩ |
| ប្រេវ៉ាឡង់ជម្ងឺរបេងក្នុងចំណោមអ្នកពិនិត្យសួត ១០០.០០០នាក់ | | ពុំមានតួលេខ | ២៦៩ |

*កំណត់សម្គាល់* : តួលេខក្នុងឆ្នាំ២០០៥ ដែលមានសញ្ញា (*) ជាតួលេខប៉ាន់ស្មានក្នុង *ផយអជ* ហើយតួលេខដែលគ្មានសញ្ញាជាតួលេខជាក់ស្តែង

១.១១ ជំពូកបន្តបន្ទាប់ទៀតនៃឯកសារនេះ នឹងបង្ហាញជូនជាលម្អិតបន្ថែមទៀត នូវព័ត៌មានស្តីពីវឌ្ឍនភាពក្នុងឆ្នាំ២០០៦ និងព្យាករណ៍ដែលមានការផ្លាស់ប្តូរ សម្រាប់ពេលអនាគត ទាំងតួលេខ ទាំងគុណភាព ។

*ជំពូកទី២* : វឌ្ឍនភាពក្នុងឆ្នាំ២០០៦ និង យុទ្ធសាស្ត្រនិងការរំពឹងទុកនាពេលអនាគត ។

*ជំពូកទី៣* : គោលដៅនិងចំណុចដៅអាទិភាព និង ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ។

*ជំពូកទី៤* : ចំណាយ ធនធាន និងការរៀបចំកម្មវិធី ។

*ជំពូកទី៥* : សេចក្តីសន្និដ្ឋាន ។

***ឧបសម្ព័ន្ធ :***

១.១ កម្ពុជា : សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ

១.២ កម្ពុជា : ការព្យាករណ៍ការវិនិយោគសម្រាប់ ឆ្នាំ២០០៦-២០១០

១.៣ កម្ពុជា : ការប៉ាន់ស្មានការបែងចែកចំណាយចរន្តនៃថវិកាតាមវិស័យនិងក្រសួងអាទិភាព

១.៤ កម្មវិធីវិនិយោគសាធារណៈ ២០០៦-២០០៨ : តារាងទី ១ : សង្ខេបតាមវិស័យ

១.៥ កម្មវិធីវិនិយោគសាធារណៈ ២០០៧-២០០៩ : តារាងទី ១ : សង្ខេបតាមវិស័យ

១.៦ កម្មវិធីវិនិយោគសាធារណៈ ២០០៨-២០១០ : តារាងទី ១ : សង្ខេបតាមវិស័យ

២ ក្របខ័ណ្ឌតាមដានត្រួតពិនិត្យផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

៣ ពាក្យបំព្រួញ

# ជំពូកទី២

## វឌ្ឍនភាពក្នុងឆ្នាំ២០០៦ និង យុទ្ធសាស្ត្រនិងការរំពឹងទុកនាពេលអនាគត

២.០១ ដូចដែលបានបញ្ជាក់នៅក្នុង*ផយអជ* រាជរដ្ឋាភិបាលកម្ពុជាបានកំណត់អាទិភាពខ្ពស់ និងធ្វើការប្តេជ្ញាចិត្តយ៉ាងមុតមាំ ចំពោះអធិបតេយ្យភាពជាតិ សន្តិភាព ការផ្សះផ្សារជាតិ ស្ថេរភាព សណ្តាប់ធ្នាប់សង្គម លទ្ធិប្រជាធិបតេយ្យ ការការពារសិទ្ធិមនុស្ស និងការអភិវឌ្ឍប្រកបដោយចីរភាព ដែលនឹងជំរុញវឌ្ឍនភាពវិបុលភាព សុខដុមភាព ហើយនឹងលើកកម្ពស់កម្រិតជីវភាព និងសេចក្តីថ្លៃថ្នូរ សម្រាប់គ្រប់ប្រជាជនកម្ពុជា ។ ក្នុងការអនុវត្តយ៉ាងខ្ជាប់ខ្ជួនដើម្បីឱ្យសម្រេចបាននូវគោលដៅទាំងនេះ រាជរដ្ឋាភិបាលកម្ពុជា នឹងប្រកាន់ខ្ជាប់នូវជំហររបស់ខ្លួន ក្នុងការអនុវត្តតាមទិសដៅ គោលការណ៍ យុទ្ធសាស្ត្រ កម្មវិធី និងផែនការ សំខាន់ៗទាំងឡាយដែលបានកំណត់យ៉ាងច្បាស់នៅក្នុង*ផយអជ*[១] (លើកលែងតែមានករណីចាំបាច់) ។

២.០២ ដោយប្រើប្រាស់យុទ្ធសាស្ត្រចតុកោណ ជំពូកនេះ[២] :

- ផ្តោតការយកចិត្តទុកដាក់ និងធ្វើការវិភាគយ៉ាងជិតដល់ ទៅលើគោលនយោបាយ និងទៅលើគ្រប់ការប្រែប្រួលសំខាន់ៗក្នុងឆ្នាំ២០០៦ ក្នុងគ្រប់វិស័យទាំងអស់ រួមទាំង បណ្តាមូលហេតុដែលនាំឱ្យសម្រេចបានជោគជ័យ និងនាំឱ្យមិនសម្រេចបានជោគជ័យ ។
- ផ្តល់នូវតារាងទិន្នន័យប្រៀបធៀប ដូចមាននៅក្នុងជំពូកទី៤ នៃ*ផយអជ* ដែលបង្ហាញពីវឌ្ឍនភាព និងការមិនសម្រេចបានតាមចំណុចដៅ ក្នុងឆ្នាំ២០០៦ ។
- បង្ហាញពីបញ្ហាប្រឈម និងយុទ្ធសាស្ត្រសម្រាប់ដោះស្រាយបញ្ហាប្រឈមទាំងនោះ ។

២.០៣ ជំពូកនេះ បង្ហាញតែពីទិដ្ឋភាពរួមនៃការប្រែប្រួលនិងយុទ្ធសាស្ត្រសំខាន់ៗជាគន្លឹះ ព្រមទាំងពីសកម្មភាពចាំបាច់នានា សម្រាប់ពេលខាងមុខ ។ ជំពូកនេះ ត្រូវបានរៀបចំឡើង ដើម្បីធ្វើជាការណែនាំជាទូទៅ ដោយពុំមានរាយលម្អិតពីការងារនានាដែលកំពុងអនុវត្ត ឬនឹងត្រូវអនុវត្តដោយក្រសួង-ស្ថាប័នទេ ។ បណ្តាសកម្មភាពលម្អិត និងច្បាស់លាស់ជាងនេះ នឹងមានបង្ហាញនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ និងក្នុងរបាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តផែនការទាំងនោះ ។ ប្រការដែលឱ្យគួរគត់សម្គាល់គឺថា ជារួម គោលដៅជាច្រើនដែលនឹងត្រូវសម្រេចឱ្យបាននោះ ត្រូវមានលក្ខណៈជាបរិមាណ ។ ទិដ្ឋភាពដែលមានលក្ខណៈជាគុណភាព ទោះបីជាមានសារៈសំខាន់ក៏ដោយ ជាទូទៅ មានការលំបាកក្នុងការវាស់វែងណាស់ ប៉ុន្តែឆ្លងកាត់រយៈពេលមួយ ទិដ្ឋភាពទាំងនោះ នឹងត្រូវអាចគេស្វែងយល់បាន និងអាចស្តែងចេញឡើងតាមរយៈការប្រែប្រួលទាំងឡាយ ក្នុងរូបភាពជាច្រើន ។

---

[១] កថាខ័ណ្ឌ ៤.០២ នៃ *ផយអជ*

[២] ជំពូកនេះ រួមបញ្ចូលផ្នែកនានាក្នុងជំពូកទី២ និងទី៤ នៃ*ផយអជ*

២.០៤ ភាពក្រីក្រ ៖ ដោយបានកំណត់យ៉ាងច្បាស់ថា ការកាត់បន្ថយនិងការឈានទៅលុបបំបាត់ភាពក្រីក្រឱ្យបានឆាប់រហ័ស ជាចំណុចកណ្តាលនៃការខិតខំប្រឹងប្រែងក្នុងការងារអភិវឌ្ឍន៍ ការផ្តោតការយកចិត្តទុកដាក់នឹងត្រូវបន្តអនុវត្ត ក្នុងការបង្កើតកាលានុវត្តភាពដល់អ្នកក្រីក្រឱ្យបានចូលរួម ក្នុងចំណោមមហាជនដែលត្រូវបានគេទទួលស្គាល់ថាជាអ្នករួមចំណែកនិងអ្នកចូលរួម និងក្នុងការផ្តល់ឱ្យបានច្រើននិងប្រសើរជាងមុននូវ ការថែរក្សាសុខភាព សេវាអប់រំ ការបង្កើនចំណូលតាមរយៈសកម្មភាពនៅតំបន់ជនបទ (ការងារស្រែចំការ និងមិនមែនស្រែចំការ) ការកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទ និងផ្នែកផ្សេងៗទៀត ។ មូលនិធិបន្ថែមទៀត គួរតែត្រូវបានផ្តល់ជូនដល់តំបន់ទាំងនេះ តាមរយៈមូលនិធិអភិវឌ្ឍន៍ឃុំ-សង្កាត់ និងវិធានការផ្សេងៗទៀត ។ ការសម្រេចបានវឌ្ឍនភាពក្នុងការកាត់បន្ថយភាពក្រីក្រ ដែលជាបញ្ហាអន្តរវិស័យមួយ គឺអាស្រ័យទៅលើលក្ខណៈសរុបនៃគោលនយោបាយគាំទ្រអ្នកក្រីក្រ និងកិច្ចខិតខំប្រឹងប្រែងនៅគ្រប់វិស័យផ្សេងទៀត ដូចដែលបានបញ្ជាក់រួចមកហើយនៅក្នុង*ផយអជ*[១] ។

២.០៥ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តផ្តោតការយកចិត្តទុកដាក់លើសកម្មភាពទាំងឡាយ ដែលអាចផ្តល់ផលប្រយោជន៍ដល់កម្រិតមូលដ្ឋានផ្ទាល់ ដែលនៅទីនោះការផ្តោតការយកចិត្តទុកដាក់នេះ នឹងមានប្រយោជន៍ច្រើនបំផុតដល់ប្រជាពលរដ្ឋទូទៅ និងដល់ការកាត់បន្ថយភាពក្រីក្រយ៉ាងឆាប់រហ័ស ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជានឹងព្យាយាមសម្រេចឱ្យបាននូវយុទ្ធសាស្ត្រនិងសកម្មភាពរួមទាំងឡាយ ដែលមានកំណត់នៅក្នុង*ផយអជ*[២] ហើយដែលនឹងមានសារៈសំខាន់ និងជះឥទ្ធិពលចំពោះ គ្រប់ទិដ្ឋភាពទាំងអស់នៃការងាររាជរដ្ឋាភិបាល នៅក្នុងរយៈពេលពីរ-បីឆ្នាំខាងមុខនេះ ។

២.០៦ *យុទ្ធសាស្ត្រចតុកោណ "ដើម្បីជំរុញកំណើន បង្កើតការងារ ធានាសមធម៌ និងប្រសិទ្ធភាព"* បង្ហាញពីក្របខ័ណ្ឌការងារមួយដែលមានគោលបំណងច្បាស់លាស់ ដើម្បីជំរុញប្រទេសកម្ពុជាឆ្ពោះទៅមុខលើមាគ៌ាឆ្ពោះទៅកាន់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ចយ៉ាងឆាប់រហ័ស ។ អភិបាលកិច្ចល្អ គឺជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ ដែលនឹងត្រូវជំរុញនិងអនុវត្ត នៅក្នុងបរិស្ថានព័ទ្ធជុំវិញមួយ ដើម្បីអនុវត្តការងារអភិបាលកិច្ចនេះឱ្យបានជោគជ័យ ហើយដើម្បី ការធ្វើឱ្យសម្រេចបានយ៉ាងឆាប់រហ័សនូវវឌ្ឍនភាពសេដ្ឋកិច្ច-សង្គមកិច្ច នៅក្នុងវិស័យអាទិភាពនានា ដូចដែលដាក់បញ្ចូលនៅក្នុងចតុកោណ "កំណើន" បួនផ្សេងទៀត ។ ក្នុងន័យនេះ យុទ្ធសាស្ត្រចតុកោណ[៣] មានទិដ្ឋភាពចំនួនប្រាំមួយ ។ ផ្នែកដែលនៅសេសសល់នៃជំពូកនេះ ត្រូវបានរៀបចំទៅតាមទម្រង់នៃយុទ្ធសាស្ត្រចតុកោណ ដូចដែលបានរៀបចំនៅក្នុង*ផយអជ* រួចមកហើយដែរ ។

[១] កថាខ័ណ្ឌ ៤.០៤ នៃ*ផយអជ*

[២] កថាខ័ណ្ឌ ៤.០៥ នៃ*ផយអជ*

[៣] សូមមើលរូបភាពក្នុងទំព័រដំបូង

## ស្នូលនៃយុទ្ធសាស្ត្រចតុកោណ : អភិបាលកិច្ចល្អ

២.០៧ អភិបាលកិច្ចសាធារណៈល្អ ដែលស្ថិតនៅចំណុចស្នូលនៃយុទ្ធសាស្ត្រចតុកោណ កំណត់យកការចូលរួមជាសាធារណៈប្រកបដោយសមធម៌និងយុត្តិធម៌ នៅក្នុងបញ្ហាទាំងអស់ តាមរយៈ ការពិគ្រោះយោបល់ របៀបរបបការងារដែលមានលក្ខណៈប្រជាធិបតេយ្យ ដែលធានាថា ឆន្ទៈនិងការជ្រើសរើសរបស់មនុស្សភាគច្រើនត្រូវបានអនុម័តយក និងអនុវត្តស្របពេលជាមួយគ្នា ដោយធានាឱ្យមានការការពារសិទ្ធិនិងសុខុមាលភាពរបស់មនុស្សភាគតិច ។ ស្ថេរភាពនយោបាយ សន្តិសុខនិងសុវត្ថិភាពផ្ទៃក្នុង ការប្រកាន់ខ្ជាប់នូវការគ្រប់គ្រងដោយច្បាប់ និងតម្លាភាព ភាពអាចដឹងមុនបាននិងគណនេយ្យភាពនៃស្ថាប័នសាធារណៈ គឺមានសារៈសំខាន់សម្រាប់ការរីកចម្រើនជាប្រក្រតី នៃផ្នែកសេដ្ឋកិច្ចនិងធនធានមនុស្ស និងដើម្បីការពារផលប្រយោជន៍សាធារណៈ ឱ្យរួចផុតពីការបំផ្លិចបំផ្លាញ ដោយកម្លាំងដែលប៉ងធ្វើការរំខាន ។ នៅក្នុងបរិបទនេះ ប្រការគួរឱ្យកត់សម្គាល់ រួមមាន :

- ជោគជ័យដ៏ចំបងមួយជំហានទៀតនៅក្នុងការលើកកម្ពស់ស្ថេរភាពក្នុងអភិបាលកិច្ច តាមរយៈការធ្វើវិសោធនកម្មដ៏សំខាន់លើរដ្ឋធម្មនុញ្ញ ដែលធ្វើឱ្យការងារនីតិប្បញ្ញត្តិអាចប្រព្រឹត្តទៅបាន តាមរយៈការអនុម័តច្បាប់ដោយសម្លេងភាគច្រើនដាច់ខាត ជំនួសឱ្យតម្រូវការសម្លេង២/៣ដែល ជាឧបសគ្គដ៏ធំមួយ នៅក្នុងពេលនោះ ។ ការងារនេះ បានត្រួសត្រាយផ្លូវសម្រាប់ការអនុម័តដ៏ឆាប់រហ័សលើការងារនីតិប្បញ្ញត្តិនិងលើការបង្កើតរដ្ឋាភិបាលបន្ទាប់ពីការបោះឆ្នោត ដែលធ្លាប់បានជាប់ជាចំណាប់ខ្នាំង នៃបញ្ញត្តិច្បាប់ពីមុននៅក្នុងការបោះឆ្នោតកន្លងមក ។
- ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់លើកទី២ សម្រាប់ឃុំ-សង្កាត់ ១.៦២១ នៅទូទាំងប្រទេស ដែលមានប្រជាជនមានសិទ្ធិបោះឆ្នោតប្រមាណ ៦៨ភាគរយបានចូលរួម បានប្រព្រឹត្តិទៅនៅដើមខែមេសាឆ្នាំ២០០៧ ប្រកបដោយសន្តិវិធី មានសេរីភាពនិងយុត្តិធម៌ ហើយបានបង្ហាញជាថ្មីម្តងទៀតថា លទ្ធិប្រជាធិបតេយ្យនៅកម្ពុជាត្រូវបានជំរុញនិងធ្វើឱ្យប្រសើរឡើងដោយប្រជាជនកម្ពុជា និងបានចាក់ឫសយ៉ាងរឹងមាំនៅក្នុងប្រទេស ព្រមទាំងក្លាយជាផ្នែកមួយនៃរចនាសម្ព័ន្ធសង្គម និងនយោបាយ ។

២.០៨ ដើម្បីជំរុញ ធានាឱ្យមាន និងទ្រទ្រង់អភិបាលកិច្ចល្អ ដែលជាបុរេលក្ខខណ្ឌដ៏សំខាន់បំផុតសម្រាប់ការធ្វើឱ្យសម្រេចបានការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ចប្រកបដោយចីរភាព ដោយមានសមធម៌ កាលានុវត្តភាពស្មើភាពគ្នា និងយុត្តិធម៌សង្គម កំណែទម្រង់ទាំងបួននៃអភិបាលកិច្ច *(ក) ការប្រឆាំងនឹងអំពើពុករលួយ (ខ) កំណែទម្រង់ច្បាប់និងតុលាការ (គ) កំណែទម្រង់រដ្ឋបាលសាធារណៈ រួមទាំង វិមជ្ឈការនិងវិសហមជ្ឈការ និង (ឃ) កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ជាពិសេស ការរំសាយកងទ័ព* នៅតែបន្តជាស្នូលនៃកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា និងនៃកិច្ចខិតខំប្រឹងប្រែងរបស់សង្គមជាតិ ក្នុងការកាត់បន្ថយកម្រិតភាពក្រីក្រនៅក្នុងចំណោមប្រជាជនកម្ពុជា ។ ការអភិវឌ្ឍសំខាន់ៗ ក្នុងឆ្នាំ២០០៦ រួមមាន :

- ទន្ទឹមនឹងពេលដែលការរៀបចំច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយកំពុងដំណើរការ ដោយឆ្លងកាត់ការពិនិត្យពិភាក្សាយ៉ាងហ្មត់ចត់ជាច្រើនដំណាក់កាល ក្របខ័ណ្ឌច្បាប់និងយន្តការស្ថាប័នដែលមានស្រាប់ កំពុងត្រូវបានដាក់ឱ្យប្រើប្រាស់ ដើម្បីកាត់បន្ថយនិងទប់ស្កាត់អំពើពុករលួយដែរ ។ យុទ្ធសាស្ត្រប្រឆាំងនឹងអំពើពុករលួយរបស់រាជរដ្ឋាភិបាលកម្ពុជា ផ្អែកលើគោលការណ៍សំខាន់ៗមួយចំនួនគឺ ការអប់រំបង្ការទប់ស្កាត់ ការជំរុញការអនុវត្តច្បាប់ និងការជំរុញការចូលរួមគាំទ្រយ៉ាងសកម្មពីមហាជន ។ ក្នុងន័យនេះ ការកែសម្រួលរចនាសម្ព័ន្ធអង្គភាពប្រឆាំងនឹងអំពើពុករលួយ ត្រូវបានរៀបចំឡើងតាមរយៈ អនុក្រឹត្យស្តីពីការប្រឆាំងនឹងអំពើពុករលួយ ដែលត្រូវបានចុះហត្ថលេខាកាលពីថ្ងៃទី២២ ខែ សីហា ឆ្នាំ២០០៦ ។ ការិយាល័យទទួលពាក្យបណ្តឹង ត្រូវបានបង្កើតឡើងនៅទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងគោលបំណងបង្កើនការចូលរួមផ្តល់និងទទួលពត៌មានពាក់ព័ន្ធនឹងអំពើពុករលួយពីសំណាក់មហាជន ។ លើសពីនេះទៀត ការដាក់ពិន័យនិងទណ្ឌកម្ម ត្រូវបានធ្វើឡើងចំពោះមន្ត្រីរាជការស៊ីវិល មន្ត្រីគយ នាយនគរបាលជាតិ និងអ្នកដែលមានចំណែកពាក់ព័ន្ធនឹងការនាំចូលរថយន្តចង្កូតស្តាំខុសច្បាប់ ។ ទោះជាដូចនេះក្តី ការប្រឆាំងនឹងអំពើពុករលួយ គឺជាការងារលំបាកនិងមានបញ្ហាប្រឈមច្រើន ដែលទាមទារពេលវេលាយូរអង្វែង និងមធ្យោបាយគ្រប់គ្រាន់ ក្នុងនោះរួមមាន ក្របខ័ណ្ឌស្ថាប័ន ធនធានមនុស្សនិងធនធានហិរញ្ញវត្ថុ សមស្រប ។
- ផែនការសកម្មភាព (ខែមេសា ឆ្នាំ២០០៥) សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងតុលាការ (ខែមិថុនា ឆ្នាំ២០០៣) ត្រូវបានអនុវត្ត ដោយផ្តោតលើទិសដៅនិងសកម្មភាពជាយុទ្ធសាស្ត្រទាំងប្រាំពីរ ដែលបានកំណត់នៅក្នុង*ផយអជ* ។ ជាលទ្ធផល ច្បាប់ស្តីពីក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបានប្រកាសឱ្យប្រើប្រាស់កាលពីថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦ ។ ក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវបានបញ្ជូនទៅសភាដើម្បីសុំការអនុម័ត ។ ក្រមរដ្ឋប្បវេណីត្រូវបានគណៈរដ្ឋមន្ត្រីអនុម័តរួចហើយ ហើយក្រមព្រហ្មទណ្ឌ ត្រូវបានយកទៅពិភាក្សានៅក្នុងកិច្ចប្រជុំអន្តរក្រសួងមួយរួចហើយដែរ ។ សេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តិដទៃទៀតស្តីពីនីតិវិធីច្បាប់និងតុលាការ ព្រមទាំងសេចក្តីព្រាងច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ និងសេចក្តីព្រាងច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងអំពើភេរវកម្ម ក៏ត្រូវបានរៀបចំបង្កើតឡើងផងដែរ ។ ដោយឡែក តុលាការគំរូខេត្តកណ្តាលបានសាងសង់រួចហើយ ហើយគម្រោងការលើកកម្ពស់ការយល់ដឹងពីសិទ្ធិមូលដ្ឋាន ការធ្វើឱ្យប្រសើរឡើងនូវចីរភាពក្នុងការបោះពុម្ពផ្សាយនិងចែកចាយរាជកិច្ច ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ កំពុងត្រូវបានអនុវត្តយ៉ាងសកម្ម ។ ការអភិវឌ្ឍសមត្ថភាពដល់ចៅក្រម និងការពង្រឹងការអនុវត្តច្បាប់នៅតាមសាលាជំនុំជម្រះក្តីត្រូវ បានយកចិត្តទុកដាក់ខ្ពស់ ។ វិធានការដាក់ពិន័យ និងទណ្ឌកម្មយ៉ាងតឹងតែងនិងទាន់ពេលវេលា ត្រូវបានធ្វើឡើង ចំពោះអ្នកប្រព្រឹត្តបទល្មើសច្បាប់ក្នុង

ប្រព័ន្ធតុលាការ ហើយក្រមសីលធម៌សម្រាប់ចៅក្រម ត្រូវបានរៀបចំដាក់ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីអនុម័តរួចហើយ ។

- ក្នុងឆ្នាំ២០០៦ បៀវត្សរ៍មធ្យមប្រចាំខែរបស់មន្ត្រីរាជការស៊ីវិល បានកើនឡើងដល់ ៤៥ដុល្លារអាមេរិក (គិតទាំងការបង្កើនបៀវត្សរ៍១៥ភាគរយ ដែលបានគ្រោងទុកក្នុងផែនការ)។ បន្ថែមលើនេះទៀត ប្រាក់លាភការសម្រាប់មន្ត្រីរាជការស៊ីវិល ដែលឧស្សាហ៍ព្យាយាមនិងសកម្មក្នុងការងារ ត្រូវបានចាប់ផ្តើមអនុវត្ត តាមរយៈកន្សោមអាទិភាព និងប្រាក់ឧបត្ថម្ភតាមគុណសម្បត្តិក្នុងការងារ ។ ចំនួនមន្ត្រីរាជការស៊ីវិលសរុប ត្រូវបានរក្សាឱ្យមានស្ថេរភាពចាប់តាំងពីឆ្នាំ២០០២មក (១៦៥.០០០នាក់ ក្នុងឆ្នាំ២០០២ ដល់ ១៦៧.០០០នាក់ ក្នុងឆ្នាំ២០០៦ ដោយមិនរាប់បញ្ចូល បុគ្គលិកអណ្តែត) ។ ការបង្កើនតំណាងស្ត្រីនៅក្នុងសេវាសាធារណៈ នៅតែបន្តជាបញ្ហាចោទ ដោយសព្វថ្ងៃនេះ ស្ត្រីមានប្រមាណតែ ៣១ភាគរយប៉ុណ្ណោះ នៅក្នុងសេវាសាធារណៈ ។
- កម្មវិធីការងារដែលបានរៀបចំឡើងយ៉ាងល្អ សម្រាប់វិមជ្ឈការនិងវិសហមជ្ឈការ ត្រូវបានដាក់ឱ្យដំណើរការទៅមុខទៅតាមផែនការ ។ គ្រប់ការងារទាំងអស់ដែលទាក់ទងនឹងវិមជ្ឈការនិងវិសហមជ្ឈការ ត្រូវបានដាក់ឱ្យនៅក្រោមតួនាទីរួមក្នុងការដឹកនាំចាត់ចែងនិងសម្របសម្រួលរបស់ក្រសួងមហាផ្ទៃ ដែលបានចាប់ផ្តើមផងដែរនូវការទទួលខុសត្រូវក្នុងការបន្តអនុវត្តកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ក្រោយពេលដែលកម្មវិធីសីលារបស់រាជរដ្ឋាភិបាល ត្រូវបានបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០០៦ ។ គណៈកម្មាធិការជាតិមួយដែលដឹកនាំដោយក្រសួងមហាផ្ទៃ (*គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ - គជវវ*) ត្រូវបានរៀបចំឡើង ដោយព្រះរាជក្រឹត្យលេខ ០៨០៦/៣៩៥ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៦ ។ ទន្ទឹមនឹងនេះ ដើម្បីធ្វើឱ្យប្រសើរឡើងនូវតួនាទីរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ លិខិតបទដ្ឋានគតិយុត្តិមួយចំនួន ត្រូវបានរៀបចំឡើង ដូចជាសេចក្តីណែនាំស្តីពីនីតិវិធីនៃការជ្រើសរើសមេភូមិ និងសេចក្តីណែនាំស្តីពីការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ជាដើម ។
- នៅក្នុងអាណត្តិទី១របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ រាជរដ្ឋាភិបាលបានបែងចែកធនធានពីថវិការជូនទៅឱ្យមូលនិធិឃុំ-សង្កាត់ ដែលមានសមាមាត្រចំនួន ១,៥ភាគរយនៅឆ្នាំ២០០២ ២ភាគរយនៅឆ្នាំ ២០០៣ ២,៥ភាគរយនៅឆ្នាំ២០០៤ ២,៥២ភាគរយនៅឆ្នាំ២០០៥ និង២,៥៤ភាគរយនៅឆ្នាំ ២០០៦ នៃចំណូលចរន្តរបស់ថវិកាជាតិ (គិតជាទឹកប្រាក់សរុប មានប្រមាណ ២៨៤,០៧៥ ពាន់លានរៀល) និងបានកៀរគធនធានក្រៅប្រទេស (ទាំងជំនួយឥតសំណង និងកញ្ចី ដែលបានពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស) បានប្រមាណជាង ២០០លានដុល្លារ សម្រាប់គាំទ្រដល់ការអនុវត្តគម្រោងនិងកម្មវិធីទាំងឡាយ ដែលទាក់ទងនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅឃុំ-សង្កាត់ទូទាំងប្រទេស ។

- នៅត្រឹមចុងឆ្នាំ២០០៦នេះ សេចក្តីព្រាងច្បាប់រៀបចំអង្គការដែលមានចំនួនសរុប ៤ភាគ ត្រូវបានរៀបចំ ៣ភាគរួចហើយ ។ សេចក្តីព្រាងច្បាប់ទាំងបីភាគនោះ កំពុងត្រូវបានពិនិត្យពិចារណាដោយរាជរដ្ឋាភិបាល និងកំពុងត្រូវបានកែលម្អនូវចំណុចមួយចំនួន ដើម្បីដាក់ជូនក្រុមពិគ្រោះយោបល់ដែលរួមមាន សាធារណៈជន សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍នានា ធ្វើការពិភាក្សា និងសុំការសម្រេចពីគណៈរដ្ឋមន្ត្រី មុននឹងបញ្ជូនទៅស្ថាប័នរដ្ឋសភាធ្វើការ អនុម័តដាក់ឱ្យប្រើប្រាស់ឱ្យបាននៅក្នុងឆ្នាំ២០០៧នេះ ។
- កំណែទម្រង់ និងការពង្រឹងសមត្ថភាពកងកម្លាំងប្រដាប់អាវុធ ក្នុងនេះគិតទាំង ការកាត់រំសាយកងទ័ព និងការបង្កើតឡើងជាបណ្តើរៗ នូវកងកម្លាំងប្រដាប់អាវុធមួយដែលមានប្រសិទ្ធភាពជាងមុន ត្រូវបានបន្តធ្វើទៅតាមផែនការដែលបានគ្រោងទុក ។ សមាមាត្រនៃចំណាយការពារជាតិ និងសន្តិសុខនៅក្នុង*ផសស* ត្រូវបានរក្សាឱ្យមានស្ថេរភាពនៅជុំវិញ ២ភាគរយ (១,៨ភាគរយ ក្នុងឆ្នាំ២០០៥និង២០០៦) ហើយនឹងត្រូវបានរំពឹងថាស្ថិតនៅក្នុងកម្រិតប្រហែល ១,៧ភាគរយ ត្រឹមឆ្នាំ២០១០ ។ ចំណាយថវិការដ្ឋ សម្រាប់ការការពារជាតិនិងសន្តិសុខ បានថយចុះជាបន្តបន្ទាប់ (២២,៩៣ភាគរយ ក្នុងឆ្នាំ២០០៥ និង ២១,៩១ភាគរយ ក្នុងឆ្នាំ២០០៦) ហើយត្រូវបានរំពឹងថា នឹងមានស្ថេរភាពនៅក្នុងកម្រិត ១៧,៤០ភាគរយ ត្រឹមឆ្នាំ២០១០ ។

### បរិស្ថានសម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ

២.០៩ ទិដ្ឋភាពបួន ដែលនៅព័ទ្ធជុំវិញស្នូលរបស់យុទ្ធសាស្ត្រចតុកោណ គឺ : *(ក) សន្តិភាព ស្ថេរភាពនយោបាយនិងសណ្តាប់ធ្នាប់សង្គម (ខ) សមាហរណកម្មកម្ពុជាទៅក្នុងតំបន់និងក្នុងពិភពលោក (គ) ភាពជាដៃគូក្នុងការអភិវឌ្ឍ និង (ឃ) បរិស្ថានម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ* ។ បន្ថែមលើនេះ បញ្ហាអន្តរវិស័យសំខាន់ៗមួយចំនួន ក៏ត្រូវបានគិតថា ជាផ្នែកនៃបរិស្ថានសម្រាប់វឌ្ឍនភាព ផងដែរ ។

២.១០ សន្តិភាព ស្ថេរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម ជាមូលដ្ឋានគ្រឹះសម្រាប់ទ្រទ្រង់ដល់ការធ្វើឱ្យមានវឌ្ឍនភាពប្រកបដោយចីរភាព ។ បន្ថែមពីលើការកែប្រែរដ្ឋធម្មនុញ្ញ ដែលបានលើកឡើងក្នុងកថាខ័ណ្ឌ ២.០៧ ខាងលើ ការផ្សះផ្សារជាតិដ៏មានតម្លៃក្រោយពីវិបត្តិ លទ្ធិប្រជាធិបតេយ្យ សណ្តាប់ធ្នាប់សង្គម និងការកាត់បន្ថយឧក្រិដ្ឋកម្ម ដែលសម្រេចបានក្នុងពេលកន្លងមក តាមរយៈការពិភាក្សា និងការសម្រួលគ្នាទៅវិញទៅមក ត្រូវបានលើកកម្ពស់ ។ សុវត្ថិភាពនិងសន្តិសុខនៅទូទាំងប្រទេស ត្រូវបានពង្រឹង ហើយកិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើង ដើម្បីធានាថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់លើកទី២ នៅឆ្នាំ២០០៧ នឹងត្រូវបានធ្វើឡើងដោយសន្តិវិធី ដោយមានការចូលរួមពីគ្រប់ស្រទាប់ប្រជាជន ដោយសេរីនិងយុត្តិធម៌ ។

២.១១ សមាហរណកម្មកម្ពុជាទៅក្នុងសហគមន៍តំបន់និងពិភពលោក : នៅកម្រិតតំបន់និងអនុតំបន់ ក្រៅពីការចូលរួមនៅក្នុងអាស៊ាន កម្ពុជាក៏បានចូលរួមយ៉ាងសកម្មនៅក្នុងគំនិតផ្តួចផ្តើមនិងក្របខ័ណ្ឌនៃសហប្រតិបត្តិការជាច្រើនទៀត ដូចជា *កិច្ចប្រជុំអាស៊ី-អឺរ៉ុប ការសន្ទនាស្តីពីសហប្រតិបត្តិការអាស៊ី មហាអនុតំបន់ទន្លេមេគង្គ យុទ្ធសាស្ត្រសហប្រតិបត្តិការសេដ្ឋកិច្ចអាយេយ៉ាវ៉ាឌី-ចៅប្រាយ៉ា-មេគង្គ កិច្ចសហប្រតិបត្តិការកម្ពុជា-ឡាវ-មីយ៉ាន់ម៉ា-វៀតណាម* និង*កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម* ជាដើម ។ កម្ពុជាបានផ្តល់សារៈសំខាន់ដូចគ្នាដែរ ទៅលើការចូលរួមនិងធ្វើសហប្រតិបត្តិការឱ្យបានសកម្ម នៅក្នុងអង្គការអន្តរជាតិសំខាន់ៗ ។ ការបញ្ចូលប្រទេសកម្ពុជា ជាសមាជិកពាណិជ្ជកម្មពិភពលោក គឺជាសក្ខីភាពបង្ហាញថា កម្ពុជាបានត្រៀមរួចជាស្រេចហើយ ដើម្បីចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចពិភពលោក ។ ការចូលរួមរបស់កម្ពុជាក្នុងកិច្ចការតំបន់និងអន្តរជាតិ មិនត្រឹមតែបានជួយលើកកម្ពស់កិត្យានុភាពនយោបាយ និងសេដ្ឋកិច្ចរបស់កម្ពុជាប៉ុណ្ណោះទេ ថែមទាំងបានផ្តល់វិភាគទានយ៉ាងធំដល់ការថែរក្សាសុវត្ថិភាព សន្តិសុខ និងសន្តិភាព នៅក្នុងតំបន់ ក៏ដូចជា នៅទូទាំងពិភពលោក ។ គោលដៅចម្បងនៃកិច្ចខិតខំប្រឹងប្រែងទាំងនេះ គឺដើម្បីទាញយកផលប្រយោជន៍ឱ្យបានច្រើនជាអតិបរិមា ពីការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់និងពិភពលោក សំដៅធ្វើឱ្យសម្រេចបានគោលដៅនិងយុទ្ធសាស្ត្រជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់បន្ថយភាពក្រីក្រ ឱ្យបានឆាប់រហ័ស នៅកម្ពុជា ។ កិច្ចខិតខំប្រឹងប្រែងជាច្រើនបន្ថែមទៀត ត្រូវតែបានធ្វើឡើង ដើម្បីពង្រីកនិងពង្រឹង និងដើម្បីទាញយកអត្ថ-ប្រយោជន៍ ពីដំណើរការនៃការធ្វើសមាហរណកម្ម ។

២.១២ ភាពជាដៃគូក្នុងការអភិវឌ្ឍ : ទិដ្ឋភាពជាមូលដ្ឋានបីនៃភាពជាដៃគូ រវាងរាជរដ្ឋាភិបាលកម្ពុជា និងអ្នកដែលមានចំណែកពាក់ព័ន្ធផ្សេងទៀត គឺការធ្វើទំនាក់ទំនងជាមួយនឹង : *(១) សង្គមស៊ីវិល (២) ផ្នែកឯកជន* និង *(៣) ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស* ។ ក្នុងន័យនេះ :

- កិច្ចខិតខំប្រឹងប្រែងទាំងអស់ កំពុងត្រូវបានធ្វើឡើង ដើម្បីធ្វើឱ្យគ្រប់ផ្នែកទាំងអស់នៃសង្គមស៊ីវិលបានជាប់ពាក់ព័ន្ធនិងចូលរួមក្នុងគ្រប់ទិដ្ឋភាពសមស្រប នៃដំណើរការការងារផែនការ និងការធ្វើសេចក្តីសម្រេចចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយដើម្បីធ្វើឱ្យសង្គមស៊ីវិលក្លាយជាដៃគូមួយដ៏មានប្រសិទ្ធភាពក្នុងកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍ប្រទេសជាតិ ។ អង្គការក្រៅរដ្ឋាភិបាលជាច្រើន ទាំងក្នុងស្រុក ទាំងអន្តរជាតិ បានរួមចំណែកពាក់ព័ន្ធនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច ក៏ដូចជានៅក្នុងការជំរុញលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស ។ អង្គការក្រៅរដ្ឋាភិបាលជាច្រើន មានតំណាងរបស់ខ្លួនចូលរួមនៅក្នុង គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូសហប្រតិ-បត្តិការអភិវឌ្ឍន៍ និងក្នុងក្រុមការងារបច្ចេកទេស ហើយក៏មានការពាក់ព័ន្ធនៅក្នុងកិច្ចប្រជុំទាំងឡាយនៃវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា នាពេលអនាគត ។ ច្បាប់ស្តីពីអង្គការក្រៅរដ្ឋាភិបាល នឹងត្រូវបានរៀបចំឡើងនៅពេលឆាប់ៗនេះ ដោយមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយ ជាមួយនឹងគ្រប់ស្ថាប័ននិងអង្គការដែលមានចំណែកពាក់ព័ន្ធទាំងអស់ ។

- តួនាទីដ៏សំខាន់របស់ផ្នែកឯកជន ដែលជាកម្លាំងចលករ សម្រាប់ការវិនិយោគនិងកំណើនសេដ្ឋកិច្ច មិនអាចមិនត្រូវបានផ្តោតការយកចិត្តទុកដាក់លើនោះឡើយ ។ ដោយផ្តល់អាទិភាពខ្ពស់ចំពោះការសម្រួលដល់ប្រតិបត្តិការរបស់ផ្នែកឯកជន យន្តការជាច្រើនត្រូវបានដាក់ឱ្យអនុវត្ត ហើយកិច្ចខិតខំប្រឹងប្រែងជាច្រើន នឹងត្រូវបានបន្តធ្វើ ដើម្បីពង្រឹងនិងពង្រីកនូវទំនាក់ទំនងប្រកបដោយភាពសុខដុមជាមួយនឹងផ្នែកឯកជន ដោយផ្អែកលើការប្រកាន់ខ្ជាប់នូវការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តិនានា និងដោយផ្តោតការយកចិត្តទុកដាក់លើអាទិភាពនៃការអភិវឌ្ឍ ។

២.១៣ ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស : រាជរដ្ឋាភិបាលកម្ពុជា ទទួលស្គាល់ដោយក្តីដឹងគុណថា ចំនួនដ៏ច្រើននៃជំនួយដ៏សប្បុរសផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេស ដែលកម្ពុជាទទួលបានពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស តាំងពីឆ្នាំ១៩៩៣មក បានជួយយ៉ាងច្រើននៅក្នុងជំរុញឱ្យមានវឌ្ឍនភាពដ៏ធំធេងនៅកម្ពុជា ។ ប្រការនេះបញ្ជាក់ឱ្យឃើញច្បាស់ថា ក្នុងនាមជាប្រទេសអភិវឌ្ឍន៍តិចតួចមួយ កម្ពុជានៅតែបន្តត្រូវការជំនួយបែបនេះ សម្រាប់មួយរយៈពេលទៀតនាពេលអនាគត ដើម្បីធ្វើដំណើរឆ្ពោះទៅសម្រេចចក្ខុវិស័យរយៈពេលវែងរបស់ខ្លួន ។ ក្នុងឆ្នាំ ២០០៦ នេះ ការអភិវឌ្ឍសំខាន់ៗ រួមមាន :

- ការអនុម័តយកក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដើម្បីគ្រប់គ្រងគ្រប់កិច្ចខិតខំប្រឹងប្រែង នៅក្នុងភាពជាដៃគូរវាងរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។
- ការពង្រឹងនិងការធ្វើសុខដុមនីយកម្មយន្តការទាំងឡាយរបស់*ក្រុមការងារបច្ចេកទេស និងគណៈ-កម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍* តាមរយៈការពិនិត្យមើលឡើងវិញយ៉ាងយកចិត្តទុកដាក់ ដោយមានការពិគ្រោះយោបល់ជាមួយនឹងអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ ។
- ការសម្រេចចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីចាប់ផ្តើមយកភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំពេញលេញ នៅក្នុងកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំសម្រាប់ការកៀរគរជំនួយ ដោយធ្វើការផ្លាស់ប្តូរដំណើរការនៃ *កិច្ចប្រជុំរបស់ក្រុមការងារពិគ្រោះយោបល់* ទៅជា *វេទិកាសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍកម្ពុជា* ពីឆ្នាំ២០០៧ តទៅ ។
- ការរៀបចំដំណើរការនៃការប្រមូលទិន្នន័យ ស្តីពីការរួមចំណែករបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ឱ្យទាន់ពេលវេលា ដើម្បីបញ្ចូលគ្នាជាមួយនឹង ការវិភាគការងារសម្រាប់ការរៀបចំរបាយការណ៍វឌ្ឍនភាពស្តីការអនុវត្ត*ផយអជ កវស ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម* និង*ថវិកាប្រចាំឆ្នាំ* ។

២.១៤ បរិស្ថានម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ : ទិន្នន័យម៉ាក្រូសេដ្ឋកិច្ចដែលបានសន្មតយក សម្រាប់ឆ្នាំ២០០៥ ដែលជាឆ្នាំគោលនៃ*ផយអជ ២០០៦-២០១០* មានការប្រែប្រួលជាវិជ្ជមានយ៉ាងខ្លាំង ដោយសារតែមានការប៉ាន់ស្មានច្បាស់លាស់ជាងមុន ត្រូវបានធ្វើឡើង នៅក្រោយពេលដែលការរៀបចំ*ផយអជ* ត្រូវបានបញ្ចប់ ។ កត្តាសំខាន់ៗ នៅក្នុងចំណោមកត្តាដែលគួរកត់សម្គាល់បំផុត រួមមាន :

- *ផសស* បានកើនឡើង ក្នុងកម្រិតមួយដែលមិនធ្លាប់មានពីមុនមក គឺ១៣,៤ភាគរយ ក្នុងឆ្នាំ២០០៥ ដែលជិតស្មើនឹងពីរដងនៃកម្រិត ៧ភាគរយ ដែលបានប៉ាន់ស្មានក្នុងពេលរៀបចំ *ផយអជ* ទោះបីជាមានភាពមិនអាចដឹងមុនបាន ដែលបង្កឡើងដោយកត្តាក្រៅប្រទេស ដូចជា ការបន្តនៅមានថ្លៃប្រេងខ្ពស់ ក៏ដោយ ។
- កំណើនខ្ពស់ក្នុងវិស័យកសិកម្ម (ដំណាំ) គឺ ២៨,០ភាគរយ[១] ក្នុងឆ្នាំ២០០៥ ខ្ពស់ជាងការប៉ាន់ស្មាន ៨,០ភាគរយ នៅក្នុង*ផយអជ* ដែលជាបច្ច័យល្អនៃការវិនិយោគក្នុងផ្នែកធារាសាស្ត្រ និងភាពអំណោយផលល្អនៃអាកាសធាតុ ។
- ការឡើងយ៉ាងឆាប់រហ័សក្នុងវិស័យកសិកម្ម បានធ្វើឱ្យកំណើននៅក្នុងវិស័យដទៃដែលផ្ទុយទៅវិញ មានលក្ខណៈថេរ មើលទៅឃើញហាក់ដូចជាមានកម្រិតតិចតួច ឬមិនសូវសំខាន់ ហើយសមាមាត្ររបស់វិស័យកសិកម្ម (ដំណាំ) បានកើនឡើងពី ១៦,៩ភាគរយ[២] បើប្រៀបធៀបនឹងកម្រិត ១៤,២ភាគរយ ដែលបានប៉ាន់ស្មាននៅក្នុង*ផយអជ* ។
- ក្នុងន័យនេះ តួលេខមូលដ្ឋានសម្រាប់ឆ្នាំគោល២០០៥ បានកើនឡើង ។ ដូច្នេះ ចំណុចដៅទាំងឡាយសម្រាប់ដំណាក់កាល*ផយអជ* ក៏បានកើនឡើងផងដែរ ទោះបីជាតួលេខទាំងនោះត្រូវផ្អែកលើតួលេខមូលដ្ឋានដែលត្រូវបានធ្វើការកែសម្រួលរួចហើយក៏ដោយ ។
- *ផសស* សម្រាប់មនុស្សម្នាក់ ស្មើនឹង ១,៨៦លានរៀល គឺខ្ពស់ជាងការប៉ាន់ស្មានក្នុង*ផយអជ* ដែលស្មើនឹង ១,៤០លានរៀលសម្រាប់ឆ្នាំ២០០៥ ហើយត្រូវបានរំពឹងថានឹងកើនឡើងដល់ ២,៨៨៨លានរៀលនៅឆ្នាំ២០១០ (ធៀបនឹងការប៉ាន់ស្មានក្នុង*ផយអជ* ដែលមានតែ ២,២៤៣លានរៀលប៉ុណ្ណោះ) ។
- បើគិតតាមសមាមាត្រនៃវិស័យឧស្សាហកម្មនិងសេវាកម្មទាំងមូល ឧស្សាហកម្មកាត់ដេរនៅតែបន្តធ្វើជាវិស័យមួយនាំមុខគេ ដោយមានវិស័យទេសចរណ៍និងសំណង់ ជាវិស័យឈានមុខបន្ទាប់ ។ រាជរដ្ឋាភិបាលកម្ពុជា រំពឹងទុកជារួមថា កំណើនដ៏ខ្ពស់នេះ នឹងនៅតែមានបន្តទៀត ។
- ហេតុដូចនេះ គ្រប់តួលេខម៉ាក្រូសេដ្ឋកិច្ច ត្រូវបានធ្វើការកែសម្រួលនិងបង្ហាញទាំងស្រុង នៅក្នុងតារាង២.១ ខាងក្រោម និងនៅក្នុងឧបសម្ព័ន្ធ១.២ និង ១.៣ ។

២.១៥ នៅឆ្នាំ២០០៦ កំណើន*ផសស* ត្រូវបានប៉ាន់ស្មានថាមានកម្រិត ១០,៨ភាគរយ បន្ថែមពីលើការកើនឡើងយ៉ាងខ្ពស់ នៅឆ្នាំ២០០៥ ។ អតិផរណា នឹងត្រូវបានរក្សាឱ្យនៅកម្រិត ៤,៧ភាគរយ ។ គោលនយោបាយថវិកាដែលមានលក្ខណៈជឿនលឿន ប្រយ័ត្នប្រយែង និងតឹងតែង សម្រាប់ចំណូលនិងចំណាយ បានបង្កើនចំណូលរបស់រាជរដ្ឋាភិបាលពី ១០,៦ភាគរយនៃ*ផសស* នៅឆ្នាំ២០០៥ ដល់ ១១,៥ភាគរយនៃ*ផសស* នៅឆ្នាំ២០០៦

[១] គណនេយ្យជាតិកម្ពុជា ឆ្នាំ១៩៩៣-២០០៥, ព្រឹត្តិប័ត្រលេខ១០, វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ

[២] គណនេយ្យជាតិកម្ពុជា ឆ្នាំ១៩៩៣-២០០៥, ព្រឹត្តិប័ត្រលេខ១០, វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ

និងបង្កើនចំណាយដល់ ១៣,៦ភាគរយនៃ*ផសស* ពីលើកម្រិត ១៣,៤ភាគរយ នៅឆ្នាំ២០០៥ ។ អត្រាប្ដូរប្រាក់ស្ថិតនៅស្ថេរភាពក្នុងកម្រិតប្រមាណ ៤.១០៣រៀល ក្នុងមួយដុល្លារអាមេរិក ។ ភាពប្រសើរឡើងបន្តិចម្ដងៗក្នុងការគ្រប់គ្រងអចលនៈទ្រព្យរបស់រដ្ឋ ដោយរាប់បញ្ចូលទាំង ទ្រព្យសម្បត្តិរូបិយនិងអរូបិយ ក៏ដូចជា សហគ្រាសរដ្ឋនិងសហគ្រាសរដ្ឋចម្រុះរដ្ឋនិងឯកជន តាមរបៀបមួយដែលមានតម្លាភាពនិងប្រសិទ្ធភាព ដើម្បីការពារផលប្រយោជន៍របស់រដ្ឋ និងដើម្បីបង្កើនចំណូលប្រកបដោយស្ថេរភាព ។ វិធានការនានា ត្រូវបានដាក់ឱ្យអនុវត្តដើម្បីឱ្យមានការគ្រប់គ្រងយ៉ាងតឹងតែងតាមនីតិវិធីច្បាប់ សំដៅអនុវត្តតាមនូវនីតិវិធីដេញថ្លៃជាសាធារណៈ ដែលមានភាពច្បាស់លាស់និងមានតម្លាភាព នៅក្នុងការលក់ឬជួលកម្មសិទ្ធិរដ្ឋឬសិទ្ធិរបស់រដ្ឋ ហើយជាការពិតណាស់ គឺនៅក្នុងរាល់ការផ្ដល់កិច្ចសន្យារបស់រដ្ឋ ។ ឆ្នាំ២០០៦ ត្រូវបានចាត់ទុកថា ជាឆ្នាំមីក្រូហិរញ្ញវត្ថុ ហើយសន្និបាតនិងសិក្ខាសាលាជាច្រើន ត្រូវបានរៀបចំឡើងក្នុងគោលបំណង ជំរុញឱ្យមានការយល់ដឹងប្រសើរជាងមុនអំពី និងការលើកកម្ពស់ប្រសិទ្ធភាពរបស់ ស្ថាប័នមីក្រូហិរញ្ញវត្ថុ ព្រមទាំងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីវិស័យនេះ ។

### តារាង ២.១ : ទិន្នន័យម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ[១]

(ភាគរយនៃ*ផសស* លើកលែងតែបានការបញ្ជាក់ផ្សេងទៀត)

| សូចនាករ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ |
|---|---|---|---|---|---|---|
| *ផសស* គិតតាមថ្លៃថេរ (% ប្រែប្រួល) | ១៣,៤ | ១០,៨ | ៧,៣ | ៦,៦ | ៦,៨ | ៧,០ |
| អតិផរណា (មធ្យមប្រចាំឆ្នាំ - %ប្រែប្រួល) | ៥,៨ | ៤,៧ | ៣,០ | ៣,០ | ៣,០ | ៣,០ |
| ចំណូល | ១០,៦ | ១១,៥ | ១០,៧ | ១១,០ | ១១,៣ | ១១,៦ |
| -- ចំណូលពន្ធ | ៧,៨ | ៨,១ | ៨,៣ | ៨,៦ | ៨,៨ | ៩,០ |
| ចំណាយ | ១៣,៣ | ១៤,២ | ១៤,៤ | ១៤,៦ | ១៤,៧ | ១៤,៩ |
| -- ចរន្ត | ៧,៧ | ៨,០ | ៨,៦ | ៨,៩ | ៩,២ | ៩,៥ |
| ការវិនិយោគផ្ទាល់ពីបរទេស (លានដុល្លារ) | ៣៧៥ | ៤៧៥ | ៥៣០ | ៥៧៣ | ៦១៣ | ៦២០ |

*ប្រភព : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

២.១៦ គោលដៅរយៈពេលវែងនឹងបន្តនៅតែជា ការត្រូវធ្វើឱ្យសម្រេចបាននូវកំណើនសេដ្ឋកិច្ច ដែលមានមូលដ្ឋានទូលំទូលាយចម្រុះច្រើនយ៉ាងនិងមានលក្ខណៈទ្រទ្រង់អ្នកក្រីក្រ ។ ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចដែលសម្រេចបានកន្លងមកបានដើរតួនាទីយ៉ាងសំខាន់មួយ នៅក្នុងការបង្កើតឱ្យមានមូលដ្ឋានគ្រឹះ សម្រាប់កំណើនយ៉ាងខ្លាំងដែលសម្រេចបាននៅកម្ពុជាក្នុងពេលពីរ-បីឆ្នាំកន្លងទៅនេះ និងជាលទ្ធផលគឺសម្រាប់ការកាត់បន្ថយភាពក្រីក្រ ហើយនឹងត្រូវថែរក្សាឱ្យមានជាបន្ត ព្រមទាំងត្រូវពង្រឹងបន្ថែមទៀតនៅក្នុងពេលអនាគត ។ ជាមួយនឹងជំនឿទុកចិត្តនិងបទពិសោធន៍ដែលទទួលបានពីការគ្រប់គ្រងដោយជោគជ័យលើសភាពការណ៍សេដ្ឋកិច្ច សូម្បីតែក្នុងអំឡុងពេលដែលទទួលរងសម្ពាធពីកត្តាសេដ្ឋកិច្ចខាងក្រៅប្រទេស ដូចជា វិបត្តិសេដ្ឋកិច្ចនៅអាស៊ីខាងកើតឆ្នាំ១៩៩៧ ការផ្លាស់ប្ដូរទ្រង់ទ្រាយ

[១] តារាងលម្អិត មាននៅក្នុងឧបសម្ព័ន្ធ ១.១ និង ១.២

ធំផ្នែករចនាសម្ព័ន្ធនិងវិស័យក្រៅប្រទេសដែលបានកើតមានឡើងចាប់តាំងពីពេលនោះមក និងតម្លៃប្រេងខ្ពស់ក្នុងអំឡុងឆ្នាំ២០០៤និង២០០៥ រាល់ការរំពឹងទុកដែលការធ្វើចំណោលម៉ាក្រូសេដ្ឋកិច្ចបានបង្ហាញខាងលើ នឹងអាចសម្រេចបានពេញលេញ ហើយគុណប្រយោជន៍ដែលទទួលបាន នឹងជះឥទ្ធិពលយ៉ាងទូលំទូលាយដល់ការកាត់បន្ថយភាពក្រីក្រ ។ ក្នុងចំណោមវិធានការសំខាន់ផ្សេងៗទៀត ការងារទាំងឡាយដែលត្រូវអនុវត្ត រួមមាន ដូចខាងក្រោម :

- វឌ្ឍនភាពបន្ថែមទៀត នៅក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលប្រឹងប្រែងបង្កើតឡើងនិងធានាឱ្យមានស្តង់ដារកម្រិតខ្ពស់ជាងមុននៃ ការងារគ្រប់គ្រងនិងគណនេយ្យភាពក្នុងការកៀរគរគ្រប់ធនធានចរន្តនិងមូលធនរបស់រដ្ឋាភិបាល ព្រមទាំងប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធានទាំងនោះក្នុងការអនុវត្ត *ផយអជ* និងកម្មវិធីអាទិភាពផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ។ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ត្រូវបានរំពឹងទុកថា នឹងដាក់ឱ្យដំណើរការសម្រាប់កម្មវិធីដែលមានរយៈពេលច្រើនឆ្នាំ ។
- ថវិកាសម្រាប់កម្មវិធី ត្រូវបានដាក់ឱ្យអនុវត្តរួចហើយសម្រាប់*កម្មវិធីសកម្មភាពជាអាទិភាព* ក្នុងក្រសួងចំនួន៧ (*ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងកិច្ចការនារី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងយុត្តិធម៌*) ដែលនឹងមានផលប៉ះពាល់ទៅលើស្ថានភាពរបស់ភាពក្រីក្រ ។ ការធ្វើវិភាជន៍និងការប្រើប្រាស់ទាន់ពេលវេលា នូវថវិកាក្នុងក្រសួងទាំងនេះ នឹងត្រូវតាមដានត្រួតពិនិត្យយ៉ាងដិតដល់ ដើម្បីធានាឱ្យមានការសម្រេចបាននូវលទ្ធផលដែលបានរំពឹងទុក ធៀបនឹងសូចនាករ សំដៅធ្វើឱ្យប្រសើរឡើងនូវការតម្រង់ទិសផ្តោតទៅរកលទ្ធផល ។
- ការកើនឡើងជាលំដាប់ក្នុងការវិភាជន៍ថវិកា និងការធានាផ្តល់ប្រាក់ចំណាយទាន់ពេលវេលា ដល់វិស័យអាទិភាពដែលជួយទ្រទ្រង់ដល់អ្នកក្រីក្រ ។ ការធ្វើវិភាជន៍ថវិកាដល់វិស័យកសិកម្ម មានចំនួន ០,៧ភាគរយនៃ*ផសស* នៅក្នុងឆ្នាំ២០០៥ បានកើនឡើងដល់ ០,៩១ភាគរយនៃ*ផសស* នៅក្នុងឆ្នាំ២០០៦ ។ សម្រាប់វិស័យអភិវឌ្ឍន៍ជនបទ ការធ្វើវិភាជន៍ថវិកាមានចំនួន ០,១៩ភាគរយនៃ*ផសស* នៅក្នុងឆ្នាំ២០០៥ បានកើនឡើងដល់ ០,២ភាគរយនៃ*ផសស* នៅក្នុងឆ្នាំ២០០៦ ។ សម្រាប់វិស័យសុខាភិបាល ការធ្វើវិភាជន៍នេះមានចំនួន ០,៨៩ភាគរយនៃ*ផសស* នៅក្នុងឆ្នាំ២០០៥ បានកើនឡើងដល់ ០,៩៦ភាគរយនៃ*ផសស* នៅក្នុងឆ្នាំ២០០៦ ។ ចំណែកឯសម្រាប់វិស័យអប់រំ ការធ្វើវិភាជន៍មានចំនួន ១,៣៨ភាគរយនៃ*ផសស* នៅក្នុងឆ្នាំ២០០៥ បានកើនឡើងដល់ ១,៥៦ភាគរយ នៃ *ផសស* នៅឆ្នាំ២០០៦[១] ។

[១] សូមមើលផងដែរក្នុង ឧបសម្ព័ន្ធ ១.៣

- កិច្ចខិតខំប្រឹងប្រែងដោយមានការសម្របសម្រួលល្អរវាងស្ថាប័នពាក់ព័ន្ធ (ធនាគារជាតិនៃកម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) នឹងបន្តធ្វើឱ្យប្រសើរឡើង និងពង្រឹងនូវលទ្ធផលសម្រេចបាន នៅក្នុងវិស័យហិរញ្ញវត្ថុ ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យមានស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងសម្រាប់ល្បឿននិងទិសដៅរបស់កំណើនសេដ្ឋកិច្ច ព្រមទាំងសម្រាប់លើកកំពស់ការកៀរគរធនធានហិរញ្ញវត្ថុអសកម្ម ដើម្បីការវិនិយោគដែលបម្រើឱ្យការងារផលិតកម្ម ។ *ចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ* កំពុងត្រូវបានធ្វើបច្ចុប្បន្នភាព ហើយលើកឡើងពីគម្រោងការអភិវឌ្ឍនូវប្រព័ន្ធហិរញ្ញវត្ថុមួយដែលដំណើរការល្អនិងផ្អែកលើទីផ្សារ នៅក្នុងរយៈពេល៥ឆ្នាំខាងមុខ ដើម្បីលើកកម្ពស់ការកៀរគរធនធាន សម្រាប់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ។
- កំណែទម្រង់វិស័យហិរញ្ញវត្ថុ នឹងផ្តោតការយកចិត្តទុកដាក់ផងដែរទៅលើ ការពង្រឹងការគ្រប់គ្រងដោយប្រុងប្រយ័ត្ន និងក្របខ័ណ្ឌគតិយុត្តិមួយសម្រាប់វិធានការច្បាប់ក្នុងវិស័យហិរញ្ញវត្ថុ ។ វិធានការច្បាប់សំខាន់ៗ រួមមាន ការអនុម័តឱ្យប្រើប្រាស់ *ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់សងប្រាក់* និងសេចក្តីព្រាងច្បាប់ស្តីពី *ប្រតិបត្តិការដោយមានការធានា* ដែលត្រូវបានដាក់ជូនទៅដល់រដ្ឋសភាពិនិត្យនិងអនុម័ត រួចហើយ ។
- កំណែទម្រង់ទាំងឡាយ ដើម្បីបង្កើននិងធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបាននូវមីក្រូហិរញ្ញវត្ថុ ។ វិធានការសំខាន់ៗ រួមមាន ការជម្រុញការផ្តល់អាជ្ញាប័ណ្ណដល់ និងការចុះឈ្មោះរបស់ស្ថាប័នមីក្រូហិរញ្ញវត្ថុ និងការសម្រួលឱ្យមានការទទួលយកនូវ លក្ខខណ្ឌតម្រូវផ្អែកកិច្ចបញ្ជីការគណនេយ្យ និងការធ្វើរបាយការណ៍ដ៏សមស្រប ដោយសហគ្រាសពាក់ព័ន្ធទាំងឡាយ ។ ភាពចាំបាច់ក្នុងការពង្រីកក្របខណ្ឌការងារនេះ ឱ្យទៅជាស្ថាប័នហិរញ្ញវត្ថុក្នុងរូបភាពផ្សេងៗទៀត ដូចជា សហករណ៍សេវាហិរញ្ញវត្ថុ សមាគមឥណទាន និងធនាគារសញ្ជ័យភូមិ កំពុងត្រូវបានធ្វើការសិក្សាស្រាវជ្រាវ ។

២.១៧ ដោយផ្អែកលើបទពិសោធន៍ដែលមានលើពិភពលោកនិងបទពិសោធន៍ផ្ទាល់របស់កម្ពុជា រាជរដ្ឋាភិបាលកម្ពុជាដឹងច្បាស់ថា កំណើនសេដ្ឋកិច្ចខ្ពស់ដូចបានរំពឹងទុកខាងលើ នឹងត្រូវបន្តរុញច្រានដោយ កម្លាំងជំរុញ កាលានុវត្តភាព សម្ពាធ និងការបង្កការលំបាក របស់ទីផ្សារ ។ ស្ថានភាពសេដ្ឋកិច្ចនានាដែលកើតមានកន្លងមក បានបង្ហាញឱ្យឃើញថា កំណើនបណ្តាលឱ្យមានការផ្លាស់ប្តូរជាច្រើន ហើយកំណើនទាមទារឱ្យមានការធ្វើការកែតម្រូវរចនាសម្ព័ន្ធជាបន្តនៅក្នុងប្រជាជននិងសេដ្ឋកិច្ច ។ ចំណេះដឹងជំនាញទាំងឡាយ នឹងត្រូវបង្កើតឡើង ដើម្បីឆ្លើយតបទៅនឹងតម្រូវការទាំងឡាយរបស់ទីផ្សារ ដែលកំពុងលេចឡើងដោយសារកំណើន ហើយជួនកាល តម្រូវការទាំងនោះជំរុញឱ្យមានការប្រែប្រួលនៅក្នុងប្រព័ន្ធអប់រំឧត្តមសិក្សានិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលត្រូវធ្វើការផ្គត់ផ្គង់នូវមុខជំនាញនានា ដើម្បីបម្រើសង្គមជាតិទាំងមូល នៅក្នុងរយៈពេលវែង ។ រហូតមកទល់នឹងពេលនេះ ឧស្សាហកម្មសម្លៀកបំពាក់ ការងារសំណង់ និងទេសចរណ៍ បានក្លាយជាវិស័យជំរុញឱ្យមានកំណើន ។ ទោះបីជាមូលដ្ឋានសម្រាប់កំណើនទាំងនេះ ត្រូវបានទទួលការស្វាគមន៍យ៉ាងខ្លាំង នៅក្នុងការបង្កើតការងារសម្រាប់ប្រជាជនជាច្រើន ក៏ដោយ

ក៏ការពឹងផ្អែកទៅលើតែវិស័យពីរ-បីបែបនេះ នឹងធ្វើឱ្យមានផលវិបាកជាច្រើន ដែលពាក់ព័ន្ធនឹងចីរភាពសេដ្ឋកិច្ច ពេលវែង ។ រាល់ការស្នើឡើងផ្នែកគោលនយោបាយ ត្រូវផ្តោតលើបញ្ហាសំខាន់ៗដូចខាងក្រោម នៅក្នុងចំណោម បញ្ហាសំខាន់ៗផ្សេងទៀត :

- កំណើនត្រូវធ្វើឱ្យមាន ដោយផ្អែកលើមូលដ្ឋានជាច្រើន ទាំងតាមវិស័យ ទាំងតាមលក្ខណៈភូមិសាស្ត្រ ដើម្បីធានាឱ្យមានចីរភាពសម្រាប់រយៈពេលវែង ។
- ក្រុមប្រជាជនដែលមានប្រៀបជាង (គិតតាមទ្រព្យធន កម្រិតអប់រំ ទីតាំងរស់នៅទីប្រជុំជន ។ល។) នឹងមានលទ្ធភាពប្រសើរជាងក្នុងការទទួលបានផលប្រយោជន៍ពីកំណើនសេដ្ឋកិច្ច ។
- កំណើនដ៏លឿន ក៏ជំរុញឱ្យមានផងដែរនូវ ការផ្លាស់ប្តូរទីលំនៅពីជនបទមកទីក្រុង ដើម្បីស្វែងរក ការងារធ្វើនិងមុខរបរបន្ថែម ដែលធ្វើឱ្យមានការថយចុះកម្លាំងពលកម្មសម្រាប់ការងារកសិកម្ម នៅ តំបន់ជនបទ ។
- យុវជននឹងចាកចេញពីប្រជាជនវ័យចំណាស់នៅតំបន់ជនបទនិងតំបន់ដាច់ស្រយាល ដែលធ្វើឱ្យមាន ការធ្លាក់ចុះនូវផលិតភាពកសិកម្ម ។
- ដូចដែលបានស្តែងចេញរួចមកហើយពីចន្លោះឆ្នាំ១៩៩៣ និង ២០០៤ កំណើនសេដ្ឋកិច្ចបានជះឥទ្ធិពល យ៉ាងច្រើនទៅលើកម្រិតនៃការកាត់បន្ថយភាពក្រីក្រនៅក្នុងទូទាំងប្រទេស ប៉ុន្តែ កម្រិតភាពក្រីក្រ នៅតែបន្តមានកម្រិតខ្ពស់នៅតំបន់ដាច់ស្រយាល ។ បញ្ហានេះនឹងនៅតែបន្តមានទៅមុខទៀត និង កាន់តែស្រួចស្រាវជាងមុន ប្រសិនបើ កំណើនសេដ្ឋកិច្ចមិនត្រូវបានគ្រប់គ្រងឱ្យបានសមស្របទេ ។
- ការមើលស្រាលណាមួយចំពោះវិស័យកសិកម្មដែលទ្រទ្រង់ដោយជីវភាពរស់នៅ នឹងមានផលវិបាក យ៉ាងធ្ងន់ធ្ងរ ចំពោះសន្តិសុខស្បៀង និងអាហារូបត្ថម្ភ សម្រាប់ប្រជាជនភាគច្រើន ។
- អតុល្យភាពនិងការខូចទ្រង់ទ្រាយនៃរចនាសម្ព័ន្ធសេដ្ឋកិច្ចទាំងមូល ចាំបាច់ត្រូវតែធ្វើការកែតម្រូវ ដោយធ្វើការតម្រង់ទិសកំណើន ទៅរកតំបន់ដែលមិនបានទទួលការផ្គត់ផ្គង់សេវាកម្មពីមុនមក ។

២.១៨ ដោយមានការយល់ដឹង ពីបញ្ហាដែលបានបង្ហាញខាងលើ និងពីកត្តាផ្សេងៗដែលនាំឱ្យមានការផ្លាស់ប្តូរ ដែលជាលទ្ធផលនៃកំណើនសេដ្ឋកិច្ច រាជរដ្ឋាភិបាលកម្ពុជានឹងបន្តរក្សាការឃ្លាំមើលជាប្រចាំ នៅពេលដែលការ អភិវឌ្ឍកំពុងបន្តកើតមានឡើង ហើយនឹងប្រើប្រាស់ឧបករណ៍និងការលើកទឹកចិត្តផ្នែកគោលនយោបាយ ដ៏មាន ប្រសិទ្ធភាពនិងមានផលប្រយោជន៍ ដើម្បីធ្វើពិពិធកម្មកំណើនតាមវិស័យនិងតាមលក្ខណៈភូមិសាស្ត្រ ព្រមទាំង ផ្តល់បណ្តាញសុវត្ថិភាពសង្គម សំដៅធានាថា ប្រជាជនដែលបានដាក់ឱ្យនៅឆ្ងាយពីឥទ្ធិពលនៃកំណើន នឹងមិនត្រូវ បន្តនៅក្រៅរង្វង់នៃឥទ្ធិពលនេះ និងមិនត្រូវបានដាក់ឱ្យស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះដូចមុនឡើយ ។ យុទ្ធសាស្ត្រ ទាំងឡាយដែលបានលើកឡើងសម្រាប់វិស័យនានា ដូចបានពិពណ៌នានៅក្នុងកថាខ័ណ្ឌបន្តបន្ទាប់ និងក្នុងជំពូកទី៣ នឹងដោះស្រាយបញ្ហាទាំងនេះ ។

២.១៩ <u>បញ្ហាវប្បធម៌និងសាសនា</u> គឺជាមូលដ្ឋានគ្រឹះសម្រាប់ការកសាង ការពង្រឹង និងការថែរក្សា "*មូលធនសង្គម*" ដែលជាកត្តាដ៏សំខាន់បំផុតសម្រាប់ទ្រទ្រង់ដល់វិស័យសេដ្ឋកិច្ច ព្រោះថា គ្មានទំហំណាមួយនៃការអភិវឌ្ឍសេដ្ឋកិច្ចអាចកើតឡើងបាន ឬអាចស្ថិតស្ថេរទៅបានដោយឯកឯងទេ ។ រាជរដ្ឋាភិបាលកម្ពុជា នៅតែបន្តផ្តល់អាទិភាពខ្ពស់ក្នុងការថែរក្សា និងលើកតម្កើងកេរ្តិ៍ដំណែលវប្បធម៌ដ៏ល្អថ្លៃថ្លាតែមួយរបស់ប្រជាជាតិ ដើម្បីអភិរក្សនិងអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធវប្បធម៌ក្នុងសង្គម ព្រមទាំងដើម្បីទាក់ទាញ "*ភ្ញៀវទេសចរណ៍វប្បធម៌*" ឱ្យចូលមកទស្សនាវប្បធម៌ពីអតីតកាល និងនាពេលបច្ចុប្បន្នរបស់កម្ពុជា ។

### ចតុកោណទី១ : ការលើកស្ទួយវិស័យកសិកម្ម

២.២០ មុំទាំងបួនរបស់ចតុកោណនេះ គឺ *(ក) ការលើកកម្ពស់ផលិតភាពនិងពិពិធកម្មវិស័យកសិកម្ម (រួមទាំងអាហារូបត្ថម្ភនិងការអភិវឌ្ឍជនបទ) (ខ) កំណែទម្រង់ដីធ្លីនិងការបោសសម្អាតមីន (គ) កំណែទម្រង់វិស័យនេសាទនិងជលផល* និង *(ឃ) កំណែទម្រង់ព្រៃឈើ (រួមទាំងការការពារបរិស្ថាន)* ។ កិច្ចខិតខំប្រឹងប្រែងជាបន្តរបស់រាជរដ្ឋាភិបាល ក្នុងការទប់ស្កាត់សកម្មភាពអនាធិបតេយ្យទាំងឡាយដែលបង្កការបំផ្លិចបំផ្លាញលើធនធានធម្មជាតិនិងបរិស្ថាន និងក្នុងការស្តារនិងលើកកម្ពស់សក្តានុពលធារាសាស្ត្រ ព្រមទាំងភាពអនុគ្រោះផ្នែកអាកាសធាតុ បានធ្វើឱ្យមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់នៅក្នុងវិស័យនេះ ក្នុងឆ្នាំ២០០៦ ។

២.២១ ក្នុងឆ្នាំ២០០៦ ការកែលម្អប្រព័ន្ធធារាសាស្ត្រ ស្ថានភាពល្អផ្នែកអាកាសធាតុ ការប្រើប្រាស់ពូជល្អជាងមុន និងការកែលម្អវិធីដាំដុះ បានរួមចំណែកដោយផ្ទាល់ ក្នុងការបង្កើនផលិតកម្មដំណាំ និងដោយប្រយោលក្នុងការធានាឱ្យមានសន្តិសុខស្បៀង និងក្នុងការលើកម្ពស់ផលិតភាពនិងពិពិធកម្ម ។ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ជនបទ បានធ្វើឱ្យលទ្ធភាពចូលទៅដល់ទីផ្សាររបស់ផលិតផលកសិកម្ម បានកើនឡើងច្រើនជាងមុន ។ លក្ខខណ្ឌអនុគ្រោះទាំងឡាយដូចបានរៀបរាប់ខាងលើ និងការបង្កើនការអនុវត្តប្រព័ន្ធប្រពលវប្បកម្មស្រូវ និងវិធីសាស្ត្រដាំដុះតាមលក្ខណៈសិរីរាង្គ បានធ្វើឱ្យផលិតផលស្រូវមានការកើនឡើងដល់ ៦,២៦លានតោន ក្នុងរដូវបង្កបង្កើនផលឆ្នាំ២០០៦-២០០៧ គឺកើនឡើងជិត៩ភាគរយ បើប្រៀបធៀបនឹងផលិតផលស្រូវក្នុងរដូវបង្កបង្កើនផលឆ្នាំ២០០៥-២០០៦ ដែលមានតែ ៥,៩៨លានតោនប៉ុណ្ណោះ ។ ចំណែកឯដំណាំផ្សេងៗទៀត ជាពិសេស ផលិតផលដំណាំរួមផ្សំបានកើនឡើងតិចតួចក្នុងឆ្នាំ២០០៦ ។ ការស្តារនិងការលើកកម្ពស់សក្តានុពលធារាសាស្ត្រ នឹងបន្តស្ថិតនៅតែជាអាទិភាពខ្ពស់ សម្រាប់ការអភិវឌ្ឍការដាំដុះដំណាំនៅកម្ពុជា ។ យុទ្ធសាស្ត្រដ៏ទូលំទូលាយមួយសម្រាប់វិស័យកសិកម្មទាំងមូល កំពុងត្រូវបានរៀបចំ ។ យុទ្ធសាស្ត្រនេះ នឹងត្រូវបានបញ្ចប់នៅក្នុងត្រីមាសទីមួយ ឆ្នាំ២០០៧ ។ យុទ្ធសាស្ត្រជាអាទិភាពនៅក្នុងវិស័យនេះ សម្រាប់ដំណាក់កាលរបស់*ផយអជ* ២០០៦-២០១០ ត្រូវបានយកទៅអនុវត្តដោយយកចិត្តទុកដាក់ ។

២.២២ ការពង្រឹងនិងពង្រីកផលិតកម្មសត្វនិងការចិញ្ចឹមសត្វ និងសេវាកម្មបសុពេទ្យ នឹងបន្តរីកចម្រើនក្នុងកម្រិតយឺតៗ ក្នុងរយៈពេលពីរ-បីឆ្នាំខាងមុខ ដោយផ្អែកលើនិន្នាការអភិវឌ្ឍន៍ នាពេលថ្មីៗកន្លងមកនេះ ។ អនុវិស័យនេះនឹងនៅតែមានសារៈសំខាន់ សម្រាប់ការលើកកម្ពស់វិស័យកសិកម្មទាំងមូល ។

២.២៣ នៅឆ្នាំ២០០៦ កិច្ចខិតខំប្រឹងប្រែងជាច្រើនក្នុងការគ្រប់គ្រងវិស័យជលផល ត្រូវបានអនុវត្តយ៉ាងសកម្មបំផុត នៅក្នុងក្របខ័ណ្ឌនៃការកែទម្រង់វិស័យនេះ ដោយសម្រេចបានលទ្ធផលយ៉ាងច្រើន រួមមាន ការរៀបចំនិងកែសម្រួលលិខិតបទដ្ឋានសម្រាប់អនុវត្តច្បាប់ស្តីពីការរៀបចំសហគមន៍នេសាទ ការអភិវឌ្ឍវារីវប្បកម្ម ការសិក្សាស្រាវជ្រាវការអភិរក្ស ការបង្ក្រាបបទល្មើសនេសាទ និងការផ្សព្វផ្សាយជាដើម ។ល។ ការធានាឱ្យមានលទ្ធភាពប្រើប្រាស់ធនធានជលផលប្រកបដោយចីរភាពសម្រាប់អ្នកក្រីក្រ នឹងនៅតែជាគោលដៅចម្បងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រ ។ ក្នុងន័យនេះ អាទិភាពទាំង៥របស់ *ផយអជ* ដែលបានកំណត់សម្រាប់អនុវិស័យនេះត្រូវបន្តអនុវត្តតាមរូបភាពមួយ ដែលមានប្រសិទ្ធភាពខ្ពស់ ។

២.២៤ ជាទូទៅ ស្ថានភាពសន្តិសុខស្បៀងនៅប្រទេសកម្ពុជាមានភាពល្អប្រសើរគួរឱ្យកត់សម្គាល់ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។ តាមរយៈការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា បានឱ្យដឹងថា កង្វះអាហារូបត្ថម្ភដែលមានលក្ខណៈរ៉ាំរ៉ៃក្នុងចំណោមកុមារដែលមានអាយុក្រោម៥ឆ្នាំ មានការថយចុះពី ៤៥ភាគរយ នៅឆ្នាំ២០០០មកត្រឹម ៣៧ភាគរយនៅឆ្នាំ២០០៥ ប៉ុន្តែភាពល្អប្រសើរនេះ មិនមានដូចគ្នាទេនៅក្នុងចំណោមបណ្តាខេត្តទូទាំងប្រទេស ។ កិច្ចខិតខំប្រឹងប្រែងរួមគ្នានិងមានទិសដៅច្បាស់លាស់នៅក្នុងវិស័យជាច្រើន នឹងធានាថា "ត្រឹមឆ្នាំ២០១០ ប្រជាជនកម្ពុជាក្រីក្រដែលស្ថិតក្នុងស្ថានភាពអសន្តិសុខស្បៀង នឹងមានលទ្ធភាពទាំងផ្នែករូបវ័ន្តនិងសេដ្ឋកិច្ចល្អប្រសើរច្រើន ក្នុងការទទួលបានស្បៀងអាហារគ្រប់គ្រាន់ អាហារមានសុវត្ថិភាព និងមានជីវជាតិ ដើម្បីបំពេញសេចក្តីត្រូវការរបបអាហារ និងចំណង់ចំណូលចិត្តរបស់ពួកគេនៅគ្រប់ពេលវេលាសម្រាប់ជីវភាពរស់នៅមួយដ៏សកម្មនិងមានសុខភាពល្អ" ។ វឌ្ឍនភាពកន្លងមកក្នុងការបង្កើននិងធានាលទ្ធភាពមានស្បៀងអាហារសម្រាប់ ការប្រើប្រាស់ការធ្វើឱ្យប្រសើរឡើងលទ្ធភាពទទួលបានស្បៀងអាហារ និងក្នុងការធានាឱ្យមានការប្រើប្រាស់ម្ហូបអាហារប្រកបដោយគុណប្រយោជន៍ តាមរយៈ ការអប់រំពីអាហារូបត្ថម្ភនិងសុខភាព កម្មវិធីផ្តល់ការបំប៉នមីក្រូសារជាតិនិងការការពារ(ជាតិដែកនិងវីតាមីនអា) និងការពង្រឹងជាបន្តទៀតនូវការប្រើប្រាស់អំបិលអ៊ីយ៉ូតនិងស្តង់ដារសុវត្ថិភាពម្ហូបអាហារ ។ល។ គួរតែត្រូវបានធ្វើឱ្យមានស្ថេរភាព ដើម្បីសម្រេចគោលដៅដែលបានលើកឡើងខាងលើ ។ ក្នុងឆ្នាំ២០០៦ ភូមិគោលដៅចំនួន១៨០ ត្រូវបានអនុវត្តក្នុង "កម្មវិធីជាតិស្តីពីសន្តិសុខស្បៀងនិងការកាត់បន្ថយភាពក្រីក្រ" ។

២.២៥ កិច្ចខិតខំប្រឹងប្រែងដែលបានធ្វើឡើងក្នុងកំណែទម្រង់ផ្នែកព្រៃឈើ បានរួមចំណែកយ៉ាងច្រើន ក្នុងការថែរក្សាការគ្របដណ្តប់របស់ព្រៃឈើ ក្នុងរយៈពេលពីរ-បីឆ្នាំចុងក្រោយនេះ ។ ផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើមានប្រមាណ ៥៩ ភាគរយ នៅឆ្នាំ២០០៦ ។ កិច្ចខិតខំប្រឹងប្រែងបន្តក្នុងការអភិរក្ស និងការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព រួមជាមួយនឹងការដាំព្រៃឈើឡើងវិញ ក៏នឹងរួមចំណែកក្នុងការថែរក្សាការគ្របដណ្តប់របស់ព្រៃឈើឱ្យបាន ៦០ភាគរយនៃផ្ទៃដីសរុបរបស់ប្រទេស នៅក្នុងឆ្នាំ២០១៥ តាមការកំណត់របស់ *គអសក* ផងដែរ ។

២.២៦ វឌ្ឍនភាពគួរឱ្យកត់សម្គាល់ត្រូវបានធ្វើឡើង ក្នុងការការពារនិងអភិរក្សបរិស្ថាន ។ ក្នុងឆ្នាំ២០០៦ តំបន់ទេសចរណ៍ធម្មជាតិបីកន្លែង ត្រូវបានបង្កើតឡើង ហើយពីរកន្លែងផ្សេងទៀត កំពុងត្រូវបានរៀបចំ ។ លើសពីនេះទៀត សហគមន៍នេសាទជាច្រើនក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងនិងតំបន់បឹងទន្លេសាប និងសហគមន៍តំបន់ការពារធម្មជាតិ ត្រូវបានបង្កើតឡើង និងកំពុងរួមចំណែកក្នុងការទប់ស្កាត់ការចាក់ដីលុបដែនទឹកធម្មជាតិ និងការការពារការទន្ទ្រានយកដីខុសច្បាប់ និងការបំផ្លាញព្រៃឈើ ។ បន្ថែមពីលើផ្ទៃដីដែលបានដកហូតមកវិញចំនួន ៧២៣ហិកតា នាឆ្នាំ២០០៥ នៅក្នុងឆ្នាំ២០០៦ រាជរដ្ឋាភិបាលកម្ពុជាបានប្រមូលយកមកវិញនូវដីធ្លីដែលត្រូវបានកាន់កាប់ ដោយ ខុសច្បាប់នៅក្នុងតំបន់ការពារធម្មជាតិ បានចំនួន ២.៤៥៥ហិកតា ។ រហូតមកទល់ឆ្នាំ២០០៦ សហគមន៍តំបន់ការពារធម្មជាតិចំនួន ៧៧ ត្រូវបានរៀបចំបង្កើតឡើង ដែលក្នុងនោះ ៨សហគមន៍ ត្រូវបានបង្កើតនៅក្នុងឆ្នាំ២០០៦ ។ ជាមួយគ្នានេះដែរ រហូតមកដល់ឆ្នាំ២០០៦ តំបន់ការពារធម្មជាតិចំនួន ១៦កន្លែង ត្រូវបានកំណត់ព្រំប្រទល់ ដែលក្នុងនោះ ២កន្លែងត្រូវបានកំណត់នៅក្នុងឆ្នាំ២០០៦ ហើយការធ្វើផែនទីជាផ្លូវការសម្រាប់តំបន់ការពារទាំងនេះ ក៏ត្រូវបានរៀបចំឡើងដែរ ។ ទោះជាដូចនេះក្តី ការការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ បាននិងកំពុងជួបបញ្ហាប្រឈមមួយចំនួន ដែលបន្តនៅមានក្នុងទិដ្ឋភាពក្របខ័ណ្ឌស្ថាប័ននិងច្បាប់ ជាពិសេស ការខ្វះខាតក្នុងការងារសម្របសម្រួលរវាងស្ថាប័ននិងអាជ្ញាធរពាក់ព័ន្ធទាំងឡាយ ។ ការគ្រប់គ្រងកាកសំណល់រឹងនិងរាវរបស់រោងចក្រ ត្រូវបានកែលម្អ ដោយបានរួមចំណែកកាត់បន្ថយហេតុប៉ះពាល់ទៅលើបរិស្ថាន ។

២.២៧ កំណែទម្រង់ដីធ្លី នឹងនៅតែជាអាទិភាពខ្ពស់សម្រាប់ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច ។ ការយកចិត្តទុកដាក់ នឹងផ្តោតទៅលើ ការផ្តល់នូវប័ណ្ណកម្មសិទ្ធិដីធីស្របច្បាប់និងមិនក្លែងបន្លំ ដើម្បីផ្តល់ការធានាសន្តិសុខក្នុងការកាន់កាប់ ដល់អ្នកទាំងឡាយណា ដែលប្រើប្រាស់ជាក់ស្តែងនូវដីធ្លី ដែលពួកគាត់កំពុងកាន់កាប់ ។ ការងារដែលត្រូវធ្វើបន្ត គឺត្រូវត្រួតពិនិត្យនិងកម្រិតលើ ការប្រមូលផ្តុំកាន់កាប់ជាកម្មសិទ្ធិរបស់មនុស្សមួយចំនួនតូច (រួមទាំង ការពិនិត្យមើលឡើងវិញលើ ការផ្តល់រួចមកហើយនូវដីសម្បទានធំៗដែលមានទំហំធំលើសពីការកំណត់របស់ច្បាប់ភូមិបាលឆ្នាំ២០០១) និងលើដីដែលទុកទំនេរចោលនិងបានដាក់ឱ្យដំណើរការផលិតកម្ម/អាជីវកម្ម ។ កិច្ចខិតខំប្រឹងប្រែងចម្បងៗ សម្រាប់ការធ្វើឱ្យសម្រេចបានអាទិភាព និងការជំនះបញ្ហាប្រឈមទាំងនេះ រួមមាន :

- ក្របខ័ណ្ឌគោលនយោបាយនិងគតិយុត្តិ ដែលចាំបាច់សម្រាប់ការអនុវត្តច្បាប់ភូមិបាលប្រកបដោយប្រសិទ្ធភាព ត្រូវបានជំរុញរៀបចំកសាងឡើង និងទទួលបានការអនុម័តជាបន្តបន្ទាប់ ដែលក្នុងនោះរាប់ចាប់តាំងពីអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា រហូតដល់ប្រកាសអន្តរក្រសួង មានជាអាទិ៍ អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ ប្រកាសស្តីពីការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទីនិងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ សារាចរណែនាំស្តីពីវិធានការទប់ស្កាត់ការកាន់កាប់ដីរដ្ឋខុសច្បាប់ ព្រមទាំង ប្រកាស

អន្តរក្រសួងដែលទាក់ទងនឹង (ក) ការពង្រឹងគណៈកម្មការសុរិយោដី (ខ) យន្តការផ្តល់សេវាកម្មផ្សព្វផ្សាយការងារកសិកម្មសម្រាប់គ្រួសារដែលបានទទួលដីសម្បទានសង្គមកិច្ច ។ល។ ទន្ទឹមនឹងនេះ សេចក្តីព្រាងគោលនយោបាយ និងអនុក្រឹត្យស្តីពីការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច និងគោលនយោបាយស្តីពីប្រព័ន្ធវាយតម្លៃដី ក៏ត្រូវបានរៀបចំបង្កើតឡើង និងកំពុងស្ថិតក្នុងដំណើរការពិគ្រោះយោបល់ដែរ ។ លើសពីនេះ ដើម្បីជំរុញដោះស្រាយវិវាទដីធ្លី អាជ្ញាធរដោះស្រាយវិវាទដីធ្លីត្រូវបានបង្កើតឡើង។

- កិច្ចខិតខំប្រឹងប្រែងជាបន្ត ត្រូវបានធ្វើឡើង ក្នុងការធ្វើឱ្យប្រសើរឡើងនិងការអនុវត្តនីតិវិធីចុះបញ្ជីដី ដើម្បីផ្តល់កម្មសិទ្ធិតាមប្រព័ន្ធនិងដាច់ដោយដុំៗ ។ ការចុះបញ្ជីដែលមានលក្ខណៈតាមប្រព័ន្ធបានចំនួន ២៨០.២០៧ក្បាលដី ហើយតាមរបៀបដាច់ដោយដុំៗ បានចំនួន ១១.៧៥៤ ក្បាលដី ។
- យន្តការដោះស្រាយជម្លោះដីធ្លី តាមរយៈគណៈកម្មការសុរិយោដី បានដោះស្រាយជម្លោះដីធ្លី ១.២៤៦ករណី ដែលទាក់ទងនឹង ៦.៦៤១គ្រួសារ និងផ្ទៃដី ២.៣៩៤ហិកតា ។
- តាមរយៈការអនុវត្តគោលនយោបាយអភិវឌ្ឍន៍នៅនឹងកន្លែង និងការបែងចែកដីដែលដោះមីនរួចរួមទាំងដីដែលបានដកហូតពីការទន្ទ្រានខុសច្បាប់ ផ្ទៃដីសរុបចំនួន ៤.៥០៥.២២ហិកតា ត្រូវបានផ្តល់ជូនដល់ប្រជាជនក្រីក្រដែលគ្មានដីប្រមាណ ២៩.៧១៨គ្រួសារ ដើម្បីកាន់កាប់ជាកម្មសិទ្ធិស្របច្បាប់ ។ ដោយផ្អែកតាមស្មារតីនៃគោលនយោបាយនិងអនុក្រឹត្យលេខ ១៩ អនក្រ.ប្រក ស្តីពីសម្បទានដីសង្គមកិច្ច គម្រោងសាកល្បងមួយដែលកំពុងអនុវត្តនៅស្រុកមេមត់ និងស្រុកក្រចេះ ដោយក្រុមការងារអន្តរក្រសួង ដោយបានវាស់វែង និងកំពុងដំណើរការគូសផែនទី ធ្វើចំណាត់ថ្នាក់និងចុះបញ្ជីដីឯកជនរបស់រដ្ឋ ឱ្យបានច្បាស់លាស់ នៅលើផ្ទៃដីសរុបជាង ៦.៣១៧ ហិកតា ។
- តម្លាភាពនិងគណនេយ្យភាពក្នុងការផ្តល់សេវាកម្មក្នុងវិស័យដីធ្លីនិងសំណង់ ត្រូវបានពង្រឹង ។

២.២៨ កិច្ចខិតខំប្រឹងប្រែងជាបន្តក្នុងប្រតិបត្តិការដោះមីន បានរួមចំណែកធ្វើឱ្យប្រសើរឡើង នូវស្ថានភាពសេដ្ឋកិច្ចនិងសង្គមកិច្ចរបស់គ្រួសារកសិករក្រីក្រនៅក្នុងតំបន់ដាច់ស្រយាល និងជំរុញការអភិវឌ្ឍជនបទ ។ នៅក្នុងឆ្នាំ២០០៦ ប្រតិបត្តិការកម្ទេចឬបោសសម្អាតមីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ បានបង្កើនផ្ទៃដីគ្មានមីនពី ៣០.២៦៣ហិកតា ដែលអនុវត្តបានជាក់ស្តែងនាឆ្នាំ២០០៥ (ការប៉ាន់ស្មានរបស់*ផយអជ* មាន ៣២.៩៧៤ហិកតា) ដល់ ៣៥.៤៣៦ហិកតា នៅឆ្នាំ២០០៦ ។ ចំនួនជនរងគ្រោះដោយសារមីន បានថយចុះប្រមាណ ៥០ភាគរយ ពោលគឺថយចុះពី ៨៧៥នាក់ នៅឆ្នាំ២០០៥ (ការប៉ាន់ស្មានក្នុង*ផយអជ* មានចំនួនដល់ទៅ ៧៩៧នាក់) ដល់ ៤៤០នាក់ នៅឆ្នាំ២០០៦ ។ ផ្ទៃដីដែលបានដោះមីនរួចហើយ ត្រូវបានប្រែក្លាយឱ្យទៅជាផ្ទៃដីសម្រាប់បម្រើគោលបំណងសេដ្ឋកិច្ចនិងសង្គមកិច្ច ដូចជា តំបន់សម្រាប់ដាំដំណាំ តំបន់សម្រាប់ប្រជាជនរស់នៅ និងសម្រាប់ការកសាងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច-សង្គមកិច្ច ផ្សេងៗ។

## តារាង ២.២ : ចំណុចដៅវិស័យកសិកម្ម សម្រាប់ឆ្នាំ២០១០

| ចំណុចដៅ | ២០០៥ | ២០០៦ | ២០១០ (ចំណុចដៅ) |
|---|---|---|---|
| ផលិតផលស្រូវ (លានតោន) | ៥,៩៨ | ៦,២៦ | ៦,៥ |
| ទិន្នផលស្រូវក្នុងមួយហិកតា (តោន) | ២,៤៨ | ២,៤៩ | ២,៥ |
| ការនេសាទ (ទឹកសាប សមុទ្រ និងវារីវប្បកម្ម) តោន | ៣៤០.០០០ | ៥០៥.០០០ | ៤៥០.០០០ |
| ផ្ទៃដីស្រោចស្រព រួមទាំងការស្រោចស្រពបន្ថែម (ពាន់ហិកតា) | ៥៩៦,៣ | ៧២១,៣ | ៨១០,៣ |
| កំណែទម្រង់ដី-ចំនួនប័ណ្ណកម្មសិទ្ធិដែលបានផ្តល់ដល់កសិករ (%នៃផ្ទៃដីសរុប) | ១២ | ១៣ | ២៤ |
| ផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ (%នៃផ្ទៃដីសរុប) | ៦០ | ៥៩ | ៦០ |
| ការពឹងផ្អែកលើឈើដុត (អុស ធ្យូង) : គ្រួសារ (%) | ៨៥,៥ | ៨៣,៩ | ៦១ |

២.២៩ ការអភិវឌ្ឍជនបទ[១] ដែលជាកត្តាមួយយ៉ាងសំខាន់ សម្រាប់ការលើកកំពស់វិស័យកសិកម្មនិងការកាត់បន្ថយភាពក្រីក្រ គឺជាបញ្ហាអន្តរវិស័យ ហើយក៏ជាសកម្មភាពអាទិភាពមួយ សម្រាប់ការធ្វើវិភាជន៍និងការផ្តល់ថវិកាសម្រាប់ចំណាយផងដែរ ។ ហេតុដូចនេះ សម្រាប់ឆ្នាំ២០០៧ វិស័យអភិវឌ្ឍន៍ជនបទនេះ ត្រូវបានជ្រើសរើសជាវិស័យអាទិភាពមួយ ក្នុងចំណោមវិស័យអាទិភាព ៦ផ្សេងទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមគម្រោងសាកល្បងនៃ*កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ* ។ ការផ្តល់និងការលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធជនបទ ការលើកកម្ពស់សុខភាពនិងអនាម័យនៅតំបន់ជនបទ និងការអភិវឌ្ឍសេដ្ឋកិច្ចជនបទ គឺជាសកម្មភាពសំខាន់ៗក្នុងវិស័យនេះ ហើយនឹងនៅតែបន្តជាសកម្មភាពអាទិភាពនិងជាការប្រឈម សម្រាប់ពេលខាងមុខ ។

២.៣០ ហេដ្ឋារចនាសម្ព័ន្ធជនបទ : ក្នុងឆ្នាំ២០០៦ ផ្លូវថ្មីចំនួន ៩២ខ្សែ ដែលមានចម្ងាយសរុបចំនួន ២៦៤គ.ម ត្រូវបានសាងសង់ ។ ផ្លូវចំនួន ៤៤ខ្សែ ដែលមានចម្ងាយសរុប ៧០៧គ.ម ត្រូវបានជួសជុល និងផ្លូវចំនួន ១១៨ខ្សែ ដែលមានចម្ងាយសរុប ៨២២គ.ម ត្រូវបានថែរក្សា ។ ស្ពានតូចៗចំនួន ៧០ និងលូបង្ហូរទឹកចំនួន ១៦០ ត្រូវបានសាងសង់ ។ បន្ថែមលើនេះទៀត សាលារៀនថ្មីចំនួន ១៧ខ្នង ដែលមាន៧២បន្ទប់ និងទីផ្សារសហគមន៍ចំនួនបីកន្លែង (២នៅខេត្តកំពង់ធំ និង ១នៅភ្នំពេញ) ត្រូវបានសាងសង់ ។ ដើម្បីផ្តល់ទឹកបរិភោគដែលមានសុវត្ថិភាពជាងមុន ទឹកអណ្តូងពីអណ្តូងទឹកចំនួន ១.៨៤០ ត្រូវបានយកទៅធ្វើតេស្តមើល ។ បង្គន់អនាម័យតាមគ្រួសារចំនួន ៣.៥០០ និងបង្គន់សាធារណៈចំនួន ២២ ក៏ត្រូវបានផ្តល់ជូនប្រជាជនដែរ ។

២.៣១ សុខភាពនិងអនាម័យនៅតំបន់ជនបទ : ក្នុងឆ្នាំ២០០៦ ទឹកអនាម័យសម្រាប់បរិភោគ ត្រូវបានផ្តល់បន្ថែមទៅដល់ ៧១ស្រុក ក្នុង២៣ខេត្ត-ក្រុង ។ អណ្តូងថ្មីគ្រប់ប្រភេទចំនួន ១.៣៤៤ ត្រូវបានសាងសង់ និងអណ្តូងចាស់ៗគ្រប់ប្រភេទចំនួន ៦១០ ត្រូវបានជួសជុល ។ ក្នុងគោលបំណងផ្គត់ផ្គង់ទឹកស្អាតបរិភោគ ស្រះទឹកចំនួន ១៨ ត្រូវបានផ្តល់ជូនដល់សហគមន៍ជនបទដែលខ្វះខាតទឹក ។

[១] តួលេខទាំងអស់នៅក្នុងការងារអភិវឌ្ឍន៍ជនបទ បង្ហាញតែពីសមិទ្ធផលដែលភាគច្រើនបង្កើតឡើងដោយក្រសួងអភិវឌ្ឍន៍ជនបទ

២.៣២ ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ៖ មីក្រូឥណទានដែលមានអត្រាការប្រាក់សមរម្យ ត្រូវបានផ្តល់ដល់ប្រជាជននៅជនបទ ដើម្បីអភិវឌ្ឍអាជីវកម្មធុនតូចនៅជនបទ ។ លើសពីនេះ ធនាគារស្រូវ និងធនាគារសត្វពាហនៈ ក៏បានដំណើរការ ដើម្បីជួយដល់ប្រជាជនក្រីក្រ ។ ប្រព័ន្ធធារាសាស្ត្រធុនតូច ក៏ត្រូវបានសាងសង់ដែរ ដើម្បីផ្គត់ផ្គង់ទឹកសម្រាប់ការងារកសិកម្ម ។ ទំនប់ទឹកថ្មីប្រវែង ១.៦៨០ម៉ែត្រ ប្រឡាយទឹកចំនួន ២១ខ្សែ ដែលមានប្រវែង ៣៩.៥១០ម៉ែត្រត្រូវបានសាងសង់ ហើយទ្វារទឹកចំនួន៤ ក៏ត្រូវបានកសាងដែរ ។ ប្រឡាយទឹកចាស់ៗចំនួន ២៦ខ្សែ ដែលមានប្រវែង ៣៩.៥១០ ម៉ែត្រត្រូវបានជួសជុល ។

**តារាង ២.៣ ៖ ចំណុចដៅសម្រាប់ការអភិវឌ្ឍជនបទ ឆ្នាំ២០១០**

| ចំណុចដៅ | ២០០៥ | ២០០៦ | ២០១០ (ចំណុចដៅ) |
|---|---|---|---|
| ផ្លូវលំជនបទដែលស្តារបាន គម (ក្នុងចំណោមផ្លូវសរុប២៨.០០០គម) | ២២.៧០០ | ២៣.៧១០ | ២៥.០០០ |
| ការទទួលបានទឹកស្អាតបរិភោគ (%នៃប្រជាជននៅជនបទ) | ៤១,៦ | ៤២,៦ | ៤៥ |
| ការទទួលបានអនាម័យ (%នៃប្រជាជននៅជនបទ) | ១៥,៧ | ១៥,៨ | ២៥ |

## ចតុកោណទី២ ៖ ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

២.៣៣ ចតុកោណនេះ ជាចតុកោណកំណើននៃយុទ្ធសាស្ត្រចតុកោណ ដែលគ្របដណ្តប់លើ *(ក) ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ (ខ) ការគ្រប់គ្រងធនធានទឹកនិងប្រព័ន្ធធារាសាស្ត្រ (គ) ការអភិវឌ្ឍវិស័យថាមពល និងបណ្តាញអគ្គិសនី និង (ឃ) ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍* ។ ការធ្វើឱ្យប្រសើរឡើងដែលសម្រេចបាននៅក្នុងការងារអាទិភាពទាំងបួននេះ បានធ្វើឱ្យមានការប្រែប្រួលជាវិជ្ជមាននៅក្នុងវិស័យសង្គមកិច្ចនិងសេដ្ឋកិច្ច ដូចជា វិស័យអប់រំ សុខាភិបាល ទេសចរណ៍ ពាណិជ្ជកម្ម អភិវឌ្ឍន៍ជនបទ រួមទាំងការធ្វើសមាហរណកម្មទៅក្នុងតំបន់និងពិភពលោក ។

២.៣៤ ការអភិវឌ្ឍសំខាន់ៗ ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត (ក្នុងនោះ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងការអភិវឌ្ឍប្រព័ន្ធទឹកស្អាតនៅក្នុងទីក្រុង) ក្នុងឆ្នាំ២០០៦ រួមមាន ៖

- ផ្លូវជាតិនិងផ្លូវខេត្តដែលក្រាលកៅស៊ូ មានចម្ងាយសរុប ២.៧៣២គ.ម កើនពីឆ្នាំ២០០៥ ដែលមានតែ ២.១០០គ.ម ប៉ុណ្ណោះ ដែលជាភស្តុតាងបញ្ជាក់ថា ឆ្នាំ២០០៦កន្លងទៅនេះ គឺជាឆ្នាំដំបូងដែលការដ្ឋានផ្លូវថ្នល់និងស្ពាន ត្រូវបានបើកឱ្យដំណើរការ ច្រើនជាងគេ ។
- ច្បាប់ចរាចរ ត្រូវបានដាក់ឱ្យអនុវត្ត ។ ការរៀបចំប្រព័ន្ធច្បាប់មួយដែលមានលក្ខណៈសមស្របនិងមានប្រសិទ្ធភាពសម្រាប់វិស័យដឹកជញ្ជូន ហើយការពង្រឹងការអនុវត្តប្រព័ន្ធច្បាប់នេះ នៅតែបន្តជាអាទិភាពមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ។

- វិធានការសុវត្ថិភាពចរាចរផ្លូវថ្នល់ត្រូវបានពង្រឹង តាមរយៈ (ក) ការរៀបចំដាក់ឱ្យអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរផ្លូវគោកដំណើរការ (ខ) ការរៀបចំឈុតឆាកអប់រំខ្លីៗស្តីពីសុវត្ថិភាពចរាចរផ្លូវគោកដើម្បីផ្សព្វផ្សាយតាមទូរទស្សន៍ និង (គ) ការបោះពុម្ពផ្សាយនូវឯកសារដែលពាក់ព័ន្ធនឹងសុវត្ថិភាពចរាចរផ្លូវគោក ។
- ការដឹកជញ្ជូនតាមផ្លូវគោកនៅតែជាសកម្មភាពធំជាងគេបង្អស់នៅក្នុងវិស័យដឹកជញ្ជូន ។
- ការដឹកជញ្ជូនតាមផ្លូវដែក មានចំនួនប្រមាណតែ ២០ភាគរយនៃបរិមាណអ្នកធ្វើដំណើរ (នាក់/គម) និង ១០ភាគរយនៃបរិមាណទំនិញ (តោន/គម) ដែលធ្វើចរាចរក្នុងទូទាំងប្រទេសប៉ុណ្ណោះ ប៉ុន្តែផែនការនិងគម្រោងការជាច្រើន កំពុងត្រូវបានរៀបចំ ដើម្បីធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធដឹកតាមផ្លូវដែកកាន់តែមានអត្ថប្រយោជន៍ ច្រើនជាងមុន ។
- ទំហំនៃដឹកជញ្ជូនតាមផ្លូវទឹកក្នុងស្រុក ក៏មានបរិមាណតូចដែរ ។ ការដឹកជញ្ជូនតាមផ្លូវទឹក មានចំនួនប្រមាណតែ ១៥ភាគរយនៃបរិមាណអ្នកធ្វើដំណើរ (នាក់/គម) និង ២០ភាគរយនៃបរិមាណទំនិញ (តោន/គម) ដែលធ្វើចរាចរក្នុងទូទាំងប្រទេសប៉ុណ្ណោះ ទោះបីជាបរិមាណទំនិញសរុបដែលបានលើកដាក់នៅកំពង់ផែអន្តរជាតិពីរមានដល់ ២,៦លានតោន ក្នុងឆ្នាំ២០០៦ក៏ដោយ ដោយមានការកើនឡើង ១៥ភាគរយ បើប្រៀបធៀបជាមួយនឹងបរិមាណលើកដាក់ ក្នុងឆ្នាំ២០០៥ ។ ការបូមដីស្តារគ្រប់ផ្លូវទឹកក្នុងស្រុកសំខាន់ៗ ជាពិសេស ទន្លេមេគង្គនិងទន្លេសាប បានបន្តជួយសម្រួលដល់ការដឹកជញ្ជូនតាមទន្លេ និងស្ថិតនៅតែជាអាទិភាពបន្ទាន់ ។ ថ្លៃដឹកជញ្ជូនខ្ពស់ និងប្រសិទ្ធភាពការងារដែលមានលក្ខណៈមិនទាន់សមស្រប គឺជាបញ្ហាប្រឈមដែលត្រូវចាប់អារម្មណ៍ ដើម្បីធ្វើការដោះស្រាយ នៅក្នុងផ្នែកដឹកជញ្ជូនតាមផ្លូវទឹកក្នុងស្រុក ។
- ការបង្កើនលើកកម្ពស់គុណភាពនិងសមត្ថភាពរបស់អាកាសយានដ្ឋានអន្តរជាតិទាំងបី បានជំរុញឱ្យមានការអភិវឌ្ឍយ៉ាងខ្លាំងក្នុងវិស័យទេសចរណ៍ ដែលបានរួមចំណែកក្នុងការធ្វើឱ្យមានវឌ្ឍនភាពសេដ្ឋកិច្ច-សង្គមកិច្ច តាមរយៈ ឥទ្ធិពលពហុមេគុណនៃវិស័យនេះ ។ អាកាសយានដ្ឋានក្នុងស្រុកចំនួន៨ ត្រូវបានជួសជុល និងថែរក្សា ជាពិសេសផ្នែកសំខាន់ៗជាច្រើន ដូចជា ផ្លូវហោះហើរនិងចុះចតទីលានចត និងការកំណត់ព្រំខ័ណ្ឌរបស់អាកាសយានដ្ឋានទាំងនោះ ទៅតាមផែនការប្រចាំឆ្នាំ ។ ក្រុមហ៊ុនអាកាសចរណ៍អន្តរជាតិពីរទៀត បានចាប់ផ្តើមហោះហើរមកកម្ពុជា ក្នុងឆ្នាំ២០០៦ ហើយការហោះហើរជាអន្តរជាតិ បានកើនឡើង ១៣ភាគរយ ធៀបនឹងឆ្នាំ២០០៥ ។ ការអភិវឌ្ឍធនធានមនុស្សក្នុងជំនាញអាកាសចរណ៍ស៊ីវិល នឹងស្ថិតនៅជាអាទិភាពមួយ សម្រាប់ការអភិវឌ្ឍក្នុងវិស័យនេះនាពេលអនាគត ។

- កិច្ចខិតខំប្រឹងប្រែងជាច្រើនត្រូវបានធ្វើឡើង នៅក្នុងពង្រីកការងារផលិតទឹកស្អាតសម្រាប់តំបន់ទីប្រជុំជន ។ នៅឆ្នាំ២០០៦នេះ សមត្ថភាពផលិតទឹកស្អាតរបស់រដ្ឋាករទឹកក្នុងក្រុងព្រះសីហនុ និងនៅទីរួមខេត្តសៀមរាប ត្រូវបានបង្កើនដល់ ៨.០០០ម៉ែត្រគ្រីគុណក្នុងមួយថ្ងៃ ចំណែកឯរដ្ឋាករទឹកខេត្តបាត់ដំបង ពោធិសាត់ កំពង់ធំ កំពង់ចាម កំពត និងខេត្តស្វាយរៀង ក៏បានលើកកម្ពស់សមត្ថភាពផលិតទឹកស្អាតរបស់ខ្លួន ចាប់ពី ២.៥០០ ដល់ ៨.០០០ម៉ែត្រគ្រីគុណដែរ ។

២.៣៥ កិច្ចខិតខំប្រឹងប្រែងរួមគ្នានិងការវិនិយោគនៅក្នុងផ្នែក ធារាសាស្ត្រនិងការគ្រប់គ្រងធនធានទឹក ក្នុងឆ្នាំ ២០០៦ ធ្វើឱ្យសម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់ ដូចខាងក្រោម :

- ប្រព័ន្ធធារាសាស្ត្រនិងប្រឡាយបង្ហូរទឹកដែលមានស្រាប់ជាច្រើន ជាពិសេស នៅក្នុងតំបន់ដែលមានអត្រាភាពក្រីក្រខ្ពស់ និងតំបន់តាមបណ្តោយព្រំដែន ត្រូវបានស្តារនិងជួសជុលឡើងវិញ ដោយមានសមត្ថភាពស្រោចស្រពលើផ្ទៃដីសរុប ៨៩.២១១ហិកតា ( ផ្ទៃដីស្រែវស្សា ៧៥.១០១ហិកតា និងផ្ទៃដីស្រែប្រាំង ១៤.១១០ហិកតា ) ។
- សមត្ថភាពស្តុកទឹកលើដី ត្រូវបានពង្រីក ហើយបច្ចេកវិទ្យាប្រមូលទឹកទុក ត្រូវបានលើកកម្ពស់ ។
- វិធានការសម្រាប់ការកាត់បន្ថយនិងការគ្រប់គ្រង គ្រោះទឹកជំនន់និងគ្រោះរាំងស្ងួត ត្រូវបានរៀបចំបង្កើតឡើង និងត្រូវបានដាក់ឱ្យអនុវត្ត ។
- សហគមន៍កសិករប្រើប្រាស់ទឹក ត្រូវបានពង្រឹង និងពង្រីក ដោយមានការបង្កើននូវសមាជិកភាព និងការចូលរួមរបស់ស្ត្រី ។
- ប្រព័ន្ធតាមដាននិងសង្កេតឧតុនិយម-ជលសាស្ត្រទូទាំងប្រទេស ដែលអាចមានលទ្ធភាពផ្តល់នូវការព្យាករណ៍ឧតុនិយម-ជលសាស្ត្រមួយ ដែលមានគុណភាពខ្ពស់ មានប្រសិទ្ធភាព និងផ្តល់ព័ត៌មានទាន់ពេលវេលា ត្រូវបានតម្លើង និងធ្វើឱ្យប្រសើរឡើង ។ ក្តារម៉ែត្រសម្រាប់វាស់កម្ពស់ទឹកបីកន្លែងត្រូវបានតម្លើងនៅខេត្តព្រៃវែង កំពង់ចាម និងកណ្តាល ហើយស្ថានីយ៍តាមដាននិងអង្កេតឧតុនិយមពីរកន្លែងនៅខេត្តរតនៈគិរី និងមណ្ឌលគិរី និងប៉ុស្តិ៍តម្រងទឹកភ្លៀងពីរកន្លែងនៅខេត្តឧត្តរមានជ័យ ក៏ត្រូវបានតម្លើងដែរ ។

២.៣៦ ការអភិវឌ្ឍសំខាន់ៗ ក្នុងវិស័យថាមពលនិងអគ្គិសនី និង ប្រេងកាតនិងឧស្ម័ន ក្នុងឆ្នាំ២០០៦ រួមមាន :

- ធ្វើកិច្ចខិតខំប្រឹងប្រែងជាបន្តក្នុងការអនុវត្តយុទ្ធសាស្ត្ររយៈពេលមធ្យមសម្រាប់វិស័យថាមពលរបស់ *ផយអជ* បានធ្វើឱ្យប្រសើរឡើងនូវស្ថានភាពអគ្គិសនីភាវូបនីយកម្មរបស់ប្រទេស ជាពិសេស នៅតំបន់ជនបទ ។ ការផលិតអគ្គិសនីបានកើនឡើង ២០ភាគរយ ក្នុងឆ្នាំ២០០៦ ពោលគឺ បានកើនឡើងពី ៨៩៤,៥២ គីកាវ៉ាត់ម៉ោង ( តួលេខជាក់ស្តែង) ក្នុងឆ្នាំ២០០៥ ដល់ ១.០៧៣,២៨ គីកាវ៉ាត់ម៉ោង ក្នុងឆ្នាំ២០០៦ ។ ចរន្តអគ្គិសនីនាំចូលពីប្រទេសថៃមានការកើនឡើងប្រមាណ ២០ភាគរយ (កើនពី

៥៦,៨៣ គីកាវ៉ាត់ម៉ោង នៅឆ្នាំ២០០៥ ដល់ ៦៨,២៤គីកាវ៉ាត់ម៉ោង នៅឆ្នាំ២០០៦) ហើយការនាំចូលពីប្រទេសវៀតណាមក៏មានការកើនឡើងដែរ គឺជិត៦០ភាគរយ (កើនឡើងពី ២៥,៤០គីកាវ៉ាត់ម៉ោង ក្នុងឆ្នាំ ២០០៥ ដល់ ៤០,៥៨គីកាវ៉ាត់ម៉ោង នៅឆ្នាំ២០០៦) ។

- ការរុករកប្រភពធនធានប្រេងកាតនិងឧស្ម័ននៅក្នុងដែនសមុទ្រ កំពុងតែមានដំណើរការល្អ ហើយការទាញយកផលនឹងអាចចាប់ផ្តើមក្នុងរយៈពេលមិនយូរខាងមុខ ។ ផែនការសម្រាប់ប្រើប្រាស់ប្រភពថាមពលនេះ និងចំណូលដែលអាចទទួលបានពីប្រភពធនធាននេះតាមរបៀបមួយដ៏ប្រសើរបំផុត ដើម្បីផ្តល់ផលប្រយោជន៍ដល់ប្រជាជនកម្ពុជា ក្នុងរយៈពេលចំពោះមុខនិងយូរអង្វែង កំពុងត្រូវបានសិក្សានិងវាយតម្លៃ យ៉ាងយកចិត្តទុកដាក់ ។

២.៣៧ ការអភិវឌ្ឍធំៗ ផ្នែកបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ ក្នុងឆ្នាំ២០០៦ រួមមាន :

- បណ្តាញទូរគមនាគមន៍ត្រូវបានពង្រីក ដោយបានស្តែងចេញតាមការកើនឡើងនៃចំនួនអ្នកប្រើប្រាស់ទូរស័ព្ទ (ទូរស័ព្ទខ្សែនិងចល័ត) ដែលបានកើនឡើងដល់ ១.១៧៥.០០០នាក់ ឬ ៧,៥៦នាក់ក្នុងចំណោមប្រជាជន ១០០នាក់ ធៀបនឹងតួលេខឆ្នាំ២០០៥ ដែលមានតែ ៨៨២.០០០នាក់ ឬ ៦,១០ នាក់ក្នុងចំណោមប្រជាជន ១០០នាក់ ជាពិសេស ការកើនឡើងនៅក្នុងតំបន់ជនបទ ។ ទន្ទឹមនេះលទ្ធភាព ទទួលបានសេវាអ៊ីមែលនិងអ៊ិនធ័រណែត ក៏មានការកើនឡើងថែមទៀតនៅក្នុងខេត្ត-ក្រុងទាំង២៤។
- ការគ្របដណ្តប់ និងគុណភាពនិងប្រសិទ្ធភាពនៃ ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋាភិបាល ក្នុងនោះមាន វិទ្យុ ទូរទស្សន៍ និងទីភ្នាក់ងារសារព័ត៌មាន ត្រូវបានពង្រីក និងធ្វើឱ្យប្រសើរឡើង ។ ប្រមាណ ៧០ភាគរយនៃប្រជាជនកម្ពុជា បានទទួលព័ត៌មាន ការអប់រំ និងការកំសាន្តតាមរយៈប្រព័ន្ធផ្សព្វផ្សាយដែលកំពុងមានសព្វថ្ងៃនេះ ទាំងរបស់រដ្ឋាភិបាល និងរបស់ឯកជន ។
- អ្នកវិនិយោគទុនបរទេសច្រើនថែមទៀត បានចូលរួមក្នុងវិស័យនេះ ហើយបានរួមចំណែកយ៉ាងច្រើនក្នុងការអភិវឌ្ឍក្នុងវិស័យ ។

### ចតុកោណទី៣ : ការអភិវឌ្ឍផ្នែកឯកជននិងការបង្កើតការងារ

២.៣៨ មុំទាំងបួននៃចតុកោណនេះរួមមាន *(ក) ការពង្រឹងវិស័យឯកជននិងការទាក់ទាញការវិនិយោគ (ខ) ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម (គ) ការបង្កើតការងារ និងការធានាលក្ខខណ្ឌការងារល្អប្រសើរជូនកម្មករនិងនិយោជិត (ឃ) ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គមសម្រាប់កម្មករ* ។ វឌ្ឍនភាពដែលបានធ្វើឱ្យមានឡើងកន្លងមកដើម្បីសម្រេចអាទិភាពទាំងនេះ បានរួមចំណែកគួរឱ្យកត់សម្គាល់ក្នុងការអភិវឌ្ឍថ្មីៗនេះ ក្នុងវិស័យផ្សេងៗទៀត និងក្នុងការលើកកម្ពស់ស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ចរបស់ប្រជាជននៅជនបទ ជាពិសេស អ្នកក្រីក្រ ។

២.៣៩ ការអភិវឌ្ឍចម្បងៗ ក្នុងការពង្រឹងវិស័យឯកជននិងការទាក់ទាញការវិនិយោគ ក្នុងឆ្នាំ២០០៦ រួមមាន :

- វេទិកាចម្រុះរវាងរាជរដ្ឋាភិបាលនិងវិស័យឯកជន បានបន្តរៀបចំកិច្ចប្រជុំរៀងរាល់ ៦ខែម្តង ។ វេទិកានេះ និងគណៈកម្មាធិការដឹកនាំការងារនិងអនុគណៈកម្មាធិការផ្សេងៗទៀត បានផ្តល់លទ្ធភាពយ៉ាងសំខាន់ សម្រាប់កិច្ចសហប្រតិបត្តិការនិងការយល់ដឹងពីគ្នា ដ៏មានអត្ថប្រយោជន៍ រវាងរាជ-រដ្ឋាភិបាលនិងវិស័យឯកជន ។ ក្រុមការងារថ្មីមួយត្រូវបានបង្កើតឡើងថែមទៀត សម្រាប់ជំរុញការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងល្អរវាងនិយោជកនិងនិយោជិត ។ ការគ្រប់គ្រងអាជីវកម្មធនធានរ៉ែលោហធាតុ និងការពង្រឹងនិងការលើកកម្ពស់សកម្មភាពពាណិជ្ជកម្ម ដែលត្រូវបានបន្ថែមជាអាទិភាព សម្រាប់កិច្ចខិតខំប្រឹងប្រែងទាំងឡាយ នៅក្នុងការងារនេះ ។
- លើកកម្ពស់កំណើន ដែលនាំមុខដោយការនាំចេញ និងដែលមានលក្ខណៈគាំទ្រអ្នកក្រីក្រ តាមរយៈការធ្វើពិពិធកម្ម ការវិនិយោគរបស់វិស័យឯកជនក្នុងវិស័យអាទិភាពមួយចំនួន ត្រូវបានលើកទឹកចិត្តសម្រួល និងទ្រទ្រង់ ដោយការគាំទ្ររបស់រដ្ឋាភិបាល ។ ឧស្សាហកម្មដែលត្រូវការពលកម្មច្រើន និងកម្មន្តសាលនិងការកែច្នៃសម្រាប់ការនាំចេញ វិស័យទេសចរណ៍និងសកម្មភាពដែលពាក់ព័ន្ធនិងការអភិវឌ្ឍធនធានមនុស្ស គឺជាគោលដៅដ៏ចម្បងរបស់ការវិនិយោគរបស់វិស័យឯកជន នៅក្នុងរយៈពេលកន្លងមក ។
- វិស័យពាណិជ្ជកម្ម បានក្លាយជាប្រភពដ៏ចម្បងមួយសម្រាប់កំណើនសេដ្ឋកិច្ច ជាកត្តាមួយយ៉ាងសំខាន់សម្រាប់ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងជាការរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ។ ការនាំចេញផលិតផលសំលៀកបំពាក់ បានកើនឡើងដល់ ១២.៧០៩ពាន់លានរៀល (ជាង ៣ពាន់លានដុល្លារអាមេរិក) នៅក្នុងឆ្នាំ២០០៦ ។ ស្រូវចំនួន ១.៥លានតោន ត្រូវបាននាំចេញនៅក្នុងឆ្នាំ ២០០៦ គឺស្មើនឹងពីរដងនៃ កម្រិតនាំចេញឆ្នាំ២០០៥ ។ ទោះជាដូចនេះក្តី ការនាំចេញផលិតផលផ្សេងទៀតរបស់កម្ពុជា នៅតែជួបប្រទះនឹងបញ្ហាប្រឈមជាច្រើន ។ ដើម្បីដោះស្រាយបញ្ហានេះ គំនិតផ្តួចផ្តើមនិងវិធានការកែ ទម្រង់នានា ត្រូវបានដាក់ឱ្យអនុវត្ត ដើម្បី :
  - ជំរុញលើកទឹកចិត្តឱ្យមានលទ្ធភាពចូលទៅក្នុងទីផ្សារក្រៅប្រទេសនានា របស់ផលិតផលពិសេស និងមានគុណភាពខ្ពស់របស់កម្ពុជា ដែលរាប់បញ្ចូលទាំងផលិតផលកសិកម្ម (ជាពិសេស ផលិតផលដែលបានកែច្នៃរួចហើយ) ផលិតផលកែច្នៃពីត្រី និងសេវាកម្មកម្លាំងពលកម្ម ។
  - ជំរុញផលិតផលកម្ពុជានៅទីផ្សារបរទេស ។
  - ជំរុញលើកទឹកចិត្តឱ្យមានការបង្កើតសមាគមសម្រាប់សមាជិកភាពក្នុងធុរៈកិច្ច និងពង្រឹងសមត្ថភាពផ្សព្វផ្សាយរបស់សមាគមទាំងនោះ ។
  - កាត់បន្ថយឧបសគ្គនានាដែលបណ្តាលមកពីគោលនយោបាយ ចំពោះប្រសិទ្ធភាពរបស់អន្តរកម្មទាំងឡាយ ។

- រៀបចំឱ្យមានប្រសិទ្ធភាពនូវអធិការកិច្ចគយ ដើម្បីធ្វើឱ្យការងារនេះមានភាពងាយស្រួលជាងមុន សម្រាប់អតិថិជន និងមិនមានការពន្យារនិងការចំណាយដែលផ្សារភ្ជាប់នឹងស្ថានភាពនេះ រួមទាំង ការរៀបចំ និងការអនុវត្តច្បាប់គយនិងរដ្ឋាករ ដែលបានកែសម្រួលរួចហើយ ។
- កាត់បន្ថយឧបសគ្គនៃការនាំចូល ដូចជា តម្លៃខ្ពស់នៃការចុះបញ្ជី និងតម្លៃនៃការចេញអាជ្ញាប័ណ្ណ ។
- ជួយសម្រួលដល់ការបង្កើត *តំបន់កែច្នៃសម្រាប់ការនាំចេញ* ដើម្បីជំរុញឧស្សាហកម្មកែច្នៃ និង កម្មន្តសាល សម្រាប់បម្រើឱ្យការនាំចេញ ។

២.៤០ ការអភិវឌ្ឍបន្ថែមទៀតនៅក្នុងសហគ្រាសធុនតូចនិងមធ្យម បានរួមចំណែកផ្តល់អត្ថប្រយោជន៍ដល់ សហគមន៍ជនបទ ក្នុងការកែច្នៃ និងក្នុងការបង្កើតតម្លៃបន្ថែមទៅលើផលិតផល ក៏ដូចជា ការបង្កើតការងារធ្វើ ។ ការអភិវឌ្ឍទាំងនេះក៏បានបង្កើតផងដែរ នូវទំនាក់ទំនងដ៏សំខាន់ ជាមួយនឹងការអភិវឌ្ឍនៃវិស័យពាណិជ្ជកម្ម ក៏ដូចជា ជាមួយនឹងសហគ្រាសធុនធំ ។

២.៤១ ការង្កើតការងារនិងការធានាលក្ខខណ្ឌការងារល្អប្រសើរជូនកម្មករនិងនិយោជិត គឺជាគោលដៅរយៈពេល វែងមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលសំដៅលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ហើយចុងក្រោយ បង្អស់ដើម្បីការកាត់បន្ថយភាពក្រីក្រនិង និងការជំរុញកំណើនសេដ្ឋកិច្ច ។ រាជរដ្ឋាភិបាលកម្ពុជា បានដើរតួនាទី យ៉ាងសំខាន់ ក្នុងការបង្កើតឱកាសការងារ សម្រាប់ប្រជាជនកម្ពុជាទាំងអស់ ជាពិសេស អ្នកក្រីក្រ ។ ក្នុងឆ្នាំ ២០០៦ ដោយមានជំនួយពីរាជរដ្ឋាភិបាល ពលករកម្ពុជាចំនួន ៣៩.០៧៥នាក់ ត្រូវបានផ្តល់ការងារជូន ទាំងនៅ ក្នុងនិងក្រៅប្រទេស (៣៥.៤៣៩នាក់ នៅក្នុងប្រទេស និង៣.៦៣៦នាក់ នៅក្រៅប្រទេស) បើប្រៀបធៀប ជាមួយតួលេខឆ្នាំ២០០៥ គឺមានតែ ២២.៨៣០នាក់ប៉ុណ្ណោះ (២០.៥៥២នាក់ នៅក្នុងប្រទេស និង ២.២៧៨នាក់ នៅក្រៅប្រទេស) ។ បណ្តាញអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ត្រូវបានបង្កើតឡើង ដើម្បីបម្រើ ដោយស្មើភាពគ្នា ទាំងបុរសនិងទាំងស្ត្រី ជាពិសេស ជនក្រីក្រ ជនពិការ និងក្រុមជនដែលងាយរងគ្រោះ ហើយ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ សម្រាប់រយៈពេលខ្លីនិងវែង ។ នៅក្នុងឆ្នាំ២០០៦ សិស្ស-និស្សិត ដែលបានបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈសាធារណៈ មានចំនួន ១០.៦៨៦នាក់ (ដោយមិនរាប់បញ្ចូលតួលេខសិស្ស-និស្សិតដែលបានទទួលការបណ្តុះបណ្តាល តាមរយៈ អង្គការក្រៅរដ្ឋាភិបាល និងសាសាឯកជននានា) គឺមានការកើនឡើងធៀបជាមួយតួលេខឆ្នាំ២០០៥ ដែលស្មើនឹង ៩.០៧៣នាក់ ។ អង្កេត ស្តីពីវិសមភាពយេនឌ័រនៅក្នុងការបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ ត្រូវបានរៀបចំធ្វើឡើងនៅក្នុងខេត្ត-ក្រុងជា ច្រើន ហើយការបញ្ជ្រាបយេនឌ័រទៅក្នុងកម្មវិធីនៃការបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ ក៏ត្រូវបានចាប់ផ្តើមធ្វើឡើង ដែរ ។ លក្ខខណ្ឌនៃកន្លែងធ្វើការ ដែលមានសុវត្ថិភាពត្រឹមត្រូវនិងមានអនាម័យល្អ និងលក្ខខណ្ឌកិច្ចសន្យាដែល ត្រឹមត្រូវ និងយុត្តិធម៌សម្រាប់កម្លាំងពលកម្ម រួមទាំង ការកំណត់កម្រិតអប្បបរមានៃប្រាក់ឈ្នួលប្រចាំខែ និងថ្ងៃ ឈប់សម្រាកការកាត់បន្ថយវិសមភាព ក្នុងប្រាក់ឈ្នួលរវាងបុរសនិងស្ត្រី ដំណោះស្រាយជម្លោះនិងការមិនឯកភាព

គ្នា ដោយសន្តិវិធី ដោយមិនបង្កឱ្យមានការអាក់ខានដល់ផលិតកម្ម និងការបាត់បង់ប្រាក់ឈ្នួលរបស់និយោជិក ត្រូវបាន យកចិត្តទុកដាក់អនុវត្ត ។ កិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយសមាមាត្រនៃពលកម្មកុមារក្នុងមុខរបរដែលមានគ្រោះថ្នាក់ ត្រូវបានអនុវត្តតាមរយៈគម្រោង/កម្មវិធី និងវិធានការគោលនយោបាយជាច្រើន ។ កុមារចំនួន ១៦.០០០នាក់ ត្រូវបានទទួលការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈក្រៅប្រព័ន្ធ ។ ផែនការប្រាំឆ្នាំស្តីពីការលុបបំបាត់រូបភាពធ្ងន់ធ្ងរនៃពលកម្មកុមារ និងលិខិតបទដ្ឋានផ្សេងៗទៀតដែលទាក់ទងនឹងពលកម្មកុមារនិងបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងពលកម្ម ត្រូវបានរៀបចំកសាងឡើង និងរៀបចំជាសេចក្តីព្រាង ។

២.៤២ ទេសចរណ៍ : វិស័យនេះ គឺមានលំដាប់ថ្នាក់ទី២ បន្ទាប់ពីផ្នែកឧស្សាហកម្មកាត់ដេរ ដែលរួមចំណែកក្នុងការបង្កើនកំណើនសេដ្ឋកិច្ច និងក្នុងការផ្តល់ការងារដ៏ច្រើនជូនប្រជាជនកម្ពុជា ក្នុងផ្នែកជាច្រើនដែលទាក់ទង (ដូចជាការធ្វើបដិសណ្ឋារកិច្ចកិច្ចភ្ញៀវទេសចរ ការដឹកជញ្ជូនភ្ញៀវ និងផ្នែកផ្សេងទៀត) ។ ក្នុងឆ្នាំថ្មីៗកន្លងទៅនេះ វិស័យទេសចរណ៍ បាននិងកំពុងកើនឡើងក្នុងអត្រាយ៉ាងខ្ពស់និងឆាប់រហ័ស ។ រាជរដ្ឋាភិបាលកម្ពុជា បានបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការអនុវត្តគោលនយោបាយទេសចរណ៍ ដោយផ្អែកលើគោលការណ៍មូលដ្ឋានដែលបានកំណត់នៅក្នុង*ផយអជ* (ការអនុវត្តគោលនយោបាយបើកទូលាយជើងមេឃ ការពង្រឹងវិស័យទេសចរណ៍ក្នុងតំបន់ ការពង្រឹងសមត្ថភាពដើម្បីទប់ស្កាត់រាលសកម្មភាពឧក្រិដ្ឋកម្មដែលជាប់ពាក់ព័ន្ធនឹងវិស័យទេសចរណ៍) និងក្នុងការធ្វើឱ្យប្រសើរឡើងហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវថ្នល់ អាកាសយានដ្ឋាន កំពង់ផែ) ក៏ដូចជាការផ្តល់នូវបរិយាកាសមួយដែលមានសន្តិភាព ច្បាប់ និងសណ្តាប់ធ្នាប់ បានធ្វើឱ្យមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់នៅក្នុងវិស័យទេសចរណ៍នេះ។ នៅក្នុងឆ្នាំ២០០៦ ភ្ញៀវទេសចរណ៍អន្តរជាតិចំនួន ១.៧០០.០៤១នាក់ បានចូលមកទស្សនាកម្ពុជា គឺបានកើនឡើង ១៩.៥៩ភាគរយ បើប្រៀបធៀបនឹងតួលេខឆ្នាំ២០០៥ ដោយបានរួមចំណែករកចំណូលជាតិជារូបិយប័ណ្ណបរទេសបានប្រមាណ ១.០៤៩ លានដុល្លារអាមេរិក និងបានបង្កើតការងារប្រមាណ ២៥០.០០០កន្លែង ។

២.៤៣ បញ្ហាប្រឈមសំខាន់ៗមួយចំនួន នៅក្នុងចំណោមបញ្ហាប្រឈមជាច្រើនដែលមានចំពោះមុខក្នុងវិស័យទេសចរណ៍ មានដូចជា ការបន្តធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធដែលតភ្ជាប់ទៅតំបន់ទេសចរណ៍សំខាន់ៗ ការពង្រឹងវិធានការផ្សព្វផ្សាយនិងក្របខ័ណ្ឌច្បាប់សម្រាប់គ្រប់គ្រងសេវាទេសចរណ៍ ការទាក់ទាញភ្ញៀវទេសចរឱ្យទៅទស្សនាតំបន់ទេសចរណ៍ប្លែកៗជាច្រើនថែមទៀត (រួមទាំងអេកូទេសចរណ៍) ព្រោះថាឥឡូវនេះភ្ញៀវទេសចរណ៍ភាគច្រើនបានប្រមូលផ្តុំនៅតែខេត្តសៀមរាប (ការបើកឱ្យប្រើប្រាស់នាពេលថ្មីៗនេះ នូវអាកាសយានដ្ឋានក្រុងព្រះសីហនុដែលទើបតែត្រូវបានកែលម្អ គឺជាជំហានមួយនៃទិសដៅនេះ) ព្រមទាំង ការដោះស្រាយបានប្រសើរជាងមុននូវបញ្ហាបែងចែកផលប្រយោជន៍នៃទេសចរណ៍ ឱ្យទៅដល់ក្រុមហ៊ុននិងអ្នកផ្គត់ផ្គង់ទំនិញនិងសេវាកម្មក្នុងស្រុក ជាជាងទុកឱ្យចំណូលទាំងមូល ត្រូវបញ្ជូនត្រឡប់ទៅប្រទេសដើមវិញ ឬត្រូវយកទៅប្រើប្រាស់ ដើម្បីទិញទំនិញពីខាងក្រៅប្រទេស ។

២.៤៤ ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គមសម្រាប់កម្មករ : ការធ្វើអន្តរាគមន៍ក្នុងវិស័យសង្គមកិច្ចដោយមានការកំណត់គោលដៅច្បាស់លាស់ គឺមានសារៈសំខាន់ណាស់ ក្នុងការផ្ដល់នូវប្រព័ន្ធសុវត្ថិភាពសង្គមដល់ក្រុមជនដែលងាយរងគ្រោះភាគច្រើន ។ ការអភិវឌ្ឍសំខាន់ៗ នៅក្នុងឆ្នាំ២០០៦ រួមមាន :

- ចំនួនជនអនាថាគ្មានទីជម្រក ត្រូវបានកាត់បន្ថយបានចំនួន ១.៤០០នាក់ ។ វិធានការសមស្របជាច្រើន ត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីជួយសម្រាលភាពទុរគតរបស់អ្នកដែលគ្មានទីជម្រក និងបន្ថយការហូរចូលមកនៅក្នុងតំបន់ទីប្រជុំជនរបស់អ្នកទាំងនោះ ។ ជាមួយនឹងការបង្កើតមជ្ឈមណ្ឌលសម្រាប់ជនរងគ្រោះដោយការជួញដូរ ការងារនីតិសម្បទានិងសេវាអប់រំផ្នែកថែទាំសុខភាព ត្រូវបានផ្ដល់ជូនដោយគ្មានការរើសអើង ដល់កម្មករនិងជនរងគ្រោះ ដោយសារអំពើជួញដូរផ្លូវភេទ ។
- កុមារ-យុវកុមារដែលប៉ះពាល់ផ្លូវច្បាប់និងកុមារញៀនគ្រឿងញៀនចំនួន ១.៩៨៥នាក់ អ្នកប្រើប្រាស់គ្រឿងញៀនចំនួន ១.២៣៨នាក់ និងកុមារអនាថា និងកុមារដើរសុំទានចំនួន ៦៩៣នាក់ ត្រូវបានប្រមូលផ្ដុំ និងផ្ដល់ជូននូវសេវាសុខភាព អប់រំសីលធម៌ និងបណ្ដុះបណ្ដាលជំនាញ ហើយត្រូវបានធ្វើសមាហរណកម្មទៅក្នុងសហគមន៍វិញ ។ កម្ពុជាបានក្លាយជាប្រទេសមួយ ដែលអនុវត្តតាមអនុសញ្ញាទីក្រុងឡាអេស្ដីពី ការសុំកូនអន្តរប្រទេស ។
- សេចក្ដីព្រាងច្បាប់ស្ដីពីសិទ្ធិជនពិការ ត្រូវបានធ្វើជូនទៅរដ្ឋសភារួចហើយ ដើម្បីសុំការអនុម័ត ។
- របបធានារ៉ាប់រងសង្គមរបស់អតីតមន្ត្រីរាជការ ត្រូវបានរៀបចំឡើង និងបន្តធ្វើការកែសម្រួល ឱ្យស្របទៅតាមការអភិវឌ្ឍសេដ្ឋកិច្ចជាតិ តាមរយៈអនុក្រឹត្យរបស់រាជរដ្ឋាភិបាល ។ អនុក្រឹត្យរបស់រាជរដ្ឋាភិបាលស្ដីពី **បេឡាជាតិសន្តិសុខសង្គម**សម្រាប់មន្ត្រីរាជការ កំពុងត្រូវបានរៀបចំឡើង ដែលជាផ្នែកមួយនៃការលើកកម្ពស់សុខុមាលភាពដមន្ត្រីរាជការដែលចូលនិវត្តន៍ ។

### ចតុកោណទី៤ : ការកសាងសមត្ថភាព និង ការអភិវឌ្ឍធនធានមនុស្ស

២.៤៥ ចតុកោណកំណើនចុងក្រោយរបស់យុទ្ធសាស្ត្រចតុកោណ គ្របដណ្ដប់យ៉ាងច្រើនទៅវិស័យសង្គមកិច្ច ដូចជា អប់រំ សុខាភិបាល សមភាពយេនឌ័រ និងបញ្ហាប្រជាជន ។

២.៤៦ ការអប់រំ : ការអប់រំជាកត្តាចាំបាច់ក្នុងការអភិវឌ្ឍធនធានមនុស្ស និងជាសមាសធាតុសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ។ យុទ្ធសាស្ត្រនិងអាទិភាពសម្រាប់ការដោះស្រាយបញ្ហានៅក្នុងវិស័យអប់រំ ត្រូវបានលើកឡើងនៅក្នុង*ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៦-២០១០* ។ ស្ថានភាពរីកចម្រើនរបស់វិស័យអប់រំក្នុងឆ្នាំសិក្សា២០០៥-២០០៦ បានឆ្លុះបញ្ចាំងឱ្យឃើញ ពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តការងារអាទិភាពទាំងឡាយនៃកម្មវិធីកំណែទម្រង់អប់រំ ដូចដែលបានកំណត់នៅក្នុង*ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៦-២០១០* និង*កម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ ២០០៦-២០១០* សំដៅសម្រេចឱ្យបាន*ផែនការជាតិអប់រំ*

*សម្រាប់ទាំងអស់គ្នា ឆ្នាំ២០០៣-២០១៥* ។ ក្នុងរយៈពេលកន្លងមកថ្មីៗនេះ ការងារអប់រំមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយបានប្រែក្លាយអាទិភាពចម្បងៗរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំឱ្យ ទៅជាការជាក់ស្តែង ជាពិសេស ការបង្កើនចំនួនសាលាបឋមសិក្សានិងសាលាមធ្យមសិក្សាបឋមភូមិ ការបង្កើនការចូលរៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ (ដែលជួយឱ្យសិស្សរៀនចប់ការអប់រំកម្រិតមូលដ្ឋាន-ថ្នាក់ទី៩) និងការបង្កើនអត្រាអក្ខរកម្មរបស់ជនពេញវ័យ (អាយុពី១៥ ទៅ ២៤ឆ្នាំ) ជាដើម ។ ទោះជាដូចនេះក្តី គម្លាតក្នុងការផ្តល់សម្ភារៈរូបវ័ន្តអប់រំត្រូវបានទទួលស្គាល់ថា នៅបន្តមាននៅក្នុងការផ្តល់សេវាអប់រំដល់កុមារមកពីគ្រួសារក្រីក្រ និងគ្រួសាររស់នៅតំបន់ដាច់ស្រយាល ។ តារាង ២.៤ នឹងបង្ហាញពីទិន្នន័យចុងក្រោយបំផុត ក្នុងវិស័យអប់រំ ។

២.៤៧ ការប្រែប្រួលសំខាន់ ក្នុងឆ្នាំ២០០៦ រួមមាន :

- ចំនួនសាលាបឋមសិក្សា បានការកើនឡើងពី ៦.១៨០សាលា ក្នុងឆ្នាំសិក្សា២០០៤-២០០៥ ដល់ ៦.២៧៧សាលា ក្នុងឆ្នាំសិក្សា២០០៥-២០០៦ ហើយសាលាមធ្យមសិក្សាបឋមភូមិ បានកើនឡើងពី ៨០០សាលា ដល់ ៩១១សាលា ក្នុងរយៈពេលដូចគ្នា ។
- ដើម្បីកាត់បន្ថយគម្លាតក្នុងការទទួលសេវាអប់រំចំពោះកុមារមកពី គ្រួសារក្រីក្រនិងគ្រួសាររស់នៅតំបន់ដាច់ស្រយាល សាលាបឋមសិក្សាថ្មីៗត្រូវបានសាងសង់បន្ថែម ។ ក្នុងឆ្នាំសិក្សា២០០៥-២០០៦ សាលាបឋមសិក្សានៅតំបន់ដាច់ស្រយាលមានចំនួន ៥១៣សាលា ដោយមានការកើនឡើងចំនួន ១៩៥សាលា បន្ថែមពីលើចំនួនសាលាក្នុងឆ្នាំ២០០០ ដែលមានតែ៣១៨តែប៉ុណ្ណោះ ។ អត្រាពិតនៃការសិក្សានៅតំបន់ដាច់ស្រយាលបានកើនឡើងពី ៨២.៥ភាគរយនៅឆ្នាំ២០០៤-២០០៥ ដល់ ៨៣.៧ ភាគរយ នៅឆ្នាំ២០០៥-២០០៦ ។
- លទ្ធភាពទទួលបានប្រកបដោយសមធម៌នូវសេវាអប់រំសាធារណៈ និងគុណភាពនៃសេវាអប់រំសាធារណៈ នៅតំបន់ទីក្រុងនិងតំបន់ជនបទ ក៏ត្រូវបានបង្កើនផងដែរ សម្រាប់កុមារានិងកុមារី ។
- ការអប់រំនៅកម្រិតមធ្យមសិក្សាបឋមភូមិមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ជាពិសេស ការកើនឡើងនៃចំនួនសាលាមធ្យមសិក្សាបឋមភូមិ និងអត្រាពិតនៃការសិក្សា (សូមមើលសូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗ និងតារាង ២.៤) ។
- អត្រាអក្ខរកម្មជនពេញវ័យ (អាយុពី ១៥ ទៅ ២៤ឆ្នាំ) បានកើនឡើងពី ៨៣.៤ភាគរយ នៅឆ្នាំ ២០០៥ ដល់ ៨៤.៧ភាគរយ នៅឆ្នាំ២០០៦ ។
- អត្រាឆ្លងភូមិសិក្សាពីមធ្យមសិក្សាបឋមភូមិទៅមធ្យមសិក្សាទុតិយភូមិស្មើនឹង ៦៧.៤ភាគរយ ។ អត្រានេះខ្ពស់ជាងចំណុចដៅគ្រោងទុក ដែលស្មើនឹង ៦៤.០ភាគរយតែប៉ុណ្ណោះ ជាពិសេស អត្រាឆ្លងភូមិសិក្សាពីមធ្យមសិក្សាបឋមភូមិទៅមធ្យមសិក្សាទុតិយភូមិរបស់សិស្សស្រី ស្មើនឹង ៦៨.៣ ភាគរយ (ខ្ពស់ជាងចំណុចដៅគ្រោងទុក ដែលមានតែ ៦៦.០ភាគរយប៉ុណ្ណោះ) ។

- អត្រាពិតនៃការសិក្សានៅកម្រិតបឋមសិក្សា (គិតតាមភេទនិងតំបន់) អត្រាគង់វង្សពីថ្នាក់ទី១-៦ និងពីថ្នាក់ទី១-៩ មានការថយចុះ ។ ប៉ុន្តែ បើយើងធ្វើការប្រៀបធៀបរវាងឆ្នាំសិក្សា២០០៤-២០០៥ និងឆ្នាំសិក្សា២០០៥-២០០៦ អត្រារួមនៃការសិក្សានៅបឋមសិក្សា បានកើនឡើងពី ១១៩,៧ ភាគរយ ដល់ ១២៤ភាគរយ ។ ចំណុចនេះបានបង្ហាញថា កុមារកាន់តែច្រើនឡើងបានទទួលការអប់រំ ប៉ុន្តែ ពួកគេភាគច្រើនជាកុមារលើសអាយុក្នុងវ័យសិក្សា ។ និន្នាការកើនឡើងនេះអាចបណ្តាលមកពី (១) កុមារលើសអាយុក្នុងវ័យសិក្សាកាន់តែច្រើនជាងមុន ចូលរៀននៅថ្នាក់ទី១ (ការសង្កេតក្នុងរយៈពេលប្រាំឆ្នាំកន្លងទៅ បានបង្ហាញថា បាតុភូតនេះមាននិន្នាការកើនឡើងក្នុងកម្រិតខ្ពស់ គឺនៅក្នុងកម្រិតប្រហែលពី ៣០ ទៅ ៦០ភាគរយ) និង (២) អត្រាត្រួតថ្នាក់ខ្ពស់ ដែលនាំឱ្យមានការកើនឡើងនៃកុមារលើសអាយុក្នុងវ័យសិក្សា ។
- អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិស្មើនឹង ៨០,៦ភាគរយ ។ អត្រានេះទាបជាងចំណុចដៅដែលបានកំណត់ដល់ទៅ ៨៧,០ភាគរយ ជាពិសេស អត្រាឆ្លងភូមិសិក្សាសម្រាប់សិស្សស្រីដែលស្មើនឹង ៧៨,៧ភាគរយ (ចំណុចដៅ ៨៥,០ភាគរយ) ។
- ដើម្បីអនុវត្តឱ្យបានសម្រេចនូវយុទ្ធសាស្ត្ររយៈពេលវែងរបស់វិស័យអប់រំ ការវិនិយោគនិងកិច្ចខិតខំប្រឹងប្រែងនានា ត្រូវបានអនុវត្តជាបន្ត ក្នុងការធានាឱ្យមានវឌ្ឍនភាពនៅក្នុងផ្នែកឧត្តមសិក្សា និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ការចូលរៀននៅឧត្តមសិក្សាត្រូវបានកែលំអឱ្យកាន់តែមានសមធម៌តាមរយៈការបង្កើនចំនួនអាហារូបករណ៍ដល់និស្សិតពូកែ និស្សិតក្រីក្រ និស្សិតមកពីតំបន់ដាច់ស្រយាល និងនិស្សិតស្រី ។ នៅក្នុងឆ្នាំ២០០៦ អន្តេវាសិកដ្ឋានចំនួន ៤កន្លែងបាន សាងសង់រួចរាល់ ដែលអាចទទួលនិស្សិតស្នាក់នៅបានចំនួន ៥០០នាក់ ជាពិសេសសម្រាប់និស្សិតស្រី ។ ទោះជាដូចនេះក្តី យន្តការក្នុងការគ្រប់គ្រងនិងវាយតម្លៃគុណភាពអប់រំឧត្តមសិក្សា នៅមិនទាន់បានអនុវត្តនៅឡើយ ដែលទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងជាបន្តទៀត ។
- កម្មវិធីសិក្សានិងស្តង់ដារនៃការសិក្សាថ្នាក់ជាតិត្រូវបានអនុម័តជាផ្លូវការនៅក្នុងឆ្នាំ២០០៦ ។ ការចាប់ផ្តើមធ្វើការបណ្តុះបណ្តាលនិងវិក្រឹត្យការគ្រូបង្រៀនកម្រិតអប់រំមូលដ្ឋាន ស្តីពីកម្មវិធីសិក្សាថ្មីនេះ កំពុងតែអនុវត្តនៅទូទាំងប្រទេស ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏បានផ្តោតការយកចិត្តទុកដាក់លើដំណើរការវាយតម្លៃការបំពេញការងារនៅតាមសាលារៀន និងកំពុងកសាងសមត្ថភាពក្នុងការវាយតម្លៃការសិក្សារបស់និស្សិតនៅឧត្តមសិក្សា ក្នុងគោលបំណងផ្តល់នូវការអប់រំប្រកបដោយគុណភាព ដើម្បីធានាឱ្យមានកម្លាំងពលកម្មមួយ ដែលមានការអប់រំនិងការបណ្តុះបណ្តាលល្អប្រសើរជាមុន ។

## តារាង ២.៤ : វិស័យអប់រំ : គោលដៅ និងចំណុចដៅអាទិភាព

| គោលដៅនិងចំណុចដៅ | | ២០០៥ | ២០០៦ | ២០១០ (ចំណុចដៅ) | ២០១៥ (ចំណុចដៅ) |
|---|---|---|---|---|---|
| ១ | អត្រាពិតនៃការសិក្សានៅសាលាបឋមសិក្សា (១-៦) : សរុប | ៩១.៩ | ៩១.៣ | ១០០ | ១០០ |
| | ប្រុស | ៩៣.០ | ៩៣.០ | ១០០ | ១០០ |
| | ស្រី | ៩០.៧ | ៨៩.៧ | ១០០ | ១០០ |
| ២ | អត្រាពិតនៃការសិក្សានៅសាលាមធ្យមសិក្សាបឋមភូមិ (៧-៩) :សរុប | ២៦.១ | ៣១.៣ | ៧៥ | ១០០ |
| | ប្រុស | ២៧.១ | ៣២.១ | ៧៥ | ១០០ |
| | ស្រី | ២៤.៨ | ៣០.៤ | ៧៥ | ១០០ |
| ៣ | អត្រាគង់វង្សសិស្សថ្នាក់ទី១-ទី៦ | ៥៣.១ | ៤៨.២ | ១០០ | ១០០ |
| ៤ | អត្រាគង់វង្សសិស្សថ្នាក់ទី១-ទី៩ | ២៩.៣ | ២៦.៥ | ៥០ | ១០០ |
| ៥ | អត្រាអក្ខរជនអាយុ ១៥-២៤ឆ្នាំ | ៨៣.៤ | ៨៤.៧ | ៩៥ | ១០០ |

២.៤៨ គោលដៅនិងអាទិភាពនានា ដែលបានកំណត់នៅក្នុង*ផយអជ* សម្រាប់វិស័យអប់រំ នៅតែបន្តមានសុពលភាព ហើយនឹងអាចសម្រេចបានតាមរយៈផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៦-២០១០ ។ ក្នុងឋានៈជាវិស័យអាទិភាពមួយ នៅក្នុងកំណែទម្រង់*ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ* ការធ្វើវិភាជន៍និងប្រើប្រាស់ថវិកាជាតិ បានកើនឡើង ទាំងបរិមាណ ទាំងសមាមាត្រធៀបនឹងបរិមាណថ្នាក់ជាតិសរុប ។

២.៤៩ សុខាភិបាល : អង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០០៥ គឺជាការសិក្សាតំណាងឱ្យសង្គមជាតិទាំងមូល ដែលត្រូវបានរៀបចំឡើង ដោយយោងទៅតាមស្តង់ដារជាក់លាក់របស់អន្តរជាតិ ។ គោលបំណងនៃការអង្កេតនេះ គឺដើម្បីផ្តល់នូវទិន្នន័យដែលបានធ្វើបច្ចុប្បន្នភាពនិងអាចជឿជាក់បាន ស្តីពី ភាពបង្កើតកូន ផែនការគ្រួសារ មរណៈភាពមាតានិងទារក អាហារូបត្ថម្ភ ជម្ងឺគ្រុនចាញ់ ចំណេះដឹងពីហ៊ីវ/អេដស៍ ប្រេវ៉ាឡង់នៃមេរោគហ៊ីវ ស្ថានភាពស្ត្រី និងអំពើហិង្សាក្នុងគ្រួសារ ។ ការអង្កេតនេះ ក៏ជាការអង្កេតទី១ផងដែរនៅកម្ពុជា ដែលបានផ្តល់នូវការប៉ាន់ស្មានប្រេវ៉ាឡង់ហ៊ីវដោយផ្អែកជាមូលដ្ឋានលើប្រជាជន ។ លទ្ធផលនៃការអង្កេតនេះ (ដែលបានធ្វើការផ្សព្វផ្សាយដំបូងនៅចុងឆមាសទី២ ឆ្នាំ២០០៧) បានធ្វើបច្ចុប្បន្នភាព និង/ឬកែប្រែទិន្នន័យមូលដ្ឋានឆ្នាំ២០០៥ សម្រាប់សូចនាករសុខភាពសំខាន់ៗ ដែលបានប៉ាន់ស្មាននៅក្នុងពេលរៀបចំ *ផយអជ* ។ តារាង ២.៥ ខាងក្រោម បង្ហាញពីទិន្នន័យចុងក្រោយបំផុត ក្នុងវិស័យសុខាភិបាល :

### តារាង ២.៥ : វិស័យសុខាភិបាល : គោលដៅនិងចំណុចដៅអាទិភាព

| | ចំណុចដៅ និងសូចនាករ | ២០០៥ (ប៉ាន់ស្មាន) | ២០០៥ (អង្កេត[១]) | ២០១០ (ចំណុចដៅ) | ២០១៥ (ចំណុចដៅ) |
|---|---|---|---|---|---|
| ១ | អត្រាមរណៈភាពទារក ក្នុង ១.០០០កំណើតរស់ | ៦៦ | ៦៦ | ៦០ | ៥០ |
| ២ | អត្រាមរណៈភាពកុមារក្រោមអាយុ ៥ឆ្នាំ ក្នុង ១.០០០ កំណើតរស់ | ៨២ | ៨៣ | ៧៥ | ៦៥ |
| ៣ | ផលធៀបមរណៈភាពមាតា ក្នុង ១០០.០០០កំណើតរស់ | ពុំមានតួលេខ | ៤៧២ | ២៤៣ | ១៤០ |
| ៤ | អត្រាយុវជនដែលផ្ទុកមេរោគហ៊ីវ/អេដស៍ (%យុវជនអាយុ១៥-៤៩) | ១,៩ | ០,៦ | ០,៥ | ០,៥ |
| ៥ | ជម្ងឺគ្រុនចាញ់ : អត្រាស្លាប់ (%) | ០,៣៦ | ០,៣៩ | ០,២៥ | ០,១ |
| ៦ | ប្រេវ៉ាឡង់ជម្ងឺរបេងក្នុងចំណោមអ្នកពិនិត្យសួត ១០០.០០០នាក់ | ពុំមានតួលេខ | ២៦៩ | ២១៤ | ១៣៥ |

**កំណត់សម្គាល់** :ប្រេវ៉ាឡង់ជម្ងឺរបេងក្នុងចំណោមអ្នកពិនិត្យសួត ១០០.០០០នាក់ = ២៦៩ (អង្កេតថ្នាក់ជាតិពីប្រេវ៉ាឡង់ជម្ងឺរបេង នៅកម្ពុជា ២០០២)

២.៥០ អង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០០៥ កត់សម្គាល់ថា ទន្ទឹមនឹងពេលដែលមានការប្រែប្រួលរវាងតំបន់ទីក្រុងនិងតំបន់ជនបទឬដាច់ស្រយាល ការប្រែប្រួលជាមធ្យមសម្រាប់កម្រិតជាតិទាំងមូល រួមមាន :

- អត្រាមរណៈភាពកុមារមានការថយចុះគួរឱ្យកត់សម្គាល់ ក្នុងនោះ មរណៈភាពទារកបានថយចុះ ៣០ ភាគរយ គិតចាប់តាំងពីឆ្នាំ២០០០ មក ។
- ២/៣នៃកុមារដែលមានអាយុពី ១២ ដល់ ២៣ខែ បានទទួលការចាក់ថ្នាំបង្ការ តាមការណែនាំ ។
- ៦៦ភាគរយនៃស្ត្រី បានទទួលសេវាថៃទាំមុនពេលសម្រាល ប្រៀបធៀបនឹងឆ្នាំ២០០០ ដែលមានតែ ៣៨ភាគរយ ប៉ុណ្ណោះ ។
- ៤៤ភាគរយនៃការសម្រាលកូន ត្រូវបានធ្វើឡើងដោយមន្ត្រីសុខាភិបាលដែលបានទទួលការបណ្តុះបណ្តាល ដោយបានកើនឡើងពី ៣៣ភាគរយ នៅក្នុងឆ្នាំ២០០០ ។
- អត្រាប្រេវ៉ាឡង់ហ៊ីវ មានត្រឹមតែកម្រិត ០,៦ភាគរយប៉ុណ្ណោះ គឺប្រហែល ១/៣នៃការប៉ាន់ស្មានសម្រាប់ឆ្នាំ២០០៥ ដែលបានធ្វើឱ្យកម្ពុជាស្ថិតនៅក្នុងចំណោមប្រទេសមួយចំនួនតូចក្នុងពិភពលោកដែលអាចសម្រេចបានគោលដៅនៅឆ្នាំ២០០៥ ។
- ផលធៀបមរណៈភាពមាតា ពុំមានការប្រែប្រួលគួរឱ្យកត់សម្គាល់ទេ បើប្រៀបធៀបនឹងតួលេខរបស់អង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០០០ ។

២.៥១ ការអភិវឌ្ឍសំខាន់ៗមួយចំនួន នៅក្នុងចំណោមការអភិវឌ្ឍជាច្រើននៅក្នុងឆ្នាំ២០០៦ មានដូចតទៅ : ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល (២០០៣-២០០៧) កំពុងត្រូវបានអនុវត្តដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទជាមួយគ្រប់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ។ ការអនុវត្តសំណុំសកម្មភាពអប្បបរមាបានដំណើរការល្អ ។ ចំនួនមជ្ឈមណ្ឌលសុខភាពដែលផ្តល់សំណុំសកម្មភាពអប្បបរមាពេញលេញ បានកើនឡើងដល់ ៤៣៩ ក្នុងឆ្នាំ

[១] អង្កេតប្រជាសាស្ត្រនិងសុខភាព ឆ្នាំ២០០៥

២០០៦ ។ ចំនួនមន្ទីរពេទ្យបង្អែកដែលមានសំណុំសកម្មភាពបន្ថែម បានកើនឡើង ហើយមូលនិធិសមធមិសម្រាប់អ្នកជម្ងឺក្រីក្រ បច្ចុប្បន្ននេះ កំពុងត្រូវបានផ្ដល់ឱ្យដល់ស្រុកចំនួន ២៥ ដែលបានកើនឡើងពី ១៧ស្រុកនៅឆ្នាំ២០០៤ ។ ករណីជម្ងឺគ្រុនចាញ់ដែលបាន ព្យាបាលនៅមណ្ឌលសុខភាពសាធារណៈ បានថយចុះពី ៧,៣ភាគពាន់ក្នុងឆ្នាំ២០០៥ មកត្រឹម ៥,១ ក្នុងឆ្នាំ២០០៦ ។ ការធ្វើវិភាជន៍ថវិកា និងការផ្ដល់ថវិកាសម្រាប់ចំណាយ សម្រាប់វិស័យសុខាភិបាល មានការកើនឡើង និងមានស្ថេរភាព ។ អង្គការក្រៅរដ្ឋាភិបាលប្រមាណ ១៣០ បានរួមចំណែកក្នុងការគាំទ្រដល់វិស័យសុខាភិបាល ហើយភាគច្រើនក្នុងចំណោមនោះ បានធ្វើប្រតិបត្តិការនៅក្នុងតំបន់ដាច់ស្រយាល ។

២.៥២ រាជរដ្ឋាភិបាលកម្ពុជាបានផ្ដល់អាទិភាព ទៅលើការជំរុញឱ្យមាន សុខភាពនិងអាហារូបត្ថម្ភល្អ និងការបង្ការល្អ ការរកឃើញនិងការព្យាបាលជម្ងឺទាំងឡាយទាន់ពេលវេលានៅក្នុងចំណោមប្រជាជនដែលជាមធ្យោបាយមួយនៃការអភិវឌ្ឍធនធានមនុស្ស ដែលទាំងអស់នេះ គឺជាប្រការចាំបាច់ណាស់សម្រាប់វឌ្ឍនភាពប្រកបដោយចិរភាពនៅក្នុងវិស័យផ្សេងទៀត ។ គោលដៅនិងអាទិភាពទាំងឡាយដែលបានកំណត់ក្នុង*ផយអជ* សម្រាប់វិស័យសុខាភិបាលនៅបន្តតែមានសុពលភាព ហើយនឹងត្រូវបានអនុវត្តយ៉ាងយកចិត្តទុកដាក់ តាមរយៈ ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល២០០៣-២០០៧ ។ ការធ្វើវិភាជន៍ថវិកាជាតិ នឹងបន្តកើនឡើង ទាំងបរិមាណ ទាំងសមាមាត្រធៀបនឹងទំហំសរុប នៅក្នុងក្របខ័ណ្ឌនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

២.៥៣ មេរោគហ៊ីវ/ជម្ងឺអេដស៍ : ក្រៅពីបង្ហាញឱ្យឃើញថា ការឆ្លងមេរោគហ៊ីវ/អេដស៍ បានធ្លាក់ចុះទាបជាងឆ្ងាយពីកម្រិតដែលបានប៉ាន់ស្មានដំបូង (ធ្លាក់ចុះពី១,៩ភាគរយ ដល់ ០,៦ភាគរយ ចំពោះក្រុមអាយុពី ១៥-៤៩ឆ្នាំ) អង្កេតសុខភាពនិងប្រជាសាស្ត្រកម្ពុជា ក៏បានបង្ហាញផងដែរថា ការគាំទ្រកម្មវិធីអប់រំ និងជំរុញលើកទឹកចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា បានទទួលលទ្ធផលគួរជាទីមោទនៈ ឧទាហរណ៍ ការយល់ដឹងពីហ៊ីវ/អេដស៍ ក្នុងចំណោមប្រជាជនមានកម្រិតខ្ពស់ខ្លាំង ហើយជាង ៨០ភាគរយនៃបុរសនិងស្ត្រីក្នុងក្រុមអាយុពី១៥-៤៩ឆ្នាំ យល់ដឹងពីវិធីសាស្ត្រចម្បងបី សម្រាប់ការការពារការឆ្លងនៃមេរោគហ៊ីវ ។ កម្មវិធីជាច្រើនពាក់ព័ន្ធនឹងមេរោគហ៊ីវ/ជម្ងឺអេដស៍ដែលមានការបញ្ចូលចម្រុះគ្នាយ៉ាងល្អប្រសើរនូវវិធានការជាច្រើនសម្រាប់ ការបង្កើតការយល់ដឹង ការការពារ ការធ្វើតេស្ត សេវាគាំទ្រនិងលើកទឹកចិត្ត និងការផ្ដល់នូវសំភារៈបរិក្ខារ ដែលត្រូវការកិច្ចសហការល្អពីអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ នឹងត្រូវបន្តអនុវត្ត ។

២.៥៤ សមធមិយេនឌ័រ : អតុល្យភាពយេនឌ័រ និងការលើកកម្ពស់ដោយយកចិត្តទុកដាក់ចំពោះសិទ្ធិស្ត្រីនិងស្ថានភាពស្មើគ្នានៅក្នុងគ្រប់ផ្នែកទាំងអស់នៃការអភិវឌ្ឍ គឺជាបញ្ហាយ៉ាងសំខាន់ នៅក្នុងកម្មវិធីការងារសម្រាប់វឌ្ឍនភាពនៅប្រទេសកម្ពុជា តាមរយៈការប្រឹងប្រែងនិងការអនុវត្តផែនការយុទ្ធសាស្ត្រសម្រាប់ស្ត្រី មានឈ្មោះថា *នារីរតនៈ* ដែលគ្របដណ្ដប់គ្រប់ វិស័យទាំងអស់ ។

២.៥៥ ក្នុងឆ្នាំ២០០៦ ទន្ទឹមនឹង ការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លា ដើម្បីជំរុញការបញ្ជ្រាបយេនឌ័រទៅក្នុងគ្រប់មជ្ឈដ្ឋាននៃសង្គមកម្ពុជា រួមទាំង នៅក្នុងគោលនយោបាយនិងកម្មវិធីជាតិនានា ផែនការតាមវិស័យ និងការរៀបចំផែនការនិងថវិកាសម្រាប់ការអភិវឌ្ឍសហគមន៍ ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ និងកិច្ចខិតខំប្រឹងប្រែងផ្សេងៗទៀត ដើម្បីការលើកកម្ពស់សិទ្ធិនិងតួនាទីរបស់ស្ត្រីនៅកម្ពុជា នឹងត្រូវបន្តអនុវត្ត ដោយយកចិត្តទុកដាក់ ។ សមត្ថភាពជាតិក្នុងការវិភាគពីសមធមិយេនឌ័រ នៅមានកម្រិតនៅឡើយ ។ បញ្ហានេះ ទាមទារឱ្យមានការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ និងកិច្ចសហប្រតិបត្តិការ យ៉ាងជិតស្និទ្ធ រវាងអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ ។ វឌ្ឍនភាពសំខាន់ៗនៅក្នុងឆ្នាំ២០០៦ រួមមាន :

- រហូតមកទល់សព្វថ្ងៃនេះ ក្រសួងចំនួន ៥ (ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសុខាភិបាល និងក្រសួងពតិមាន) បានរៀបចំបង្កើត *ផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ* របស់ខ្លួន ហើយក្រសួងចំនួន ៤ ក្នុងចំណោមនេះ (ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកសិកម្មរុក្ខា ប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ និង ក្រសួងសុខាភិបាល) បានចាប់ផ្តើមអនុវត្តផែនការនេះរួចហើយ ។
- កិច្ចខិតខំប្រឹងប្រែងជាច្រើន ត្រូវបានធ្វើជាបន្ត ដើម្បីបង្កើនកាលានុវត្តភាពក្នុងការរកចំណូលសម្រាប់ស្ត្រី តាមរយៈ ការបង្កើនឱកាសការងារ និងការគាំទ្រដល់សហគ្រាសធុនតូចនិងមធ្យមដោយស្ត្រី ។
- មជ្ឈមណ្ឌលជាច្រើនសម្រាប់ *ស្ត្រីក្នុងការអភិវឌ្ឍ* ត្រូវបានបង្កើតឡើងនៅក្នុងខេត្ត-ក្រុងនានា ។
- ផែនការសកម្មភាពមួយ ត្រូវបានរៀបចំឡើង ហើយនឹងត្រូវចាប់ផ្តើមអនុវត្ត ដោយអនុលោមតាមច្បាប់ស្តីពី *ការប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារនិងការការពារជនរងគ្រោះ* ដែលត្រូវបានអនុម័តកាលពីឆ្នាំ២០០៥ ។
- សេចក្តីព្រាងច្បាប់ស្តីពី*ការប្រឆាំងនឹងការជួញដូរស្ត្រីនិងក្មេងស្រី* កំពុងត្រូវបានពិនិត្យ ។ ច្បាប់នេះនឹងរៀបចំឱ្យបានស្របគ្នាជាមួយនឹងពិធីសាររបស់សហប្រជាជាតិ និងច្បាប់ព្រហ្មទណ្ឌជាតិ ។

២.៥៦ គោលនយោបាយជាតិប្រជាជនរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលរៀបចំបានគ្រប់ជ្រុងជ្រោយ មានទំនាក់ទំនងនឹងវិស័យជាច្រើន ដូចជា វិស័យសុខាភិបាល អប់រំ បរិស្ថាន ម៉ាក្រូសេដ្ឋកិច្ច យេនឌ័រ ចំណាកស្រុក យុវជន និងមនុស្សចាស់ និងវិស័យផ្សេងៗទៀត ។ រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងពង្រឹងសមត្ថភាពធនធានមនុស្សដល់អ្នករៀបចំផែនការ និងអ្នករៀបចំគោលនយោបាយនានា ដើម្បីបញ្ចូលបញ្ហានានាដែលទាក់ទងនឹងបញ្ហាប្រជាជនទៅក្នុងដំណើរការនៃការរៀបចំផែនការអភិវឌ្ឍន៍នៅគ្រប់កម្រិត ។ អង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០០៥ បានផ្តល់នូវទិន្នន័យបច្ចុប្បន្នភាពទាំងឡាយដែលបង្ហាញពីលទ្ធផលវិជ្ជមាននានា នៅក្នុងការអនុវត្តគោលនយោបាយជាតិនេះ ។ វឌ្ឍនភាពគួរឱ្យកត់សម្គាល់មួយចំនួន មានដូចខាងក្រោម :

- ស្ទើរតែគ្រប់ស្ត្រីទាំងអស់ បានស្គាល់និងដឹងពីវិធីសាស្ត្រពន្យារកំណើតមួយចំនួន ។ ស្ត្រីប្រមាណ ៤០ភាគរយនៃស្ត្រីដែលបានរៀបការ បាននិងកំពុងប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតមួយយ៉ាងតិច ក្នុងនោះ ២៧,២ភាគរយបានប្រើប្រាស់វិធិសាស្ត្រពន្យាកំណើតទំនើប ។
- ស្ត្រីអាយុពី១៥-៤៩ឆ្នាំ ចាប់ផ្តើមមានកូន ក្នុងអាយុមធ្យមកណ្តាល ២២ឆ្នាំ ។ ការមានផ្ទៃពោះក្នុងវ័យជំទង់ មានចំនួនតិចតួច គឺមានតែ ៨ភាគរយនៃស្ត្រីដែលមានអាយុពី ១៥-១៩ឆ្នាំប៉ុណ្ណោះដែលចាប់ផ្តើមមានផ្ទៃពោះ ។ អាយុមធ្យមកណ្តាលនៃការរៀបអាពាហ៍ពិពាហ៍ គឺ ២១ឆ្នាំសម្រាប់ស្ត្រី ។ នៅកម្ពុជា ចន្លោះពីកំណើតមួយទៅកំណើតមួយទៀត មានរយៈពេលវែងមធ្យម ។
- អត្រាបង្កើតកូនសរុបមានការថយចុះពី ៤,០កំណើតរស់ក្នុងស្ត្រីម្នាក់ នៅឆ្នាំ២០០០ មកត្រឹម ៣,៤កំណើតរស់ក្នុងស្ត្រីម្នាក់ នៅក្នុងឆ្នាំ២០០៥ ។ ចំនួនកូនមធ្យមដែលស្ត្រីម្នាក់ចង់បានស្មើនឹង ៣,៣នាក់ ។
- រចនាសម្ព័ន្ធអាយុនៃប្រជាជនកម្ពុជាក្នុងឆ្នាំ២០០៥ មានការផ្លាស់ប្តូរ បើប្រៀបធៀបនឹងរចនាសម្ព័ន្ធអាយុនៃប្រជាជនកម្ពុជាក្នុងឆ្នាំ២០០០ ។ តួលេខអង្កេតបានបង្ហាញថា ប្រជាជនដែលមានអាយុពី ១៥-៦៤ឆ្នាំមាន ៥៧ភាគរយ អាយុក្រោម ១៥ឆ្នាំមាន ៣៩ភាគរយ និងអាយុ ៦៥ឆ្នាំឡើងមានប្រហែល ៥ភាគរយ ។
- ទំហំគ្រួសារជាមធ្យមមានការថយចុះពី ៥,៤នាក់ ក្នុងឆ្នាំ២០០០ មកត្រឹម ៥នាក់ នៅក្នុងឆ្នាំ ២០០៥ ។
- កម្ពុជាមានប្រជាជនរស់ក្នុងបន្ទុកជាកុមារនិងយុវជនច្រើន ។ ទោះជាដូចនេះក្តី តាមរយៈការថយចុះនៃអត្រាភាពបង្កើតកូន សមាមាត្រនៃប្រជាជនដែលមានអាយុក្រោម ១៥ឆ្នាំ បានចាប់ផ្តើមថយចុះជាបណ្តើរៗ ។

# ជំពូកទី៣

## គោលដៅនិងចំណុចដៅអាទិភាព និង ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ

៣.០១ ដូចដែលបានបញ្ជាក់ក្នុង*ផយអជ* រាជរដ្ឋាភិបាលមានចក្ខុវិស័យយ៉ាងច្បាស់លាស់ សម្រាប់រយៈពេលវែង និងមានការប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការធ្វើឱ្យសម្រេចបាននូវកម្ពុជាមួយដែល មានការឯកភាពគ្នាក្នុងសង្គម មានការអប់រំចម្រើនជឿនលឿន មានវប្បធម៌ល្អរឹងមាំ គ្មានភាពក្រីក្រ គ្មានអនក្ខរភាព និងគ្មានសុខភាពអន់ថយ ដើម្បីឱ្យជនកម្ពុជាគ្រប់រូបអាចរស់នៅ ក្នុងភាពសុខដុម រួចផុតពីភាពអត់ឃ្លាន វិសមភាព ការដាក់ឱ្យនៅក្រៅសង្គម និងភាពងាយរងគ្រោះ ហើយដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបអាចឈានទៅសម្រេចបានយ៉ាងពេញលេញនូវសក្តានុពល ក្នុងការជ្រើសរើសមុខវិជ្ជាជីវៈ សំដៅចូលរួមចំណែកក្នុងការបន្តអភិវឌ្ឍប្រទេស និងការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនឱ្យកាន់តែប្រសើរឡើងថែមទៀត ។ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល គូសបញ្ជាក់យ៉ាងច្បាស់នូវកម្មវិធីជាបន្ទាន់ដូចតទៅ (១) ជំរុញឱ្យមានកំណើនសេដ្ឋកិច្ច (២) ការបង្កើតការងារសម្រាប់ពលករកម្ពុជាទាំងអស់ (៣) ការអនុវត្តកំណែទំរង់ដែលចាំបាច់ ដើម្បីធានាបាននូវសមធម៌និងយុត្តិធម៌សង្គម និង (៤) ការលើកកម្ពស់ប្រសិទ្ធភាពនៃកម្មវិធីកំណែទម្រង់ទាំងឡាយក្នុងវិស័យទាំងអស់ សំដៅការកាត់បន្ថយភាពក្រីក្រ និងការសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព ។ ក្នុងបរិបទនេះ *ផយអជ លើកឡើងអំពីជំហានការងារនិងគោលដៅបន្ទាន់និងរយៈពេលមធ្យម ដែលត្រូវធ្វើនៅពេលអនាគត* ដើម្បីឈានទៅសម្រេចបានយ៉ាងឆាប់រហ័សនូវចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជា ។

៣.០២ ការកាត់បន្ថយភាពក្រីក្រតាមរបៀបមួយដ៏ឆាប់តាមដែលអាចធ្វើបាន គឺជាអាទិភាពចម្បងបំផុតរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ដោយហេតុថា ៩០ភាគរយនៃប្រជាជនក្រីក្ររស់នៅតំបន់ជនបទ ការយកចិត្តទុកដាក់ជាអាទិភាព ចាំបាច់ត្រូវធ្វើឡើង តាមរយៈ*ផយអជ* ដើម្បីជំរុញល្បឿននៃការអភិវឌ្ឍនៅតំបន់ជនបទ ។ នៅក្នុងបរិបទនេះ ការសម្រេចបាននូវ*គអសក* ជាពិសេស ការកាត់បន្ថយភាពក្រីក្រនិងការអភិវឌ្ឍធនធានមនុស្ស គឺជាអាទិភាពខ្ពស់ ប៉ុន្តែ ប្រការទាំងនេះ ផ្អែកជាសំខាន់លើការផ្តុំគ្នានិងលទ្ធផលនៃកិច្ចអភិវឌ្ឍនិងស្ថានភាពជាច្រើនផ្សេងទៀត ដូចជា ស្ថេរភាពនយោបាយនិងសង្គម ការគ្រប់គ្រងដោយច្បាប់ ការថែរក្សាសណ្តាប់ធ្នាប់សាធារណៈ កំណែទម្រង់សំខាន់ៗក្នុងរដ្ឋបាលសាធារណៈនិងក្នុងបណ្តាវិស័យទាំងឡាយ ការលើកកម្ពស់សមធម៌យេនឌ័រ កំណើនម៉ាក្រូសេដ្ឋកិច្ចភាពដែលប្រកបដោយស្ថេរភាព ចីរភាព សន្ទុះខ្លាំង សមធម៌ តុល្យភាព និងដោយមានការបែងចែកល្អប្រសើរ (តាមតំបន់ភូមិសាស្ត្រនិងតាមវិស័យសេដ្ឋកិច្ច-សង្គមកិច្ច) ហើយដែលទាក់ទងនឹងគ្រប់វិស័យទាំងអស់ផ្សេងទៀត ដោយវិស័យនីមួយៗមានគោលដៅនិងចំណុចដៅផ្ទាល់របស់ខ្លួន ។ *ផយអជ* កំណត់យ៉ាងច្បាស់ថាវឌ្ឍនភាពចម្បងៗ នឹងមិនអាចកើតមានបាន ប្រសិនបើមិនមាន :

- កំណើនម៉ាក្រូសេដ្ឋកិច្ចប្រកបដោយសន្ទុះខ្លាំងក្លា និងសមធម៌ ។
- អតិផរណាដែលត្រូវបានរក្សាឱ្យស្ថិតនៅកម្រិតមួយ ដែលអាចគ្រប់គ្រងបាន ។
- ការកើនឡើងគួរឱ្យកត់សម្គាល់នូវផលិតភាពនិងផលិតកម្មកសិកម្ម ។
- ការការពារនិងការលើកកម្ពស់បរិស្ថាននិងធនធានធម្មជាតិ ។
- ការពង្រីកនិងពង្រឹងនូវ ការធ្វើឱ្យប្រសើរឡើងជាប្រចាំនូវហេដ្ឋារចនាសម្ព័ន្ធ ។
- កំណើនគួរឱ្យកត់សំគាល់នៃវិស័យឧស្សាហកម្ម ដែលបង្កើតការងារនិងប្រាក់ចំណូល ។
- កំណែទម្រង់សំខាន់ៗក្នុងផ្នែករដ្ឋបាលសាធារណៈ រួមទាំង កំណែទម្រង់ច្បាប់និងតុលាការ និង កំណែទម្រង់តាមវិស័យនានា ។
- កំណើនឆាប់រហ័សក្នុងការវិនិយោគរបស់ផ្នែកឯកជន នៅក្នុងវិស័យជាច្រើនខុសៗគ្នា ដើម្បីធ្វើឱ្យវឌ្ឍនភាព មានមូលដ្ឋានទូលំទូលាយ និងមានសន្ទុះខ្លាំងក្លា ដោយកាត់បន្ថយការចំណាយអន្តរកម្ម ដែលសព្វថ្ងៃនេះ រារាំងដល់ការវិនិយោគបែបនេះ និងដោយរៀបចំឱ្យមាននីតិវិធីសមស្រប ។
- កំណើនដែលគ្មានការរារាំងក្នុងពាណិជ្ជកម្មអន្តរជាតិ ដើម្បីសម្រួលការទាញយកប្រយោជន៍ពីឧត្តមភាពប្រៀបធៀបរបស់កម្ពុជាក្នុងការផ្គត់ផ្គង់ទំនិញនិងសេវាកម្មនៅលើទីផ្សារក្រៅប្រទេស ក្នុងលក្ខខណ្ឌប្រកួតប្រជែង ហើយបង្កើតឱ្យមានទំនាក់ទំនងទៅវិញទៅមករវាងភាពប្រសើរឡើងនៃពាណិជ្ជកម្មអន្តរជាតិនិងភាពមានការងារធ្វើនៅក្នុងវិស័យផ្សេងៗគ្នាជាច្រើន ដែលបង្កើតឱ្យមានប្រាក់ចំណូលពីប្រភពផ្សេងៗគ្នា ដូចជា ផលិតកម្ម ការកែច្នៃកសិផល ការវេចខ្ចប់ ការដឹកជញ្ជូន និងការលក់ដូរ ។
- កំណើនឆាប់រហ័សក្នុងវិស័យសេវាកម្ម (រួមទាំងទេសចរណ៍) ដើម្បីផ្តល់ការងារ និងចំណូល ។ល។

៣.០៣ *ផយអជ* បានពិនិត្យពិចារណា លើរាល់ទិដ្ឋភាពសំខាន់ៗនៃតម្រូវការសេដ្ឋកិច្ច-សង្គមកិច្ចរបស់កម្ពុជា លើអាទិភាព គោលដៅនិងចំណុចដៅ និង*គអសក* ដែលបញ្ចូលគ្នាជាមួយនឹងកត្តាជាច្រើនផ្សេងទៀត រួមទាំងបញ្ហាអន្តរវិស័យ ដើម្បីនាំប្រទេសកម្ពុជាឱ្យបានលឿនទៅមុខ នៅលើផ្លូវទៅកាន់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ចប្រកបដោយសមធម៌ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការកាត់បន្ថយភាពក្រីក្រ ក៏ដូចជា លើការកាត់បន្ថយឱ្យបានច្រើននូវភាពខុសគ្នាតាមតំបន់ និងរវាងអ្នកមាននិងអ្នកក្រ ។ ក្នុងនាមជាក្របខណ្ឌដ៏ទូលំទូលាយមួយ ដើម្បីតម្រង់ទិសដល់ដំណើរការអភិវឌ្ឍន៍*ផយអជ* បានកំណត់តែគោលដៅនិងចំណុចដៅជាអាទិភាព ដោយទុកឱ្យវិស័យនីមួយៗ ធ្វើការកំណត់គោលដៅ ចំណុចដៅ និងយុទ្ធសាស្រ្តលម្អិត នៅក្នុងផែនការនិងយុទ្ធសាស្រ្តតាមវិស័យរៀងៗខ្លួន ។ គោលដៅនិងចំណុចដៅសំខាន់ៗក្នុងតារាង ៣.២ នៃ*ផយអជ* សម្រាប់ការកាត់បន្ថយភាពក្រីក្រដែលជាអាទិភាពខ្ពស់បំផុត នឹងនៅតែបន្តមានសុពលភាព ។ តារាង ៣.១ ខាងក្រោម ត្រូវបានរៀបចំឡើងតាមលំនាំនៃតារាង ៣.២ នៃ*ផយអជ* ដោយមានការកែសម្រួលដែលបានធ្វើឡើង ដោយផ្អែកទៅតាមទិន្នន័យចុងក្រោយបំផុត ដែលមាននៅក្នុងឆ្នាំ២០០៥ និង ២០០៦ ។

៣.០៤ រាជរដ្ឋាភិបាលកម្ពុជា នៅតែរក្សាការប្តេជ្ញាចិត្តយ៉ាងមុតមាំ ដើម្បីឈានសម្រេចបានគោលដៅ និងចំណុចដៅរួមទាំងអស់ ដែលបានកំណត់ក្នុងតារាង ៣.១ ព្រមទាំងគោលដៅនិងចំណុចដៅទាំងឡាយ ដែលត្រូវបំបែកលម្អិតតាមកម្រិតវិស័យ និងថ្នាក់ក្រោមជាតិ ។ ចំណុចដៅមួយចំនួន ពិតជាមានលក្ខណៈមហិច្ឆិតាបន្តិចមែន ប៉ុន្តែរាជរដ្ឋាភិបាលមានការជឿជាក់ថា ចំណុចដៅទាំងនោះ នឹងត្រូវអាចសម្រេចបាន ប្រសិនបើធនធានអាចមានគ្រប់គ្រាន់និងត្រូវបានយកទៅប្រើប្រាស់សមស្រប សម្រាប់ការវិនិយោគនិងការអភិវឌ្ឍមនុស្ស ។ ដើម្បីសម្រេចបានជោគជ័យ រាជរដ្ឋាភិបាល នឹងត្រូវអនុវត្តឱ្យបានខ្លាំងក្លានូវរាល់យុទ្ធសាស្ត្រនិងសកម្មភាព ជាអាទិភាពតាមរយៈក្របខណ្ឌយុទ្ធសាស្ត្រចតុកោណ ដូចដែលបានលើកឡើងនៅក្នុងជំពូក៤ នៃ*ផយអជ* ។

## ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ

៣.០៥ ការតាមដានត្រួតពិនិត្យជាប្រចាំនិងទៀងទាត់ ពីការអនុវត្តនិងវឌ្ឍនភាពនៃ*ផយអជ* ត្រូវបានទទួលស្គាល់ថា ជាកត្តាគន្លឹះ[១] ដើម្បីធានាថាការតាមដានត្រួតពិនិត្យដែលសមាសធាតុមួយរបស់*ផយអជ* គឺជាប្រការចាំបាច់ ដើម្បីធានាថា ការអនុវត្ត*ផយអជ* ត្រូវបានធ្វើឡើងទៅតាមទិសដៅដែលចង់បាន និងទៅតាមល្បឿនដែលតម្រូវឱ្យមាន សំដៅធ្វើឱ្យសម្រេចបាននូវគោលដៅនិងចំណុចដៅដែលបានគ្រោងទុក ។

៣.០៦ ដើម្បីនឹងអនុវត្តជំពូកទី៤នៃ*ផយអជ* ដែលបានកំណត់ទិសដៅនិងដំណើរការ សម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ក្របខ័ណ្ឌនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃ*ផយអជ* មួយ ត្រូវបានរៀបចំឡើងហើយត្រូវបានទទួលការឯកភាពពីស្ថាប័នកណ្តាលទាំងបួន រួមមាន ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងគណៈកម្មាធិការទីតិសម្បទានិងអភិវឌ្ឍនឹកម្ពុជា ព្រមទាំងត្រូវបានអនុម័តយក (សូមមើល ឧបសម្ព័ន្ធ ២) ។ គោលបំណងនៃក្របខ័ណ្ឌនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃ*ផយអជ* គឺដើម្បីពិនិត្យមើលជារៀងរាល់ឆ្នាំ លើការប្រែប្រួលរបស់សូចនាករដែលអាចវាស់វែងចំនួន ២៦ ពីក្នុងចំណោមសូចនាករទាំង ៤៣ ដែលបានបង្ហាញនៅក្នុងតារាង ៣.២ នៃ*ផយអជ* (តារាង ៣.១ ខាងក្រោម) ជាពិសេស តាមរយៈទិន្នន័យដែលប្រមូលបានដោយប្រព័ន្ធរដ្ឋបាលដែលកំពុងដំណើការរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងដោយវិទ្យាស្ថានជាតិស្ថិតិ ឬក៏អាចបានមកពីការធ្វើអង្កេតនានា ។ អាស្រ័យហេតុនេះ ការធ្វើអង្កេតដោយឡែកៗសម្រាប់ការតាមដាន មិនចាំបាច់សម្រាប់គោលបំណងខាងលើនេះទេ ។ លើសពីនេះទៀត ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវបន្តប្រមូលទិន្នន័យសំខាន់ៗផ្សេងទៀតដែលទាក់ទងនឹងមុខងាររបស់ខ្លួន រួមទាំង ទិន្នន័យលម្អិតពាក់ព័ន្ធនឹង*គអសក* ហើយត្រូវផ្តល់ធាតុចូលសម្រាប់ការតាមដានត្រួតពិនិត្យ*ផយអជ* ដោយមានការវិភាគមួយលម្អិតនិង

[១] ជំពូកទី៦ នៃ *ផយអជ*

ច្បាស់លាស់ជាងមុន អំពីមូលហេតុនៃជោគជ័យនិងការមិនសម្រេចបាន សំដៅធ្វើឱ្យក្រសួង-ស្ថាប័នទាំងនោះ អាចធ្វើការជ្រើសរើសនិងសម្រេចចិត្តលើគោលនយោបាយ អាចរៀបចំផែនការនិងកម្មវិធីទាំងឡាយដែលនឹងត្រូវអនុវត្ត ព្រមទាំងអាចអនុវត្តសកម្មភាពរដ្ឋបាលផ្សេងៗទៀត ដើម្បីសម្រេចបាននូវគោលដៅនិងចំណុចដៅតាមវិស័យរបស់ក្រសួង-ស្ថាប័នទាំងនោះ ។ ក្របខ័ណ្ឌនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃ*ផយអជ* នឹងត្រូវពិនិត្យមើលឡើងវិញទៅតាមដំណាក់កាល ដើម្បីធានាឱ្យមានការកែសម្រួល ដោយផ្អែកលើមូលដ្ឋាននៃបទពិសោធន៍ដែលទទួលបាន ។

៣.០៧ ទិន្នន័យរដ្ឋបាលត្រូវប្រមូលនៅតាមកម្រិតផ្សេងៗគ្នាជាច្រើន ក្នុងនោះរួមមានទាំងនៅកម្រិតឃុំ-សង្កាត់ផងដែរ ។ វិទ្យាស្ថានជាតិស្ថិតិ ដែលជាផ្នែកមួយនៃអាណត្តិរបស់ខ្លួនក្នុងក្របខ័ណ្ឌនៃផែនការមេស្ថិតិ នឹងធានាឱ្យមានជាបន្តទៀតនូវ គុណភាព ស្តង់ដារ និងភាពអាចជឿជាក់បាន នៃការប្រមូល ការវិភាគ និងការបង្ហាញទិន្នន័យនៅគ្រប់កម្រិតទាំងអស់ តាមរយៈវិធានការអភិវឌ្ឍន៍សមត្ថភាព ។

៣.០៨ ចំពោះធនធានសម្រាប់ការអនុវត្ត*ផយអជ* ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ត្រូវធានាថា ធនធានក្នុងនិងក្រៅប្រទេសនឹងត្រូវបានប្រើប្រាស់សម្រាប់អាទិភាពទាំងឡាយរបស់*ផយអជ* ដូចដែលបានកំណត់និងលើកឡើងនៅក្នុង*ករស* បីឆ្នាំរំកិល ។ *គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា* ក៏ត្រូវបន្តថែរក្សានិងតាមដានទិន្នន័យស្តីពី ការសន្យាពីការផ្តល់ ការសម្រេចផ្តល់ និងការផ្តល់ជាក់ស្តែង នូវមូលនិធិរបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស តាមរយៈរបាយការណ៍សហប្រតិបត្តិការអភិវឌ្ឍន៍ ប្រចាំឆ្នាំ ។

## តារាង៣.១ : គោលដៅជាតិ និងសូចនាករសំខាន់ៗរបស់ផយអជ (ចំណុចដៅ)[១]

### (*) - គោលដៅនិងចំណុចដៅរបស់គអសហ

| | គោលដៅសំខាន់ៗ : ចំណុចដៅ/សូចនាករ | ២០០៥ | ២០១០ | គអសហ-២០១៥ |
|---|---|---|---|---|
| | ***លុបបំបាត់ភាពក្រីក្រនិងភាពអត់ឃ្លានធ្ងន់ធ្ងរ (*)*** | | | |
| ១* | ភាគរយនៃប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រ ២០០៤ | ៣៤,៦៧ | ២៥ | ១៩,៥ |
| | បើគិតតាមភាពគ្របដណ្តប់នៃអង្កេតឆ្នាំ១៩៩៣-១៩៩៤ (៥៩%នៃផ្ទៃដីទូទាំងប្រទេស) | (២៨,០) | | |
| ២* | ភាគរយនៃប្រជាជនតំបន់ជនបទ រស់នៅក្រោមបន្ទាត់ភាពក្រីក្រ ២០០៤ | ៣៩,២ | | |
| | បើគិតតាមភាពគ្របដណ្តប់នៃអង្កេតឆ្នាំ១៩៩៣-១៩៩៤ (៥៦%នៃផ្ទៃដីទូទាំងប្រទេស) | (៣៣,៧) | | |
| ៣* | ប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រស្បៀងអាហារ ២០០៤ | ១៩,៧ | ១៣ | ១០ |
| | បើគិតតាមភាពគ្របដណ្តប់នៃអង្កេតឆ្នាំ១៩៩៣-១៩៩៤ (៥៦%នៃផ្ទៃដីទូទាំងប្រទេស) | (១៤,២) | | |
| | ***លើកកម្ពស់ផលិតភាពនិងផលិតកម្មកសិកម្ម*** | | | |
| ៤ | ទិន្នផលស្រូវក្នុងមួយហិកតា (តោន) | ២,៤ | ២,៤ | |
| ៥ | ផ្ទៃដីស្រោចស្រព (រួមទាំងការស្រោចស្រពដោយប្រព័ន្ធធារាសាស្ត្រ) (%នៃផ្ទៃដាំស្រូវ) | ២០ | ២៥ | |
| ៦ | កំណែទម្រង់ដីធ្លី : ចំនួនប័ណ្ណកម្មសិទ្ធិដីធ្លីដែលផ្តល់ជូនកសិករ (%នៃផ្ទៃដីសរុប) | ១២ | ២៤ | |
| | ***លើកកម្ពស់ក្នុងវិស័យសុខាភិបាល (*)*** | | | |
| ៧* | អត្រាមរណភាពទារក ក្នុង១.០០០កំណើតរស់ | ៦៦ | ៦០ | ៥០ |
| ៨* | អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ ក្នុង១.០០០កំណើតរស់ | ៨២ | ៨៣ | ៦៥ |
| ៩* | មរណភាពមាតា ក្នុង១០០.០០០កំណើតរស់ | ពុំមានតួលេខ | ២៤៣ | ១៤០ |
| ១០* | ការសម្រាលកូនដោយបុគ្គលិកសុខាភិបាលមានជំនាញ (%) | ពុំមានតួលេខ | ៧០ | ៨០ |
| ១១* | អត្រាប្រេវ៉ាឡង់ហ៊ីវ/ជម្ងឺអេដស៍ក្នុងចំណោមមនុស្ស ពេញវ័យអាយុពី១៥-៤៩ឆ្នាំ | ១,៩ | ០,៥ | |
| ១២* | ករណីជម្ងឺគ្រុនចាញ់ អត្រាស្លាប់ | ០,៣៦ | ០,២៥ | ០,១ |
| ១៣* | ករណីអ្នកផ្ទុកជម្ងឺរបេងក្នុង ១០០.០០០នាក់ | ពុំមានតួលេខ | ២១៤ | ១៣៥ |
| ១៤* | ស្ត្រីរៀបការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតទំនើប (%) | ២០,១ | ៤៤ | ៦០ |
| ១៥ | មណ្ឌលសុខភាពដែលផ្តល់សេវាសុខភាពបន្ទាន់ពូជ | ៣៣ | ៤៥ | ៧០ |
| ១៦* | អត្រាពិតនៃការសិក្សានៅបឋមសិក្សា : សរុប | ៩១,៩ | ១០០ | ១០០ |
| | ប្រុស | ៩៣,០ | ១០០ | ១០០ |
| | ស្រី | ៩០,៧ | ១០០ | ១០០ |

[១] សូមអានព័ត៌មានពន្យល់នៅឧបសម្ព័ន្ធ ៣.១៣ ក្នុង*ផយអជ*

| | គោលដៅសំខាន់ៗ : ចំណុចដៅ/សូចនាករ | ២០០៥ | ២០១០ | គអសក-២០១៥ |
|---|---|---|---|---|
| | ***លើកកម្ពស់វិស័យអប់រំ (*)*** | | | |
| ១៧* | អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ : សរុប | ២៦.១ | ៥០ | ១០០ |
| | ប្រុស | ២៧.៣ | ៥០ | ១០០ |
| | ស្រី | ២៤.៨ | ៥០ | ១០០ |
| ១៨* | អត្រាគង់វង្ស : ថ្នាក់១-៦ | ៥៣.១ | ១០០ | ១០០ |
| ១៩* | អត្រាគង់វង្ស : ថ្នាក់១-៩ | ២៩.៣ | ៥០ | ១០០ |
| ២០* | កុមារអាយុ ៦-១៤ឆ្នាំ មិនបានចូលរៀន (%) | ១២.៣ | ១១ | 0 |
| | ***ការអភិវឌ្ឍជនបទ*** | | | |
| ២១* | ផ្លូវជនបទដែលបានស្តារ នៃប្រវែងផ្លូវសរុប ២៨.000 គម | ២២.៧00 | ២៥.000 | ២៨.000 |
| ២២* | លទ្ធភាពទទួលបានទឹកស្អាតបរិភោគ (%នៃប្រជាជនជនបទ) | ៤១.៦ | ៤៥ | ៥0 |
| ២៣* | លទ្ធភាពទទួលបានអនាម័យ (%នៃប្រជាជនជនបទ) | ១៦.៤ | ២៥ | ៣0 |
| | ***ចីរភាពបរិស្ថាន (*)*** | | | |
| ២៤* | ផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ (%នៃផ្ទៃដីសរុប) | ៦0 | ៦0 | ៦0 |
| ២៥* | ការប្រើប្រាស់អុស-ធ្យូង : គ្រួសារ (%) | ៨៣.៩ | ៦១ | ៥២ |
| ២៦* | ការទទួលបានប្រភពទឹកស្អាត (%នៃប្រជាជនទីប្រជុំជន) | ៣៥ | ៧៥ | ៨0 |
| ២៧* | ការទទួលបានការកែលម្អអនាម័យ (%នៃប្រជាជនទីប្រជុំជន) | ៥៥ | ៦៧ | ៧៤ |
| | ***សបធម៍យេនឌ័រ (*)***[១] | | | |
| ២៨ | បញ្ជ្រាបយេនឌ័រនៅគ្រប់មជ្ឈដ្ឋាន | | | |
| ក | ក្រសួង-ស្ថាប័នដែលបានរៀបចំផែនការសម្ភាពបញ្ជ្រាបយេនឌ័រផ្ទាល់របស់ខ្លួន | ២ | ២៧ | |
| ខ | ក្រសួង-ស្ថាប័នដែលបានអនុវត្តផែនការសម្ភាពបញ្ជ្រាបយេនឌ័រផ្ទាល់របស់ខ្លួន | ២ | ១៥ | ២៧ |
| ២៩* | ការចូលរួមរបស់ស្ត្រីក្នុងការងារទទួលកម្រៃ % : វិស័យកសិកម្ម | ៥២.៥ | ៥0 | ៥0 |
| | វិស័យឧស្សាហកម្ម | ៥៣.៥ | ៥0 | ៥0 |
| | វិស័យសេវាកម្ម | ២៧.0 | ៣៧ | ៥0 |
| ៣0* | កម្រិតយល់ដឹងថា អំពើហិង្សាប្រឆាំងនឹងស្ត្រី ជាអត្តចរិកខុសឆ្គងនិងឧក្រិដ្ឋកម្ម(%) | ៤.៥ | ៥0 | ១00 |
| | ***កំណែទម្រង់*** | | | |
| ៣១ | បង្កើនល្បឿនកំណែទម្រង់អភិបាលកិច្ច | នឹងត្រូវបង្កើតឡើង | | |
| | ***ធ្វើឱ្យបានស្ថេរភាពកំណើនប៉ាក្រូសេដ្ឋកិច្ចខ្ពស់ (*)*** | | | |
| ៣២ | កំណើន *ផសស* ប្រចាំឆ្នាំ គិតតាមថ្លៃថេរ (%) | ១៣.៤0 | ៧.0 | |
| ៣៣ | *ផសស* សម្រាប់មនុស្សម្នាក់ គិតតាមថ្លៃថេរ (ពាន់រៀល) | ១.៨៤៦.៥៩ | ២.៨៨៨.៤៥ | |

[១] ចំណុចដៅដែលពាក់ព័ន្ធនឹងយេនឌ័រ ត្រូវបានបង្ហាញដាច់ដោយឡែកនៅក្នុងវិស័យអប់រំ និងសុខាភិបាល

| គោលដៅសំខាន់ៗ : ចំណុចដៅ/សូចនាករ | | ២០០៥ | ២០១០ | គអសក-២០១៥ |
|---|---|---|---|---|
| ៣៤ | អត្រាអតិផរណា | ៦,៧ | ៣,០ | |
| | ***កែលម្អការប្រើប្រាស់ថវិកា*** | | | |
| ៣៥ | ចំណូលថវិការដ្ឋសរុប : (% នៃ *ផសស*) | ១០,៦០ | ១១,៦០ | |
| ៣៦ | ចំណាយថវិការដ្ឋសរុប : (% នៃ *ផសស*) | ១៣,៣ | ១៤,២ | |
| | ***បង្កើនល្បឿនកំណើនក្នុងវិស័យឧស្សាហកម្មនិងការងារ*** | | | |
| ៣៧ | កំណើនប្រចាំឆ្នាំក្នុងផ្នែកកម្មន្តសាល គិតតាមថ្លៃថេរ (%) | ១០,២ | ៧,២ | |
| ២៨* | ពលកម្មកុមារអាយុ ៥-១៧ឆ្នាំ (%) | ២២,៣ | ១០,៦ | ៨ |
| | ***ទេសចរណ៍*** | | | |
| ៣៨ | ចំនួនភ្ញៀវទេសចរណ៍ប្រចាំឆ្នាំ (ពាន់នាក់) | ១.៣០០ | ៣.១២០ | គ្មាន |
| | ***ការបោសសម្អាតមីន ការជួយសង្គ្រោះជនរងគ្រោះ (*)*** | | | |
| ៤០* | ចំនួនជនរងគ្រោះដោយសារមីន (ស្លាប់ និងរបួស) | ៨៧៥ | ២០០ | ០ |
| ៤១* | *តំបន់ដែលបានបោសសម្អាតមីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ (%)* | ៥០,៣ | ៧៧ | ១០០ |
| | ***ហេដ្ឋារចនាសម្ព័ន្ធ*** | | | |
| ៤២ | ផ្លូវក្រាលកៅស៊ូ (ផ្លូវជាតិនិងផ្លូវខេត្ត) លើប្រវែងផ្លូវសរុប ១១.៣១០ គម | ២.១០០ | ៤.១០០ | |
| | ***ថាមពល*** | | | |
| ៤៣ | ការប្រើប្រាស់ថាមពលអគ្គិសនី (គីឡូវ៉ាត់ម៉ោង/នាក់/ឆ្នាំ) | ៥៤,០១ | ៨៩,១១ | |

# ជំពូកទី៤

# ចំណាយ ធនធាន និងការរៀបចំគម្រូវិធី

## *ចំណាយ/តម្រូវការធនធាន/ការកំណត់ថវិកា*

៤.០១ ការអនុវត្តដោយជោគជ័យនិងទាន់ពេល នូវយុទ្ធសាស្ត្រទាំងឡាយរបស់*ផយអជ* និងការសម្រេចបាននូវចំណុចដៅនានារបស់*ផយអជ* ត្រូវការនូវធនធានក្នុងបរិមាណមួយសមស្រប ជាចាំបាច់ ។ ដោយផ្តោតការយកចិត្តទុកដាក់លើកត្តានានាដែលទើបតែលេចចេញមក រួមទាំង កម្រិតខ្ពស់របស់កំណើនដែលត្រូវបានរំពឹងទុកនាពេលនេះ ការប៉ាន់ស្មានសម្រាប់ការវិនិយោគដែលបានកំណត់នៅក្នុង*ផយអជ* ត្រូវបានធ្វើការកែសម្រួលពី ៦.៤០១,១០លានដុល្លារ ទៅដល់១០.០១៤,៦លានដុល្លារ ដែលភាគច្រើននៃកំណើននេះប្រហែលជាអាចបណ្តាលមកពីការវិនិយោគក្នុងផ្នែកឯកជន (សូមអានផ្នែកលម្អិតនៃតួលេខកែសម្រួល ក្នុងឧបសម្ព័ន្ធ១.២) ។ ទោះជាដូចនេះក្តី ព្យាករណ៍ថ្មីទាំងនេះ មិនបានគិតបញ្ចូលនូវគ្រប់តម្រូវការបន្ថែមទាំងអស់ សម្រាប់ការវិនិយោគនានាក្នុងវិស័យសាធារណៈ (ជាពិសេស ក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធដែលមានភាពចាំបាច់ខ្លាំង ដើម្បីជំរុញឱ្យមាននិងរក្សានិចលភាពនៃកំណើនសេដ្ឋកិច្ចដ៏ខ្លាំង) ក្នុងវិស័យសង្គមកិច្ច (ដូចជា វិស័យអប់រំនិង សុខាភិបាល) ក្នុងជំនួយបច្ចេកទេសនិងអង្កេត ក៏ដូចជា ក្នុងតម្រូវការបន្ថែមសម្រាប់ចំណាយចរន្ត ដែលអាចកើតមានឡើងមកពីការវិនិយោគបន្ថែមទៀតក្នុងវិស័យសាធារណៈ ។ អាស្រ័យហេតុនេះ តម្រូវការមូលនិធិសម្រាប់ វិនិយោគក្នុងវិស័យសាធារណៈ ដើម្បីការអនុវត្ត*ផយអជ* ក្នុងអំឡុងពេលឆ្នាំ២០០៦-២០១០ គឺស្ថិតនៅក្នុងកម្រិត ៣.៥០០លានដុល្លារអាមេរិកដូចពីមុនដែរ ដោយមានតម្រូវការប្រហែល ៧០០លានដុល្លារក្នុងមួយឆ្នាំ ដែលមានការកើនឡើងជារៀងរាល់ឆ្នាំ ។ ទោះជាដូចនេះក្តី ការបែងចែកជាលម្អិតនៃចំណាយសរុបនេះ មានការប្រែប្រួលមួយចំនួន ដូចមានបង្ហាញនៅក្នុងតារាងខាងក្រោម :

**តារាង ៤.១ : កម្រិតនៃការវិនិយោគសាធារណៈដែលត្រូវការចាំបាច់សម្រាប់ ២០០៦-២០១០**

(លានដុល្លារអាមេរិក)

| | |
|---|---|
| ១. ការវិនិយោគសាធារណៈ ដូចមានចែងក្នុង ឧបសម្ព័ន្ធ ១.២ | ២.៣៥៣,៨ |
| ២. ចំណាយបន្ថែម : | |
| - តម្រូវការចាំបាច់បន្ថែមសម្រាប់វិស័យសង្គមកិច្ច និងចំណាយអភិបាលកិច្ច | ៣០០,០ |
| - ជំនួយបច្ចេកទេស បណ្តុះបណ្តាល និងអង្កេត | ៥០០,០ |
| - ចំណាយចរន្តបន្ថែម | ៣០០,០ |
| - ទុនបំរុងសម្រាប់វិស័យផលិតកម្ម | ៤៦,២ |
| **ចំណាយសរុប ២០០៦-២០១០** | **៣.៥០០,០** |

៤.០២ យោងតាមតួលេខកែតម្រូវ ចំណាយសរុបក្នុងវិស័យសាធារណៈចំនួន ៣.៥០០លានដុល្លារ ត្រូវបានរំពឹងថា នឹងបានពីប្រភពនានា ដូចខាងក្រោម :

- ធនធានក្នុងស្រុកប្រមាណ ៦៥១,១លានដុល្លារ (អតិរេកថវិកាចរន្ត) ។ តួលេខនេះ មានចំនួនតិចជាងច្រើនពីតួលេខ ៧៨៣,៣លានដុល្លារ ដែលបានរំពឹងទុកនៅក្នុង *ផយអជ* ប៉ុន្តែ តួលេខថយចុះនេះ គឺផ្អែកលើការប៉ាន់ស្មានចុងក្រោយបំផុត ដែលមានលក្ខណៈប្រាកដនិយមច្រើនជាង ។
- ធនធានពីក្រៅប្រទេស (ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសប្រពៃណី) ប្រមាណ ២.៥០០លានដុល្លារ ពុំមានការប្រែប្រួលទេធៀបនឹងការរំពឹងទុករបស់ *ផយអជ* ។
- លម្អៀងចំនួន ៣៤៨,៩លានដុល្លារ ដែលត្រូវការដើម្បីបំពេញតម្រូវការសរុប ៣,៥០០លានដុល្លារ អាចទទួលបានពីប្រភពដូចតទៅ : (១) ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសមិនមែនប្រពៃណី (២) ប្រតិបត្តិការថវិកាល្អប្រសើរជាងមុន (៣) ធនធានបន្ថែមដែលអាចបានមកពីការធ្វើអាជីវកម្មដោយជោគជ័យលើធនធានប្រេងកាតនិងឧស្ម័ន (៤) មូលនិធិទទួលបានពីការលុបចោលបំណុលពីអតីតកាល និង (៥) មូលនិធិបន្ថែមទៀតពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេសប្រពៃណី ដោយមានការបង្កើនលំហូរនៃជំនួយអភិវឌ្ឍន៍ក្នុងពិភពលោក ទៅតាមការសន្យាឱ្យបាន ០,៧ភាគរយនៃ *ផសស* របស់ដៃគូអភិវឌ្ឍន៍ទាំងនោះ ។

៤.០៣ លម្អៀងចំនួន ៣៤៨,៩លានដុល្លារ នៃធនធានសម្រាប់ចំណាយសាធារណៈ អាចកាន់តែត្រូវកើនធំឡើងថែមទៀត ប្រសិនបើការធ្វើវិភាជន៍និងការប្រើប្រាស់ថវិកា មិនត្រូវបានតម្រឹមយ៉ាងពេញលេញទៅនឹងអាទិភាពរបស់ *ផយអជ* ឬអាចនិយាយម្យ៉ាងទៀតថា ប្រសិនបើធនធានទាំងនោះត្រូវបានចំណាយទៅលើគម្រោង ឬការវិនិយោគ ឬសកម្មភាពមិនមែនអាទិភាព ។ ក្នុងពេលកន្លងមក ភាគច្រើននៃធនធានពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេសមិនបានឆ្លងកាត់ថវិការដ្ឋទេ ។ អាស្រ័យហេតុនេះ ប្រការដែលការសំខាន់បំផុតនោះគឺថា ចាប់ពីពេលនេះទៅ ការធ្វើវិភាជន៍ថវិកានិងការគាំទ្រពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស មិនត្រឹមតែត្រូវធ្វើឱ្យកើតមានឡើង តែប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវតម្រឹមឱ្យបានពេញលេញជាមួយអាទិភាពរបស់ *ផយអជ* ផងដែរ ។ ជាងនេះទៀត ជំនួយបច្ចេកទេសទោល ត្រូវតែកម្រិតឱ្យនៅត្រឹមចំនួនមួយតូចល្មម (នៅត្រឹមប្រមាណ ៥០០លានដុល្លារ) ។

៤.០៤ អាស្រ័យហេតុនេះ បញ្ហាប្រឈមចម្បង១ចំពោះមុខគឺ ត្រូវធានាថា (នៅរាល់ពេលណាដែលអាចធ្វើទៅបាន តាមរយៈ យន្តការនៃក្រុមការងារបច្ចេកទេសដែលបានបង្កើតឡើង) :

- គ្រប់កម្មវិធីនិងសកម្មភាពកំពុងដំណើរការ ដែលគាំទ្រផ្នែកហិរញ្ញវត្ថុដោយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ត្រូវបានពិនិត្យមើលឡើងវិញយ៉ាងយកចិត្តទុកដាក់ ហើយបើសិនជាចាំបាច់ ត្រូវតម្រឹមទៅនឹងអាទិភាពរបស់ *ផយអជ* នូវកម្មវិធីនិងសកម្មភាពទាំងនោះឡើងវិញ ។

- ជាពិសេស ប្រឹងប្រែងធ្វើការកាត់បន្ថយសមាសភាគនៃជំនួយបច្ចេកទេសទោលឱ្យបានច្រើនតាមតែអាចធ្វើបាន ដើម្បីសម្រេចបាននូវការផ្ទេរធនធានសុទ្ធសាធសម្រាប់ការវិនិយោគឱ្យបានច្រើនបំផុត ។
- កម្មវិធីថ្មីទាំងអស់ដែលគាំទ្រដោយធនធានក្នុងនិងក្រៅប្រទេស ត្រូវបានផ្សារភ្ជាប់ទៅនឹងអាទិភាពរបស់ *ផយអជ* ។
- ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសទាំងឡាយ (ដែលបានរាប់បញ្ចូលជាពិសេស) នឹងផ្តល់ជំនួយតែក្នុងទម្រង់ជាជំនួយឥតសំណងនិងឥណទាន (ភាគច្រើនក្នុងទម្រង់ជាឥណទានសម្បទាន) ដែលត្រូវបានកម្រិតយ៉ាងច្បាស់ សម្រាប់តែគម្រោងវិនិយោគជាមូលធននានា ។
- ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស (ទ្វេភាគីនិងពហុភាគី) ចាប់ផ្តើមលុបចោលបំណុលពីអតីតកាល ឱ្យបានឆាប់ តាមដែលអាចធ្វើបាន ។
- គ្រប់វិធីសាស្ត្រនៃការផ្តល់ជំនួយក្រៅប្រទេស ត្រូវបានតម្រឹម និងធ្វើឱ្យមានភាពរលូនជាមួយនីតិវិធីនិងដំណើរការរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានអនុម័តរួចហើយ នៅក្នុងគោលបំណងចុងក្រោយបង្អស់ គឺដើម្បីជំរុញឱ្យមានការប្រើប្រាស់ "ការគាំទ្រថវិកា" ដែលជាវិធីសាស្ត្រនៃការផ្តល់ជំនួយក្រៅប្រទេស ដែលរដ្ឋាភិបាលចង់បានបំផុត ។
- បង្កើនល្បឿនការរៀបចំយុទ្ធសាស្ត្រនិងផែនការសកម្មភាពទូទាំងវិស័យ ដោយផ្តោតអាទិភាពទៅលើវិស័យសំខាន់ៗ ដូចជា កសិកម្ម ដែលមានឥទ្ធិពលលើជីវភាពរស់នៅ និងការរស់នៅរបស់ប្រជាជនភាគច្រើន ។

៤.០៥ ព្យាករណ៍សម្រាប់ ការវិនិយោគរបស់ផ្នែកឯកជន ក្នុងផ្នែកផ្សេងៗនៃសកម្មភាពសេដ្ឋកិច្ច ត្រូវបានបង្កើនដល់ ៧.១២២.១លានដុល្លារ[១] ក្នុងរយៈពេលពីឆ្នាំ២០០៦-២០១០ បើប្រៀបធៀបនឹងការប៉ាន់ស្មាន នៅក្នុង*ផយអជ* ដែលមានតែ ៤.០១៦.៥លានដុល្លារប៉ុណ្ណោះ ។ កំណើនប្រហែល ៧០ភាគរយនេះ ហាក់ដូចជាមានភាពសុទិដ្ឋិនិយមពេក ប៉ុន្តែត្រូវបានចាត់ទុកថាអាចសម្រេចបាន ។ កំណើននេះ ត្រូវបានព្យាករដោយផ្អែកលើការកើនឡើងខ្ពស់ដែលបានរំពឹងទុកថានឹងមាននៅក្នុងការវិនិយោគក្នុងផ្នែកឯកជន (ពីប្រភពក្នុងនិងក្រៅប្រទេស) ដោយត្រូវបានរំពឹងថា នឹងកើតមានឡើង ជាពិសេស នៅក្នុងវិស័យប្រេងកាតនិងឧស្ម័នធម្មជាតិ ព្រមទាំង ក្នុងវិស័យថាមពលនិងអគ្គិសនី ។ រាជរដ្ឋាភិបាលកម្ពុជា នឹងខិតខំប្រឹងប្រែងក្នុងការធ្វើឱ្យប្រសើរឡើងជាលំដាប់នូវបរិយាកាសវិនិយោគនៅកម្ពុជា តាមរយៈការផ្តោតកិច្ចខិតខំប្រឹងប្រែងនានា ក្នុងនោះរួមមាន ការធ្វើឱ្យល្អប្រសើរជាងមុននូវហេដ្ឋារចនាសម្ព័ន្ធ កំណែទម្រង់និងការពង្រឹងវិស័យហិរញ្ញវត្ថុ ដើម្បីបញ្ចេញទុនអសកម្មទៅឱ្យការវិនិយោគក្នុងផ្នែកផលិតកម្ម និងការគាំទ្រតាមរយៈការសម្រួលក្របខ័ណ្ឌច្បាប់និងនីតិវិធី ដើម្បីបង្កើតឡើងនូវបរិស្ថានមួយដែលមានស្ថេរភាពនិងមានភាពងាយស្រួល សម្រាប់សកម្មភាពទាំងឡាយដែលមានលក្ខណៈប្រកួតប្រជែង ។

[១] សូមអានឧបសម្ព័ន្ធ ១:២

៤.០៦ ការធ្វើវិភាជន៍និងការបែងចែកលម្អិតនូវចំណាយហិរញ្ញវត្ថុសរុបសម្រាប់ *ផយអជ* : *ផយអជ* ត្រូវបានធ្វើវិភាជន៍[១] រួចហើយនូវចំណាយសរុបមានចំនួន ៣.៥០០លានដុល្លារសម្រាប់វិស័យនានា ដើម្បីធ្វើឱ្យសម្រេចបាននូវគោលដៅនិងទិសដៅរួម ទាំងផ្នែកបរិមាណនិងគុណភាព ជាពិសេស ការកាត់បន្ថយភាពក្រីក្រនិង *គអសក* ។ ការធ្វើវិភាជន៍នេះ ដែលផ្តល់ថវិកាចំនួន ៣២.៨៥ភាគរយទៅដល់វិស័យសង្គមកិច្ច និង៦២ភាគរយ ដើម្បីផ្តល់ផលប្រយោជន៍ដល់តំបន់ជនបទ ពុំមានការប្រែប្រួលទេ ដូចមានបង្ហាញជូនក្នុងតារាង ៤.២ ។

**ការរៀបចំកម្មវិធីចំណាយសម្រាប់ *ផយអជ***

៤.០៧ ព្យាករណ៍ការធ្វើវិភាជន៍ថវិកាដែលបានធ្វើឡើង សម្រាប់វិស័យនានានៅក្នុងក្របខ័ណ្ឌ *ផយអជ* (តារាង ៥.២) គឺជាការតម្រង់ទិសនិងការចង្អុលបង្ហាញជារួម សម្រាប់ការអភិវឌ្ឍ ។ ដើម្បីឱ្យអាចដំណើរការអនុវត្ត ជាក់ស្តែងបានការតម្រង់ទិសនិងការចង្អុលបង្ហាញទាំងនោះ ត្រូវធ្វើការបំបែកលម្អិតប្រចាំឆ្នាំបន្ថែមទៀត ឱ្យទៅជាសំណើគម្រោងសម្រាប់ចំណាយចរន្តនិងចំណាយមូលធន ។ ក្នុងន័យនេះ ឧបករណ៍មួយចំនួនខាងក្រោម ត្រូវបានដាក់ឱ្យដំណើរការ :

- កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល (*កវស*) ដែលមានគម្រោងវិនិយោគជាទុន និងគម្រោងជំនួយបច្ចេកទេស ដែលប្រើប្រាស់ប្រភពធនធានពីថវិកាក្នុងស្រុកនិងពីក្រៅប្រទេស (ប៉ុន្តែពុំរាប់បញ្ចូលការចំណាយចរន្តទេ) ត្រូវបានរៀបចំឡើងដោយក្រសួងផែនការ ។
- ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមបីឆ្នាំរំកិល ដែលរួមបញ្ចូលចំណាយថវិកា គិតទាំងចំណាយមូលធនទាំងចំណាយចរន្ត ត្រូវបានរៀបចំឡើង ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។
- ថវិកាប្រចាំឆ្នាំ (ដែលរួមបញ្ចូលទាំងចំណាយមូលធននិងចំណាយចរន្ត) ត្រូវរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។
- ការប្រជុំពិគ្រោះយោបល់យ៉ាងទៀតទាត់ រវាងរាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ដែលត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា និងក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីធានាថា ការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសពិតជាបានតម្រឹមយ៉ាងពេញលេញជាមួយអាទិភាពរបស់ *ផយអជ* ។

៤.០៨ កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិលចំនួនពីរ សម្រាប់ឆ្នាំ២០០៦-២០០៨និងឆ្នាំ២០០៧-២០០៩[២] ដែលត្រូវបានរៀបចំរហូតមកទល់ពេលនេះ បានព្យាយាមតម្រឹមយ៉ាងជាក់លាក់ នូវគម្រោងទាំងឡាយទៅនឹងអាទិភាព របស់ *ផយអជ* ទោះបីជាថវិកាប្រមាណ ៤៨ភាគរយដែលត្រូវការសម្រាប់ដំណាក់កាលឆ្នាំ២០០៧-២០០៩

---

[១] តារាង ៥.២ នៃ *ផយអជ*

[២] មើលតារាងទី១ នៃកម្មវិធីវិនិយោគសាធារណៈ ឆ្នាំ ២០០៧-២០០៩ នៅឧបសម្ព័ន្ធ ១.៤

(គឺស្មើ ១.០៦០លានដុល្លារនៃតម្រូវការថវិកាចំនួន ២.២០៩លានដុល្លារដែលបានកំណត់) នៅតែចាំបាច់ត្រូវស្វែងរកឱ្យបានឬធានាឱ្យមាន សម្រាប់ដំណាក់កាលនេះ ។ ទន្ទឹមនឹងពេលដែលតារាង ៤.២ បង្ហាញពីការធ្វើវិភាជន៍ដែលចង់បានបំផុតនៅក្នុង*ផយអជ កវស ២០០៧-២០០៩* នៅក្នុងឧបសម្ព័ន្ធ ១.៤ បង្ហាញជាលម្អិតនូវកម្មវិធីនិងគម្រោងទាំងឡាយ (រួមទាំងកម្មវិធីនិងគម្រោងជាច្រើនដែលត្រូវបានបង្ហាញថាជាអាទិភាពខ្ពស់ ប៉ុន្តែនៅត្រូវការទុនដើម្បីអនុវត្ត) ដែលត្រូវបានរំពឹងទុកដោយរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើឱ្យមានការវិនិយោគចាំបាច់ នៅក្នុងវិស័យសាធារណៈ ។

៤.០៩ កិច្ចខិតខំប្រឹងប្រែងជាច្រើន កំពុងដំណើរការរៀបចំឯកសារ ដើម្បីកំណត់លំដាប់លំដោយឱ្យបានត្រឹមត្រូវនូវឯកសារមួយចំនួន (ដូចជា *កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម* និង *របាយការណ៍សហប្រតិបត្តិការអភិវឌ្ឍន៍*) និងដើម្បីធ្វើឱ្យមានភាពរលូនជាមួយគ្នា រវាងឯកសារទាំងនេះ ។ ដំណើរការនេះ និងការតាមដានត្រួតពិនិត្យនូវវឌ្ឍនភាពនៃការអនុវត្ត*ផយអជ* កំពុងត្រូវបានដំណើរការដូចបានគ្រោងទុកនៅក្នុងឯកសារ*ផយអជ* ដោយមានការសម្របសម្រួលនិងកិច្ចសហការយ៉ាងជិតស្និទ្ធរវាងស្ថាប័នកណ្តាល ទាំងបួនគឺ *ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា* ។

## តារាង ៤.២ ៖ ទិន្នន័យរបស់ផយអជ តាមវិស័យ ២០០៦-២០១០

(គិតជាលានដុល្លារ)

| វិស័យ | បរិមាណ | ភាគរយ | ជនបទ | ភាគរយ | ទីប្រជុំជន | ភាគរយ | កំណត់ |
|---|---|---|---|---|---|---|---|
| | | | | | | | ១ |
| **វិស័យសង្គមកិច្ច** | | | | | | | |
| អប់រំ ៖ (ក្នុងនោះ ការអប់រំមូលដ្ឋាន ៦០%) | ៥៥០ | ១៥,៧១ | ៣៣០ | ៦០ | ២២០ | ៤០ | ២ |
| សុខាភិបាល | ៦០០ | ១៧,១៤ | ៤២០ | ៧០ | ១៨០ | ៣០ | |
| **សរុប** | **១.១៥០** | **៣២,៨៦** | | | | | |
| **វិស័យសេដ្ឋកិច្ច** | | | | | | | |
| កសិកម្មនិងការគ្រប់គ្រងដីធ្លី ៖ ក្រៅពីដំណាំ | ១៥០ | ៤,២៩ | ១៤៣ | ៩៥ | ៨ | ៥ | ៣ |
| ដំណាំតាមរដូវ ៖ ស្រូវ និងផ្សេងៗ | ២០០ | ៥,៧១ | ២០០ | ១០០ | ០ | | |
| អភិវឌ្ឍន៍ជនបទ | ៣៥០ | ១០,០០ | ៣៥០ | ១០០ | ០ | | ៤ |
| កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម | ៨០ | ២,២៩ | ១២ | ១៥ | ៦៨ | ៨៥ | ៥ |
| **សរុប** | **៧៨០** | **២២,២៩** | | | | | |
| **ហេដ្ឋារចនាសម្ព័ន្ធ** | | | | | | | |
| ដឹកជញ្ជូន (ផ្លូវថ្នល់ កំពង់ផែ ផ្លូវដែក អាកាសចរ) | ៥៥០ | ១៥,៧១ | ២៧៥ | ៥០ | ២៧៥ | ៥០ | ៦ |
| ទឹក និងអនាម័យ (មិនគិតនៅជនបទ) | ១៥០ | ៤,២៩ | ១៥ | ១០ | ១៣៥ | ៩០ | ៧ |
| ថាមពល និងអគ្គិសនី | ១២០ | ៣,៤៣ | ៦០ | ៥០ | ៦០ | ៥០ | ៨ |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | ៦០ | ១,៧១ | ៣០ | ៥០ | ៣០ | ៥០ | ៩ |
| **សរុប** | **៨៨០** | **២៥,១៤** | | | | | |
| **សេវាកម្ម និងកម្មវិធីអន្តរវិស័យ** | | | | | | | |
| ការបញ្ជ្រាបយេនឌ័រ | ៣០ | ០,៨៦ | ៩ | ៣០ | ២១ | ៧០ | ១០ |
| ទេសចរណ៍ | ៣០ | ០,៨៦ | ៨ | ២៥ | ២៣ | ៧៥ | |
| បរិស្ថាន និងការអភិរក្ស | ១០០ | ២,៨៦ | ៩០ | ៩០ | ១០ | ១០ | ១១ |
| សហគមន៍ និងសេវាកម្មសង្គម | ៨០ | ២,២៩ | ៦០ | ៧៥ | ២០ | ២៥ | |
| វប្បធម៌ និងសិល្បៈ | ៣០ | ០,៨៦ | ១៥ | ៥០ | ១៥ | ៥០ | |
| អភិបាលកិច្ច និងរដ្ឋបាល | ២២០ | ៦,២៩ | ៤៤ | ២០ | ១៧៦ | ៨០ | ១២ |
| **សរុប** | **៤៩០** | **១៤,០០** | | | | | |
| មិនទាន់បែងចែក | ២០០ | ៥,៧១ | ១០០ | ៥០ | ១០០ | ៥០ | ១៣ |
| **សរុបរួម** | **៣.៥០០** | **១០០%** | **២.១៦០** | **៦២%** | **១.៣៤០** | **៣៨%** | **១៤** |

***កំណត់ពន្យល់ ៖***

១. ក. បរិមាណតាមវិស័យនីមួយៗ រួមមាន : ធនធានដែលបានមកពីគ្រប់ប្រភពទាំងអស់ : រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ក្រៅប្រទេស (ចំណាយផ្ទាល់ដោយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ឬតាមរយៈរាជរដ្ឋាភិបាលកម្ពុជា) ។

ខ. ចំណាយមូលធន ចំណាយចរន្តបន្ថែម ជំនួយបច្ចេកទេស ចំណាយក្នុងការតាមដានត្រួតពិនិត្យ ប្រមូលទិន្នន័យ ការថែរក្សាគេហទំព័រ ។

គ. តួលេខជនបទ-ទីប្រជុំជន ជាតួលេខចង្អុលបង្ហាញជាកំណត់សម្គាល់ និងត្រូវផ្តោតការយកចិត្តទុកដាក់លើ ។

ឃ. បរិមាណទាំងនេះ ក៏រួមបញ្ចូលផងដែរនូវប្រាក់ឧបត្ថម្ភទាំងអស់ទៅថ្នាក់ខេត្ត ស្រុក និងឃុំ ដែលនឹងត្រូវអនុវត្តដោយថ្នាក់ទាំងនោះ ។

២. ក. រួមបញ្ចូលទាំង យុវជន និងកីឡា ។

ខ. ៦០ភាគរយ នៃចំនួនសរុប នឹងត្រូវបែងចែកសម្រាប់ការអប់រំមូលដ្ឋាន ។

៣. រួមបញ្ចូលទាំង ការនេសាទ ការបោសសម្អាតមីន និងសកម្មភាពផ្សេងៗ លើកលែងតែដំណាំតាមរដូវ ហើយមិនរាប់បញ្ចូលព្រៃឈើដែលបានបង្ហាញ នៅក្នុងផ្នែកបរិស្ថាននិងការអភិរក្ស ។

៤. ការអភិវឌ្ឍជនបទ : រួមបញ្ចូលទាំង កម្មវិធីសីលា ផ្លូវលំ ទីផ្សារ ប្រព័ន្ធធារាសាស្ត្រ ការផ្គត់ផ្គង់ទឹកនិងអនាម័យ វិមជ្ឈការនិងវិសហមជ្ឈការ អភិបាលកិច្ចមូលដ្ឋាន ។

៥. រួមបញ្ចូលនូវ : ការបង្កើតការងារ និងបញ្ហាកម្លាំងពលកម្ម ។

៦. មិនរាប់បញ្ចូលនូវផ្លូវជនបទ ។ ផ្លូវជាតិនិងផ្លូវខេត្ត មានផលប្រយោជន៍ដល់តំបន់ជនបទ ដូច្នេះផ្លូវទាំងពីរប្រភេទនេះមានសមាមាត្រ ៥០ភាគរយ ។ ផ្នែកឯកជនដែលមានការពាក់ព័ន្ធ ។ រួមបញ្ចូលទាំង ចំណាយបន្ថែមលើការថែទាំ ។

៧. មិនរាប់បញ្ចូលនូវសកម្មភាពនៅតំបន់ជនបទ ដែលបានកំណត់នៅក្នុងការអភិវឌ្ឍជនបទ ។

៨. ភាគច្រើនបំផុតនៃការវិនិយោគក្នុងវិស័យនេះ គប្បីត្រូវជំរុញលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន ។

៩. ភាគច្រើនបំផុតការវិនិយោគក្នុងវិស័យនេះ គប្បីត្រូវជំរុញលើកទឹកចិត្តឱ្យមានការចូលរួមពីផ្នែកឯកជន ។

១០ ជាពិសេស សម្រាប់ការបង្កើតការយល់ដឹង និងការបញ្ច្រាប ។ វិស័យនីមួយៗផ្សេងទៀត នឹងបញ្ចូលសកម្មភាពនានាទៅក្នុងការងាររបស់គេ ។

១១ រួមបញ្ចូលទាំងព្រៃឈើ ។

១២ រួមបញ្ចូលទាំង :

ក. កំណែទម្រង់ទាំងអស់ ដូចជា កំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ម៉ាក្រូសេដ្ឋកិច្ច កំណែទម្រង់សារពើពន្ធ និងកំណែទម្រង់ផ្សេងៗទៀត ។

ខ. ការសិក្សានិងការអង្កេតរបស់វិទ្យាស្ថានជាតិស្ថិតិ ដូចជា ជំរឿនប្រជាជនឆ្នាំ២០០៨ ការវាយតម្លៃភាពក្រីក្រ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ការតាមដានត្រួតពិនិត្យការអនុវត្ត *ផយអជ* ។ល។

គ. ការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ល។

ឃ. ការបោះឆ្នោតនានា ។

ង. សកម្មភាពរដ្ឋបាលសាធារណៈផ្សេងៗទៀត ។

១៣. ទុនបម្រុងសម្រាប់ការបំបែរទិសដៅរបស់ការប្រើប្រាស់ប្រភពធនធាន បើសិនជាចាំបាច់ ។

១៤. ភាពខុសគ្នាបន្តិចបន្តួចក្នុងតួលេខសរុបនានា (ជនបទ ទីប្រជុំជន) និងតួលេខសរុបរួម អាស្រ័យទៅនឹងការតម្រឹមលេខទសភាគ។

# ជំពូកទី៥

## សេចក្តីសន្និដ្ឋាន

៥.០១ ក្នុងបណ្តាជំពូកមុនៗទាំងឡាយ ឯកសារនេះបានបង្ហាញពី ការធ្វើបច្ចុប្បន្នភាពលើតួលេខថ្មីៗដែលបានមកពីការអង្កេតនានា ការប្រែប្រួលដែលបានកើតឡើងមានឡើង និងវឌ្ឍនភាពដែលបានធ្វើឱ្យមានឡើង ចាប់តាំងពីពេលដែល *ផយអជ* ត្រូវបានអនុម័តដោយគណៈមន្ត្រី នាដើមឆ្នាំ២០០៦។ ឯកសារនេះក៏បានបង្ហាញផងដែរពីការកែតំរូវឡើងវិញនូវបណ្តាគោលដៅនិងចំណុចដៅទាំងឡាយសំរាប់ឆ្នាំ២០១០ រួមទាំង តម្រូវការធនធានដែលត្រូវបានពិនិត្យឃើញថាចាំបាច់ ។ ទន្ទឹមនឹងនេះ របាយការណ៍នេះ បានគូសបញ្ជាក់ថា ធាតុចូលសម្រាប់តាមដានត្រួតពិនិត្យការអនុវត្ត *ផយអជ* ត្រូវរៀបចំឡើង ដោយមានការវិភាគមួយលម្អិតនិងច្បាស់លាស់ជាងមុន អំពីមូលហេតុនៃជោគជ័យនិងការមិនសម្រេចបាន សំដៅធ្វើឱ្យរបាយការណ៍វឌ្ឍនភាព ក្លាយជាឧបករណ៍មួយ សម្រាប់ផ្តល់ព័ត៌មានជូនអ្នកធ្វើការសម្រេចចិត្តផ្នែកគោលនយោបាយ អំពីអនុសាសន៍ជាគោលនយោបាយទាំងឡាយដែលត្រូវយកទៅអនុវត្ត ដើម្បីសម្រេចបាននូវគោលដៅនិងចំណុចដៅទាំងឡាយតាមវិស័យ ។ ក្របខ័ណ្ឌតាមដានត្រួតពិនិត្យដ៏ច្បាស់លាស់មួយ នឹងធ្វើការតម្រង់ទិសនិងធានាឱ្យមានការតាមដានត្រួតពិនិត្យ យ៉ាងជាប់លាប់លើវឌ្ឍនភាពក្នុងការអនុវត្ត *ផយអជ* ។

៥.០២ ដូចដែលបានបង្ហាញនៅក្នុង *ផយអជ* កត្តាក្នុងនិងក្រៅប្រទេសមួយចំនួនដែលមិនអាចដឹងជាមុនបាននឹងអាចកើតមានឡើង។ កត្តាទាំងនោះ អាចរារាំងមិនឱ្យការអនុវត្តយុទ្ធសាស្ត្រ ផែនការ និងសកម្មភាពនានា ដូចដែលមានចែងនៅក្នុង *ផយអជ* និងយុទ្ធសាស្ត្រតាមវិស័យដែលបានរៀបចំឡើងក្នុងក្របខ័ណ្ឌ *ផយអជ* ប្រព្រឹត្តទៅបានប្រកបដោយជោគជ័យ និងទៅតាមការគ្រោងទុក ។ កត្តាទាំងនោះរួមមាន :

- ធនធានទាំងឡាយដែលត្រូវបានរំពឹងទុក មិនអាចមានសម្រាប់ការប្រើប្រាស់ ជាពិសេស ធនធានពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ។
- ថ្លៃប្រេងនិងឧស្ម័នក្នុងពិភពលោក នៅតែបន្តស្ថិតក្នុងកម្រិតខ្ពស់នៅឡើយ (ខ្ពស់ជាងពីរដងនៃឆ្នាំ២០០៤) ដែលធ្វើឱ្យអតិផរណាកើនឡើងខ្ពស់ ។
- ស្ថានភាពនយោបាយនិងសង្គមនៅតាមតំបន់និងក្នុងពិភពលោក បាននិងកំពុងធ្លាក់ចុះ ដោយសារស្ថានភាពភេរវកម្មដែលកើតឡើងភ្លាមៗ។
- របាំងពាណិជ្ជកម្មអន្តរជាតិ មិនទាន់ត្រូវបានលុបបំបាត់ចោល ទៅតាមល្បឿនដែលបានគ្រោងទុក ។
- ការលេចឡើងនៃជំងឺនានា ដូចជា ជំងឺផ្តាសាយបក្សី ឬជំងឺថ្មីៗផ្សេងទៀត ។

- គ្រោះធម្មជាតិដែលកើតឡើងលើសពីកម្រិតធម្មតា ដូចជា ការកើតឡើងផ្ទួនៗនៃគ្រោះរាំងស្ងួត ឬទឹកជំនន់ ដែលនឹងប៉ះពាល់ដល់ផលិតកម្មដំណាំ និងបំផ្លិចបំផ្លាញដល់ហេដ្ឋារចនាសម្ព័ន្ធ។

៥.០៣ ការងារដែលយើងត្រូវធ្វើតទៅមុខទៀត គឺមានលក្ខណៈប្រឈម និងលំបាក ។ ទោះបីជាដូចនេះក្តី រាជរដ្ឋាភិបាលកម្ពុជា មានជំនឿជាក់ថា យើងអាចនឹងអនុវត្ត *ផយអជ* យ៉ាងពេញលេញទៅបានអាស្រ័យទៅនឹងការផ្លាស់ប្តូរ ដែលនឹងត្រូវធ្វើឱ្យកើតមានឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដោយពិនិត្យពិចារណាលើតថភាពទាំងឡាយដែលកំពុងកើតមានឡើង ហើយក៏ជឿជាក់ដែរថា ធនធានទាំងឡាយដែលត្រូវការសម្រាប់ការអនុវត្ត *ផយអជ* នឹងមានគ្រប់គ្រាន់ដើម្បីគោលបំណងនេះ ។ រាជរដ្ឋាភិបាលកម្ពុជា សង្ឃឹមថានឹងទទួលបាននូវកិច្ចសហប្រតិបត្តិការយ៉ាងពេញលេញពីអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ (ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងក្រសួង-ស្ថាប័ន) ក្នុងការធ្វើឱ្យសម្រេចបាននូវគោលដៅទាំងឡាយរបស់ *ផយអជ* ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាទាំងអស់ ជាពិសេស ក្នុងការបន្ថយកម្រិតភាពក្រីក្រឱ្យបានឆាប់រហ័ស ។

**ឧបសម្ព័ន្ធ ១.១**

## កម្ពុជា ៖ សូចនាករសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ច

### ការព្យាករណ៍សម្រាប់ឆ្នាំ ២០០៦-២០១០

| **សូចនាករសំខាន់ៗ** | **២០០៥** | **២០០៦** | **២០០៧** | **២០០៨** | **២០០៩** | **២០១០** |
|---|---|---|---|---|---|---|
| | | | | | | |
| ***ផសស*** (ថ្លៃថេរ) ពាន់លានរៀល | ២១.៨១២ | ២៤.០៨០ | ២៥.៨៣១ | ២៧.៥៤១ | ២៩.៤២០ | ៣១.៩៩២ |
| *ផសស* គិតតាមថ្លៃថេរ (% កំណើន) | ១៣.៤ | ១០.៨ | ៧.៣ | ៦.៦ | ៦.៨ | ៧.០០ |
| អតិផរណាប្រាក់រៀល (មធ្យមប្រចាំឆ្នាំ - %) | ៥.៨ | ៤.៧ | ៣.០ | ៣.០ | ៣.០ | ៣.០ |
| វិនិយោគផ្ទាល់ពីបរទេស (លានដុល្លារ) | ៣៧៥ | ៤៧៥ | ៥៣០ | ៥៧៣ | ៦១៣ | ៦២០ |
| ទុនបម្រុងបរទេសសរុប (ចំនួនខែនៃការនាំចូល) | ២.៨ | ២.៩ | ៣.០ | ៣.០ | ៣.០ | ៣.០ |
